៨

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៩ ខែ សីហា

ព.ស. ២៥១០ គ.ស. ១៩៦៧

– ភ្នំពេញ –

ÉCOLE FRANÇAISE D'EXTRÊME-ORIENT
BIBLIOTHÈQUE
F.205
P.O.

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

១ – បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . ៧៧៩
២ – សម្ដែងអំពីសុខនិងទុក្ខ ដែលកើតអំពីកម្ម ព្រះសាសនមុនី កិម-ទូ រៀបរៀង . ៧៨៩

*ផ្នែកអក្សរសាស្ត្រ*

៣ – ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន-គីមសៀ រៀបរៀង (ត) . . . ៨០៤
៤ – វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង–ខាត់ រៀបរៀង (ត) . . . . . ៨១២
៥ – បណ្ដាំកសិករខ្មែរ ដោយសហ. អ៊ុង-ស៊ុមន៍ . . . . . . . . ៨១៦
៦ – ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . ៨២៥
៧ – រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . ៨៣៦
៨ – ឯកសារកម្ពុជសុរិយា លោក ឌ.គាម ប្រមូលរៀបរៀង (ត) . . . . . . ៨៤៤
៩ – ជីវប្រវត្តិ ព្រះមុនីកោសល សួរ-ហាយ ចៅអធិការវត្តទីពោធិវង្ស អធិបតីរង ក្រុមជំនុំព្រះត្រៃបិដក . . . . . . . . . . . . . . ៨៥៨

## ផ្នែកកំណត់ និង ប្រវត្តិការណ៍


១០ - សកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ ក្នុងខែមិថុនា និង កក្កដា ១៩៦៧ . . . . . ៨៨២

១១ - ពិធីប្រគល់បរិញ្ញាប័ត្រនៃពុទ្ធិកមហាវិទ្យាល័យ . . . . . . . . . . ៨៨៥

– សុន្ទរកថា របស់សហជីវិនអគ្គលេខាធិការ ពុទ្ធិកមហាវិទ្យាល័យ . . . . ៨៨៦

– សុន្ទរកថា ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ. . . . . . ៨៩៨


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០៛០០ ។

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យជុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

## បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(៣)

លោក សម-ថាំង ប្រែ - រៀបរៀង

ប្រ. ចូរអ្នកនាំឧទាហរណ៍ជាសំអាងបន្តិចមកមើល?

ឆ្លើ. (មានកាលថ្ងៃមួយ) ព្រះអានន្ទត្រាច់ទៅជិតអណ្តូងទឹកមួយ មានការស្រេកទឹក ក៏បិណ្ឌបាតទឹកនាងប្រក្រតី ដែលជាធីតានៃជនចណ្ឌាល ។ នាងនោះ ក៏ទូលតបទៅព្រះអានន្ទវិញថា ខ្ញុំម្ចាស់ជាកូនចណ្ឌាល ថោកទាបណាស់ លោកម្ចាស់ទានទឹកដែលខ្ញុំម្ចាស់នឹងប្រគេននេះ សេចក្តីសៅហ្មងនឹងឆ្លងជិតជាមដល់លោកម្ចាស់ពុំខាន ។ ព្រះអានន្ទតបទៅវិញថា "អាត្មាពុំបានបិណ្ឌបាតវណ្ណៈទេ គឺសុំទឹកឆាន់ទេតើ" ។ នាងនោះក៏មានចិត្តរីករាយ ហើយប្រគេនទឹកដល់ព្រះអានន្ទ ។ ព្រះពុទ្ធជាម្ចាស់ជ្រាបហើយ ក៏ទទួលអនុមោទនា ។

ប្រ. ក្នុងសេលសូត្រ ព្រះបរមគ្រូទ្រង់សំដែងអំពីមនុស្សម្នាក់ក្នុងពួក "បរិយសោឋាក" ថា ដូចម្ដេច?

ឆ្លើ. ថា ដោយការបំពេញកុសលធម៌ បុរសនោះក៏មានកេរ្តិ៍ឈ្មោះល្បីល្បាញទូទៅ, ថា ពួកក្សត្រិយ៍និងព្រាហ្មណ៍ សឹងនាំគ្នាចូលទៅបំរើ លុះរំលាងខន្ធទៅ បុរសនោះនឹងបានទៅកើតក្នុងព្រហ្មលោក; ឯពួកព្រាហ្មណ៍ទាំងឡាយ នឹងធ្លាក់ទៅក្នុងនរក ដោយអកុសលកម្មរបស់ខ្លួន ។

ប្រ. ព្រះពុទ្ធសាសនាប្រដៅថាដួងព្រលឹងនឹងមិនចេះរលត់ឬ ?

ឆ្លើ. ពាក្យថាព្រលឹង ដែលអ្នកលង់ខ្លៅប្រើនោះ ព្រះពុទ្ធសាសនាសំគាល់ថាជាគំនិតខុស ។ កាលបើវត្ថុ ឬ ធម្មជាតិទាំងអស់ប្រែប្រួលហើយ មនុស្សក៏ដូច្នោះដែរ សរីរៈកងកាយក៏សឹងតែប្រែក្លាយគ្មានសល់ទាំងអស់ - វត្ថុដែលលុះដោយសេចក្ដីវិបរិត ប្រែប្រួលហើយគ្មានខ្លឹមអ្វីទេ, ហេតុដូច្នេះ គ្មានវត្ថុអ្វីមួយដែលតាំងនៅជានិច្ចថិតថេរសោះឡើយ ។

ប្រ. ហេតុដូចម្ដេចក៏មានទំនាស់នឹងពាក្យថាព្រលឹងនេះ?

ឆ្លើ. ស័ព្ទនេះ នាំឲ្យយល់ថាមនុស្សជាភាគមួយ ដែលឃ្លាតចេញអំពីភាគដទៃ ហើយជាចំណែកនៃភពទាំងមូលផង ។ គំនិតនេះមិនឈ្មោះថាត្រឹមត្រូវឡើយ ព្រោះបើក្នុងវិទ្យាសាស្ត្រ ក៏ពុំមានគ្រឿងអាងដែរ ។

ប្រ. បើដូច្នោះ គ្មានពាក្យថា "ខ្ញុំ" ដោយឡែក ឬ យើងនឹងហៅរបស់នេះនោះថា "ជារបស់ខ្ញុំ" ដូច្នេះ ពុំបានទេឬ?

វិ. ពិតមែនហើយ, មានតែជាគុម្ព្រាងទេ យើងនិងសត្វទាំងពួងនិងវត្ថុទាំងអស់ គ្រាន់តែជាចំណែកប៉ុណ្ណោះ ។

ប្រ. បើត្រង់ដែលថា មនុស្សមាន "ព្រលឹង" នៅដោយឡែកពីប្រាណនោះ ត្រូវបដិសេធទៅហើយ ចុះអ្វីដែលនាំឲ្យមនុស្សនីមួយ ៗ ដឹងថាខ្លួនមានអត្តភាពតាំងនៅឋិតថេរនោះ ?

វិ. គឺតណ្ហា ឬ សេចក្ដីប្រាថ្នា ចំពោះការរស់នៅជាមនុស្សក្នុងលោកនេះ ។ សត្វណាដែលត្រូវបានទទួលផលបុណ្យ ឬ ផលបាប បើនៅមានសេចក្ដីប្រាថ្នានេះ នឹងមានជាតិជាថ្មីទៀតតាមយថាកម្មរបស់ខ្លួន ។

ប្រ. ចុះអ្វីដែលនាំឲ្យមានបដិសន្ធិ?

វិ. គឺវិញ្ញាណក្ខន្ធ ឬ ដួងវិញ្ញាណ ដែលកើតឡើងអំពីចិត្តគំនិតជាក្រោយបង្អស់ របស់បុគ្គលដែលជិតដល់នូវមរណកាល ។

ប្រ. ខន្ធមានប៉ុន្មានយ៉ាង?

វិ. មាន ៥ យ៉ាង ។

ប្រ. ចូររាប់មកមើល?

វិ. រូប, វេទនា, សញ្ញា, សង្ខារ និង វិញ្ញាណ ។

ប្រ. ចូរអធិប្បាយពីខន្ធនីមួយៗ មកមើល?

វិ. រូបជាគ្រោងកាយខាងក្រៅ, វេទនាជាការសោយ ឬទទួលនូវអារម្មណ៍, សញ្ញាជាធម្មជាតិដែលសំគាល់នូវអារម្មណ៍, សង្ខារជាសភាវៈដែលតុបតែងបង្កើតជានេះជានោះ, វិញ្ញាណជាធម្មជាតដឹងនូវអារម្មណ៍ ឬមនោ ។ កងកាយរបស់យើង ត្រូវប្រកបព្រមដោយខន្ធទាំងនេះ ចំពោះខ្លួនយើង ដែលប្រព្រឹត្តទៅក្នុងការរស់នៅ ត្រូវពឹងប្រាស្រ័យនឹងរបស់ដែលនៅជុំវិញយើង ដោយសារបញ្ចក្ខន្ធនេះ ។

ឬ. ហេតុម្តេច បានជាមនុស្សយើងមានរូបខុសគ្នា ហើយមានខន្ធប្រាំដូចគ្នាទេ?

វិ. ដោយកម្មនៃបុគ្គលនីមួយៗ ដែលបានបំពេញអំពីអតីតជាតិ ។

ឬ. ធម្មជាតិអ្វី ដែលនាំឲ្យកម្មមានកម្លាំង មានអានុភាព អាចនាំសត្វឲ្យមានជាតិកំណើតជាថ្មី?

វិ. គឺសេចក្តីប្រាថ្នាឲ្យជីវិតតាំងនៅ ។

ឬ. ដែលថា សត្វស្លាប់កើតវិញនោះ តើអាងដល់ធម៌ណា?

វិ. អាងដល់កុសលនិងអកុសលមួយ ដែលជាគ្រឿងទ្រទ្រង់ នឹងបដិច្ចសមុប្បាទធម៌ ដែលមានអវិជ្ជាជាបច្ច័យឲ្យកើតឡើង ។ ពួកពុទ្ធ-មាមកជនមិនជឿថា ជីវិតរបស់មនុស្ស ទុកជារស់នៅប្រមាណ ៥០០ ឆ្នាំ ឬក៏លើសពីនេះនោះ ដើម្បីនឹងទទួលរង្វាន់ ឬទណ្ឌកម្មផ្ទាល់ខ្លួនដូច្នេះទេ គឺបុគ្គលនីមួយៗ ដែលអន្ទោលទៅមកក្នុងសង្សារវដ្ត ដោយយឺតយូរ ឬ

ឆាប់រហ័សនោះ មកពីកម្លាំងផលបុណ្យបាប ដែលខ្លួនបានប្រព្រឹត្តក្នុងភពនោះ ។ ។

ប្រ. បញ្ចក្ខន្ធ ឬរូបកាយមនុស្សថ្មីនេះ ជារូបដដែលពីក្នុងជាតិមុន ដោយតណ្ហានាំមកបង្កើត ឬ ដូចម្តេច?

វិ. មិនមែនជារូបដដែលទេ ទាំងជារូបដទៃក៏មិនមែនដែរ ។ នៅក្នុងជាតិនេះ ខន្ធទាំង ៥ ក៏សឹងប្រែប្រួលជាដរាប ឧបមាដូចជា មនុស្សម្នាក់ឈ្មោះ ក អាយុ ៤០ ឆ្នាំ ជាអ្នកដែលនៅមានរូបរាងកាយដូចមាណពឈ្មោះ ក កាលនៅក្មេងអាយុ ១៨ ឆ្នាំដោយពិត តែដោយសេចក្តីចាស់គ្រាំគ្រាប្រែប្រួលគ្មានឈប់ឈរនៃរូបកាយ ដោយការផ្លាស់ប្តូរចរិតចិត្តគំ-និតនិងកិរិយាប្រព្រឹត្តជាលំដាប់មក ក៏ត្រឡប់ទៅជាបុគ្គលដទៃ ពីកាលមុនស្រឡះ ។ កាលបើសេចក្តីចាស់ដរាបមកដល់ហើយ ឈ្មោះ ក ក៏ត្រូវទទួលផលកម្ម បុណ្យទោសទុក្ខលំបាក ដែលកើតមកអំពីចិត្តគំនិត និងអំពើកម្មអាក្រក់ ដែលខ្លួនបានប្រព្រឹត្តជាលំដាប់មកក្នុងជីវិតរបស់ខ្លួន ។ ហេតុនេះ បុគ្គលដែលកើតថ្មីទៀតនោះ គឺជាបុគ្គលដដែលពីមុន គ្រាន់តែផ្លាស់ទ្រង់ទ្រាយរាងកាយនិងខន្ធ ជាថ្មីប៉ុណ្ណោះ ហើយជាអ្នកទទួលកម្រៃផលដែលកើតពីចិត្តគំនិតនិងកម្ម ពីជាតិមុននោះឯង ។

ប្រ. មនុស្សចាស់-ជរា អាចនឹករឭឃើញហេតុគេ ដែលខ្លួនបានជួបប្រទះកាលនៅពីក្មេងនោះ ពោះបីសរីរៈរាងកាយនិងស្មារតី ប្រែ

ប្រួលទៅកើតដោយ សឹងអាចចាំបានទាំងអស់ តែហេតុម្តេច ក៏ក្នុងជាតិនេះ ហេតុពុំដឹងនូវជាតិកំណើតរបស់ខ្លួនពីមុនមកផង?

វិ. ព្រោះសត្វគេ កើតអាស្រ័យនឹងខន្ធដែរ, កាលបើបញ្ចក្ខន្ធនេះបានប្រែប្រួលបដិសន្ធិក្នុងបច្ចុប្បន្នជាតិនេះទៅហើយ សត្វតែថ្មីក៏ត្រូវកើតមានវិញដែរ ។ តែទោះយ៉ាងណា ក៏គង់នៅមានអ្នកនឹករឭកឃើញហេតុការណ៍ពីជាតិមុនមកដែរ ដូចយ៉ាងព្រះសិទ្ធត្ថបរមពោធិសត្វ កាលទ្រង់បានត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធហើយ, ព្រះអង្គក៏ជ្រាបច្បាស់គ្មានសល់ចន្លោះអ្វីពីជាតិមុនៗមក, ប្រសិនបើហេតុការណ៍ទាំងនោះ គ្មានសល់សត្វមកខ្លួនទេ, ព្រះអង្គក៏ពុំអាចជ្រាបច្បាស់បានឡើយ ។ បុគ្គលណាដែលបានសម្រេចចតុត្ថជ្ឈាន នឹងអាចនឹកឃើញហេតុការណ៍ក្នុងបុព្វជាតិរបស់ខ្លួនបានដោយពិត ។

បុ. ការផ្លាស់ប្តូរនៃខន្ធនេះ នឹងមានទីបំផុតត្រឹមណា?

វិ. ត្រឹមព្រះនិព្វាន ។

បុ. ព្រះពុទ្ធសាសនា មានប្រដៅថា ត្រូវតែឲ្យយើងធ្វើអំពើល្អដើម្បីបានសម្រេចព្រះនិព្វាន ឬដូចម្តេច?

វិ ទេ, ប្រសិនបើសេចក្តីប្រាថ្នានេះ ចំពោះទៅរកការចង់បានមាសប្រាក់ ភពសម្បត្តិ ឬ សេចក្តីត្រេកត្រអាលក្នុងកាមគុណនោះ គឺជាកិច្ចបំពេញតណ្ហាទេ ។ ព្រះនិព្វាន ពុំមែនសម្រេចដោយសេចក្តីប្រាថ្នាយ៉ាងនេះទេ

ហើយអ្នកដែលធ្វើដូច្នេះ នឹងជួបប្រទះតែសេចក្តីតាមទស្សនៈរបស់ខ្លួន

ឬ. ចូរអ្នកអធិប្បាយពន្យល់រឿងនេះ ឲ្យពិស្តារបន្តិចមកមើល?

វិ. ពាក្យថា ព្រះនិព្វាន ជាគូតាមនឹងការបូលេះបង់ជីវិតរបស់ពួកមនុស្សណាៗ មនុស្សល្ងង់ខ្លៅ ច្រើនច្រឡំថាបែកសេចក្តីសុខក្នុងព្រះនិព្វាន គ្មានគិតថា ព្រះនិព្វាននោះ យ៉ាងដូចម្តេច ។ ការគ្មានចិត្តអស្ចារ្យសេចព្រះនិព្វាន, ការប្រព្រឹត្តធ្វើអំពើល្អ ដើម្បីជាប្រយោជន៍នៃខ្លួន ឬ បួសជាតាបស ដោយមានបំណងចង់បានសេចក្តីសប្បាយក្នុងឋានសួគ៌ គុំមែនជាផ្លូវនៃព្រះនិព្វាន ដែលព្រះបរមគ្រូទ្រង់ត្រាស់សំដែងទេ ។ ការសេពគប់នៃព្រះអរិយៈទាំងឡាយ ប្រពៃពន់ពេកណាស់, ព្រោះគ្មានបំណងចង់បានសេចក្តីសុខក្នុងភពទាំងបីនេះទេ ។ បុគ្គល អាចគ្មានសំណល់ចូលទៅព្រះនិព្វានក្នុងលោកនេះដោយពិត ។

ឬ. ចូរអ្នករៀបរាប់អំពីចំណងដែលគេតែងសត្វ មិនឲ្យបានសេចក្តីចម្រើន ១០ ប្រការ ដែលលោកហៅថា «សំយោជនៈ» នោះមកមើល?

វិ. គឺសេចក្តីប្រកាន់ខ្ជាប់ថា រូបកាយជារបស់ខ្លួន (សក្កាយទិដ្ឋិ), សេចក្តីសង្ស័យ (វិចិកិច្ឆា), ការប្រកាន់ជឿសីលព្រតមន្តអាគមនិងវត្តប្រតិបត្តិខុស (សីលព្វតបរាមាស), តម្រេកក្នុងកាមគុណ (កាម), សេចក្តីទាំងក្តៅក្តុកអន់ចិត្ត (បដិឃ), ការពេញចិត្តនឹងរូបភព (រូបរាគៈ), ការពេញចិត្តនឹងអរូបភព (អរូបរាគៈ), អំនួតវីងគ្រិះ (មានៈ), ចិត្តរវើ-

រវាយកយមាយ, ( ឧទ្ធច្ចៈ ) សេចក្ដីល្ងង់ខ្លៅ ( អវិជ្ជា ) ។

ប្រ. ដើម្បីឲ្យបានដល់នូវព្រះអរហត្ត តើត្រូវកំចាត់ចោលចំណង នេះប៉ុន្មាន?

វិ. ត្រូវកំចាត់ចោលទាំងអស់ ។

ប្រ. ធម៌ជាគ្រឿងកាំងខ្ទាំងខ្ទប់ទាំងប្រាំប្រការ ដែលលោកហៅ ថា "នីវរណៈ" គឺអ្វីខ្លះ?

វិ. គឺកាមច្ឆន្ទៈ, ព្យាបាទ, ថីនមិទ្ធៈ, ឧទ្ធច្ចៈ, កុក្កុច្ចៈ និង វិចិកិច្ឆា ។

ប្រ. ហេតុដូចម្ដេច កំពាក្យប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ខាងផ្លូវចិត្ត ចេតសិក សុទ្ធតែប្រកបដោយចំណែកល្អិតល្អន់ខ្លាំងម៉្លេះ? ហេតុនេះនឹង នាំឲ្យអាទិកបុគ្គលរសេមរសោមគំនិត ដោយពិតឬទេ?

វិ. ដើម្បីជាជំនួយដល់យើង ឲ្យដឹងស្គាល់នូវអត្តភាពរបស់ខ្លួន ឲ្យ គំនិតយើងមានទម្លាប់ស្គាល់ហេតុនីមួយៗឲ្យបានគ្រប់ប្រការ ។ ដោយការ គិតពីនេះ យើងនឹងអាចដឹងស្គាល់នូវធម៌ដោយជាក់ស្ដែង ។ អាចារ្យទាំង ពួងក្នុងព្រះពុទ្ធសាសនា តែងណែនាំឲ្យចម្រើនផ្លូវបញ្ញាតាមគន្លងនេះឯង ។

ប្រ. បណ្ដាសាវ័កទាំងអស់ របស់ព្រះបរមគ្រូ មានប៉ុន្មានអង្គ ដែល មានកិត្តិស័ព្ទល្បីល្បាញក្នុងផ្លូវវិជ្ជាផ្សេងៗ ។

វិ. មាន ៨០ ព្រះអង្គ គេសន្មតហៅថា "ព្រះអសីតិមហាសាវ័ក" ។

ប្រ. ព្រះពុទ្ធជាម្ចាស់ ព្រះអង្គត្រាស់ដឹងអ្វីខ្លះ?

វិ ព្រះអង្គជ្រាបច្បាស់ នូវត្រៃលោក, វិជ្ជានិងអវិជ្ជា. ហេតុជាកុសលនិងអកុសល, ចិត្តគំនិតរបស់អ្នកដទៃ, ការសោយអារម្មណ៍ និងផ្លូវកំចាត់បង់នូវតណ្ហា, ព្រះអង្គជ្រាបច្បាស់ នូវចុតិនិងបដិសន្ធិរបស់សត្វនិងហេតុដទៃទៀតជាអនេក ៗ

ប្ុ. ធម៌ជាប្រធាននៃពាក្យប្រៀនប្រដៅ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ គេហៅថាដូចម្តេច?

វិ. ហៅថា បដិច្ចសមុប្បាទធម៌ ។

ប្ុ. ចុះធម៌នេះ ងាយយល់ងាយចូលចិត្តឬទេ?

វិ. ធម៌នេះ ជ្រៅ ពិបាកយល់ណាស់ គឺមានអត្ថដ៏ជ្រាលជ្រៅធំទូលាយក្រៃពេក ហួសវិស័យនៃអ្នកដែលពុំបានបំពេញផ្លូវបញ្ញាយល់ចាក់ធ្លុះបាន ។

ប្ុ. ព្រះពុទ្ធឃោសាចារ្យ ដែលជាអដ្ឋកថាចារ្យយ៉ាងឯក នោះលោកយល់ដូចម្តេច ក្នុងធម៌នេះ?

វិ. លោកពោលត្អូញត្អែរថា ពុំអាចយល់សព្វគ្រប់ក្នុងធម៌ដ៏ជ្រាលជ្រៅនេះដែរ ហាក់ដូចជាមនុស្សសាត់អណ្តែតក្នុងទឹកមហាសមុទ្ររកកោះត្រើយពុំឃើញ ។

ប្ុ. ហេតុដូចម្តេច ក៏ក្នុងមហាបរិនិព្វានសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា " ធម៌វិន័យរបស់តថាគត ។ គ្មានលាក់ទុកដូចសាសនា

ដទៃ ដែលមានវត្ថុកាប់ទុកក្នុងដៃនោះទេ, បើព្រះធម៌ទាំងមូលរបស់ព្រះអង្គសឹងជាវិស័យនៃបុគ្គលទាំងពួង ហេតុម្តេចក៏ព្រះពុទ្ធឃោសាចារ្យ ដែលជាអ្នកប្រាជ្ញយ៉ាងធ្ងន់ នៅពោលថា ពិបាកយល់ជាក់បានដូច្នេះ?

វិ. ព្រះពុទ្ធជាម្ចាស់ សំដៅសេចក្តីថា ព្រះអង្គបានត្រាស់សំដែងប្រាប់សព្វគ្រប់ទាំងអស់ គ្មានសល់លាក់ទុកកន្លែងណាទេ ។ ឯអត្ថរសរបស់ព្រះធម៌នេះ អ្នកមានប្រាជ្ញាច្រើនកងវៃ អាចយល់ជាក់ច្បាស់បានដោយងាយ ពុំកំបាំងឡើយ ។ ចំណែកខាងអ្នកដែលនៅមានសេចក្តីល្ងង់ ទើបកំបាំងមិនយល់មែន ។

ព្រ. ចុះដំណើរដែលព្រះបរមគ្រូទ្រង់ប្រៀនប្រដៅ ដល់វេនេយ្យសត្វនោះ ទ្រង់សំដែងបញ្ជាក់សេចក្តីនេះឬទេ?

វិ. ព្រះអង្គទាញយកអតីតនិទាន និងយកសេចក្តីងាយៗមកពន្យល់ដល់សត្វដែលនៅងងឹតល្ងង់, សត្វណាដែលដឹងគ្រាន់បើ ព្រះអង្គប្រៀនប្រដៅសុត្តន្តបិដក, ព្រះអង្គបញ្ញត្តវិន័យបិដក ដើម្បីគ្រប់គ្រងពួកភិក្ខុ និងឧបាសក, ឯចំណែកអភិធម្មបិដក ដែលជាផ្លូវបរមត្ថ ព្រះអង្គប្រោសសំដែងតែដល់បុគ្គលអ្នកមានប្រាជ្ញាចាស់ក្លាហើយ ។

(នៅមានត)

# សម្តែងអំពី

# សុខ និង ទុក្ខ

ដែលកើតអំពី

# កម្ម

(គ)

ព្រះសាសនមុនី ហ៊ិម-ទួរ ក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

## អនាថបិណ្ឌិកសេដ្ឋី កសាងវត្តជេតពន

ក្នុងផ្នែករឿងនេះ មានសេចក្តីពិស្តារវែង ប៉ុន្តែក្នុងទីនេះ សូមពណ៌នាដោយសង្ខេបថា អនាថបិណ្ឌិកសេដ្ឋី ទៅកាន់ក្រុងរាជគ្រឹះ ដោយមានករណីយកិច្ចអ្វីមួយ ក៏បានចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ ៗ ក្នុងខណៈនោះ ព្រះអង្គទ្រង់សំដែងអនុបុព្វីកថា គឺ ទានកថា ( និយាយពីការឲ្យទាន ) ១ សីលកថា ( និយាយពីការរក្សាសីល ) ១ សគ្គកថា ( និយាយពីឋានសួគ៌ ) ១ កាមាទីនវកថា ( និយាយពីទោសនៃកាម ) ១ នេក្ខម្មានិសំសកថា ( និយាយពីអានិសង្សនៃការចេញចាកកាម ឬ ការចេញកសាងផ្នួស ) ១ ចំពោះអនាថបិណ្ឌិកសេដ្ឋី ៗ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា កាលណាអនាថបិណ្ឌិកសេដ្ឋី មានចិត្តទន់ស្រួល មាន

ចិត្តប្រាសចាកនីវរណធម៌ មានចិត្តរីករាយជ្រះថ្លា, គឺធម្មទេសនាណា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង ព្រះអង្គក៏ទ្រង់ប្រកាសនូវធម្មទេសនានោះ ក្នុងសច្ចៈទាំង ៤ គឺ ទុក្ខសច្ច សមុទយសច្ច និរោធសច្ច និង មគ្គសច្ច ក្នុងកាលណោះ ៗ ប្រៀបដូចសំពត់ដ៏ស្អាត ដែលមិនទាន់មានពណ៌ទៅ តែងទទួលយកនូវទឹកជ្រលក់ដោយប្រពៃ យ៉ាងណាមិញ, ក៏ដូចជាធម្មចក្ខុ គឺសោតាបត្តិផល មានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ ក៏បានកើតឡើងដល់អនាថបិណ្ឌិកសេដ្ឋី លើអាសនៈនោះ ដូច្នេះថា ធម្មជាតណាមួយ មានសភាពកើតឡើងហើយជាធម្មតា ធម្មជាតទាំងអស់នោះមានសភាពរលត់ទៅវិញជាធម្មតា ។

គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានឃើញធម៌ហើយ មានចិត្តចុះកាន់ធម៌ស៊ប់ហើយ ឆ្លងចាកសេចក្តីសង្ស័យហើយ ដល់នូវសេចក្តីក្លៀវក្លា លែងជឿនូវពាក្យនៃជនដទៃក្នុងសាសនារបស់ព្រះបរមសាស្តា ហើយក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា អភិក្កន្តំ ភន្តេ បពិត្រព្រះអង្គដ៏ចំរើន, ពីរោះពេកណាស់ ! ធម៌ដែលព្រះអង្គទ្រង់សំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ភ្លឺច្បាស់ណាស់ គួរនាដូចជាមនុស្សបើកវត្ថុដែលគេផ្កាប់ឲ្យផ្ងារឡើង ឬដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំងទុក ពុំនោះសោត ដូចគេប្រាប់ផ្លូវដល់មនុស្សវង្វេង

ឬដូចជាគេកាន់ចង្កៀងទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក នឹងមើលឃើញនូវរូបទាំងឡាយបាន ៗ លំដាប់នោះ អនាថបិណ្ឌិកសេដ្ឋី បានប្រកាសប្រគល់ខ្លួនជាឧបាសក ដល់នូវត្រៃសរណគមន៍ថា ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់ហើយនូវព្រះត្រៃសរណគមន៍ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

មួយយ៉ាងទៀត បពិត្រព្រះអង្គដ៏ចំរើន, សូមព្រះមានព្រះភាគមួយអន្លើដោយភិក្ខុសង្ឃ ទទួលនិមន្តរបស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋីបានដឹងច្បាស់ថា ព្រះអង្គទ្រង់ទទួលនិមន្តហើយ ក៏ថ្វាយបង្គំលាព្រះមានព្រះភាគក្រោកចាកអាសនៈ ធ្វើប្រទក្សិណ រួចថយចេញទៅ ។ កាលរាត្រីនោះកន្លងទៅហើយ អនាថបិណ្ឌិកសេដ្ឋី ក៏ឲ្យជនទាំងឡាយតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម ក្នុងគេហដ្ឋានរបស់រាជគហសេដ្ឋីជាបងថ្លៃ រួចហើយក៏ប្រើគេឲ្យទៅក្រាបបង្គំទូលភត្ត-

កាលចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន, កាលគួរហើយ កត្តកំសម្រេចហើយ ។ នៅក្នុងវេលាបុព្វណ្ហសម័យ ព្រះសម្ពុទ្ធទ្រង់ពុទ្ធដំណើរទៅកាន់លំនៅរបស់កឌគហសេដ្ឋី ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ជាមួយនឹងភិក្ខុសង្ឃ ៖ អនាថបិណ្ឌិកសេដ្ឋី បានអង្គាសថ្វាយខាទនីយភោជនីយាហារដ៏មានរសឆ្ងាញ់ពីសាដោយដៃខ្លួនឯងចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន, លុះដល់ទីបំផុតនៃភត្តកិច្ចហើយ ទើបក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា អធិវាសេតុ មេ ភន្តេ ភគវា សាវត្ថិយំ វស្សាវាសំ សទ្ធិំ ភិក្ខុសង្ឃេន បពិត្រព្រះអង្គដ៏ចំរើន, សូមព្រះមានព្រះភាគជាមួយនឹងភិក្ខុសង្ឃ ទទួលនិមន្តគង់ចាំវស្សាក្នុងក្រុងសាវត្ថីរបស់យើងខ្ញុំព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតី ព្រះតថាគតទាំងឡាយ រមែងត្រេកអរក្នុងលំនៅដ៏ស្ងប់ស្ងាត់តែម្យ៉ាង ។ អនាថបិណ្ឌិកសេដ្ឋី ក៏បានក្រាបបង្គំទូលតបថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានយល់ច្បាស់ហើយ ។ ទើបព្រះមានព្រះភាគទ្រង់ពន្យល់អនាថបិណ្ឌិកសេដ្ឋីឲ្យឃើញព្រម ឲ្យកាន់យកព្រម ឲ្យទស្សាហ៍ព្រម ឲ្យរីករាយព្រម ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ទ្រង់ពុទ្ធដំណើរចេញទៅ ។

សម័យនោះឯង អនាថបិណ្ឌិកសេដ្ឋី ជាអ្នកមានមិត្តច្រើន មានសម្លាញ់ច្រើន មានវាចាគួរឲ្យអ្នកផងកាន់យក លុះបានចាត់ចែងកិច្ចការ

របស់ខ្លួនដែលគួរធ្វើនោះ ក្នុងក្រុងរាជគ្រឹះរួចហើយ ក៏ត្រឡប់មកឯក្រុងសាវត្ថីវិញ ៗ កាលដល់ពាក់កណ្ដាលផ្លូវ អនាថបិណ្ឌិកសេដ្ឋី បានប្រកាសប្រាប់មនុស្សទាំងឡាយថា ម្នាលអ្នកទាំងឡាយ ចូរអ្នកកល់គ្នាធ្វើអារាម សាងវិហារ ផ្ដើមធ្វើទានទៅ! ដ្បិតឥឡូវនេះ ព្រះពុទ្ធបានត្រាស់ឡើងក្នុងលោកហើយ, ឯព្រះពុទ្ធអង្គនោះសោត ខ្ញុំក៏បាននិមន្តហើយ ព្រះអង្គនឹងទ្រង់ពុទ្ធដំណើរមកតាមផ្លូវនេះឯង ៗ គ្រានោះមនុស្សទាំងឡាយ ដែលអនាថបិណ្ឌិកសេដ្ឋីប្រកាសប្រាប់នោះ ក៏បាននាំគ្នាធ្វើអារាម សាងវិហារ និងផ្ដើមធ្វើទាន ៖ វេលាដែលអនាថបិណ្ឌិកសេដ្ឋីទៅដល់ក្រុងសាវត្ថីហើយ ក៏គយគន់រកមើលទីកន្លែងគ្រប់អន្លើក្នុងក្រុងសាវត្ថី ដោយគិតថា ព្រះមានព្រះភាគ សមនឹងគង់នៅក្នុងទីណាហ្ន៎! ទីណាដែលមិនជិតពេក មិនឆ្ងាយពេកអំពីស្រុក ជាទីល្មមទៅល្មមមកបានដោយស្រួល ល្មមពួកមនុស្សដែលត្រូវការដោយប្រយោជន៍ងាយនឹងទៅមក ហើយជាទីមិនច្រឡូកច្រឡំក្នុងវេលាថ្ងៃ មានសំឡេងតិច ឥតមានសំឡេងគឹកកង ជាទីមានខ្យល់បក់ស្រួល គួរដល់ការពួនសម្ងំនៅនៃមនុស្សទាំងឡាយ ៗ អនាថបិណ្ឌិកសេដ្ឋី បានឃើញឧទ្យានរបស់ព្រះរាជកុមារព្រះនាម ជេត ជាទីមិនឆ្ងាយពេក មិនជិតពេកអំពីស្រុក ល្មមពួកមនុស្សដែលត្រូវការដោយប្រយោជន៍អាចទៅមកបានដោយងាយ, លុះបានឃើញដូច្នេះហើយ ក៏ចូលទៅរកព្រះរាជកុមារ

ជេត ថា បពិត្រព្រះអង្គម្ចាស់, សូមព្រះអង្គប្រទានឧទ្យានមកខ្ញុំព្រះអង្គ ដើម្បីនឹងធ្វើអារាម ។ ព្រះអង្គម្ចាស់ជេត ឆ្លើយថា ម្នាលគហបតី ឧទ្យានខ្ញុំឲ្យទៅអ្នកទទេពុំបានទេ លុះតែអ្នកឲ្យថ្លៃ គឺក្រាលដោយកោដិនៃកហាបណៈពេញទាំងអស់ ទើបឲ្យបាន ។ អនាថបិណ្ឌិកសេដ្ឋី ឆ្លើយថា បពិត្រព្រះអង្គម្ចាស់ ឧទ្យាន ខ្ញុំព្រះអង្គប្រាកដជានឹងយកហើយ, ក៏ចាត់ចែងឲ្យគេផ្ទុកប្រាក់ដឹកដោយរទេះទាំងឡាយ មកចាក់ក្រាលតម្រៀបដោយកហាបណៈក្នុងឧទ្យានរបស់ព្រះអង្គម្ចាស់ ជេត ។ ប្រាក់ដែលដឹកជញ្ជូនយកមកតែម្តងប៉ុណ្ណោះមិនគ្រប់គ្រាន់ នៅសល់ទីឱកាសបន្តិច ត្រង់ជុំវិញក្លោងទ្វារ ទើបអនាថបិណ្ឌិកសេដ្ឋីបង្គាប់ឲ្យគេទៅនាំយកប្រាក់មកថែមទៀត ដើម្បីនឹងក្រាលត្រង់ឱកាសនោះ ។ គ្រានោះ ព្រះអង្គម្ចាស់ជេត មានសេចក្តីត្រិះរិះដូច្នេះថា គហបតីនេះចំណាយប្រាក់ច្រើនដល់ម៉្លោះ ចំពោះកិច្ចណា កិច្ចនោះ មិនមែនជារបស់ថោកទាបទេ, ហើយក៏និយាយនឹងអនាថបិណ្ឌិកសេដ្ឋីថា ណ្ហើយគហបតី, អ្នកកុំក្រាលត្រង់ទីឱកាសនោះឡើយ អ្នកចូរឲ្យទីឱកាសនោះដល់ខ្ញុំ ទីដីនោះ ខ្ញុំទុកជាទានរបស់ខ្ញុំ រួមជាមួយនឹងអ្នកផង ។

ន័យមួយទៀត មានសេចក្តីពណ៌នាក្នុងគម្ពីរបបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយថា ទីដីនោះ គឺព្រះអង្គម្ចាស់ជេត បានដាំដើមឈើធំ-តូច ថែទាំធ្វើជាព្រៃសួនឧទ្យាន មានលំអគួរជាទីរីករាយសប្បាយ សំរាប់

ទ្រង់យាងទៅក្រសាលកំសាន្តមួយដងមួយកាល ហើយទ្រង់ត្រូវជាម្ចាស់ឧទ្យាននោះផង ព្រោះហេតុនោះ បានជាគេហៅ ឧទ្យាននោះថា ជេតវន ។ អនាថបិណ្ឌិកសេដ្ឋីចំណាយអស់ប្រាក់ ១៨ កោដិទិញដីឧទ្យាននោះអំពីព្រះអង្គម្ចាស់ជេត លុះបានដីឧទ្យាននោះហើយ ក៏ចំណាយប្រាក់ ១៨ កោដិទៀត ចាត់ការរៀបចំសាងសេនាសនៈផ្សេង ៗ ជាច្រើន មានគន្ធកុដិធំមួយ ប្រកបដោយលំអរុងរឿង ជាទីសម្រាប់ព្រះសម្មាសម្ពុទ្ធគង់ ជាដើម, លុះចាត់ចែងធ្វើអារាម ព្រមទាំងសេនាសនៈរួចសព្វគ្រប់ហើយ ក៏ចំណាយប្រាក់ ១៨ កោដិទៀត ធ្វើបុណ្យសម្ពោធឆ្លង ។ រួមការចំណាយទាំង ៣ លើក គឺចំណាយទិញដី, ចំណាយទិញគ្រឿងឧបសម្ភារៈធ្វើសេនាសនៈ, ចំណាយទិញរណ្តាប់បុណ្យ មានចីវរនិងខាទនីយភោជនីយាហារជាដើម ត្រូវជា ៥៤ កោដិប្រាក់ រួចហើយក៏វេរទីអារាមព្រមទាំងសេនាសនៈទាំងមូល ថ្វាយដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រោះហេតុនោះ បានជាព្រះគន្ថរចនាចារ្យទាំងឡាយ ចារឹកឈ្មោះនៃជនទាំងនោះទុកក្នុងខាងដើមនៃសូត្រជាច្រើន មានមង្គលសូត្រជាដើមថា ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ប្រែថា សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិក-សេដ្ឋី ជិតក្រុងសាវត្ថី ។ ត្រង់ពាក្យថា ជេតវនេ នេះ គេចារឹក

ឈ្មោះអ្នកម្ចាស់ដើម គឺព្រះអង្គម្ចាស់ជេត ជាម្ចាស់ដីឧទ្យាន, ត្រង់ពាក្យថា អនាថបិណ្ឌិកស្ស អារាមោ នេះ គេហៅឈ្មោះអ្នកម្ចាស់ខាងក្រោយ គឺអនាថបិណ្ឌិកសេដ្ឋី ដែលបានទិញហើយហៅការកសាងអារាម ៗ បើមានពាក្យចោទសួរថា ការហៅឈ្មោះនៃជនទាំងនោះទុកដូច្នេះ ទើងមានផលប្រយោជន៍ដូចម្ដេច? ឆ្លើយថា មានប្រយោជន៍យ៉ាងសំខាន់ គឺហៅទុកជាភស្តុតាងឲ្យបច្ឆាជនទាំងឡាយ អ្នកប្រាថ្នាបុណ្យ បានឃើញហើយនឹងយកជាតម្រាប់តាមតទៅក្នុងអនាគត ៗ

## នាងវិសាខា កសាងវត្តបុព្វារាម

ថ្ងៃមួយ ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រមើលមើលសត្វលោក ក្នុងបច្ចូសសម័យ បានឃើញនូវសម្បត្តិ គឺឧបនិស្ស័យនៃសេដ្ឋីបុត្រម្នាក់ឈ្មោះ ភទ្ទិយៈ ដែលច្យុតចាកទេវលោកមកកើតក្នុងត្រកូលនៃសេដ្ឋីក្នុងភទ្ទិយនគរ, ព្រះអង្គទ្រង់ធ្វើភត្តកិច្ចក្នុងផ្ទះនៃអនាថបិណ្ឌិកសេដ្ឋីរួចហើយ ទ្រង់បែរព្រះភក្ត្រយាងទៅតាមទ្វារទិសខាងជើង ដើម្បីទៅសំដែងធម៌ប្រោសសេដ្ឋីបុត្រនោះឯង ៗ តាមប្រក្រតី ព្រះបរមសាស្ដា បើទ្រង់ទទួលភិក្ខាហារក្នុងផ្ទះនៃនាងវិសាខារួចហើយ ទ្រង់យាងចេញតាមទ្វារខាងត្បូងទៅគង់ក្នុងវត្តជេតពន, បើទ្រង់ទទួលនូវភិក្ខាហារក្នុងផ្ទះនៃអនាថបិណ្ឌិកសេដ្ឋីរួចហើយ ទ្រង់យាងចេញតាមទ្វារខាងកើតទៅគង់ក្នុងវត្ត

បុញ្ញកម្ម ៗ មនុស្សទាំងឡាយ កាលបើបានឃើញព្រះតថាគត ទ្រង់យាងសំដៅទៅកាន់ទ្វារទិសខាងជើង ហើយរមែងដឹងបានថា ព្រះអង្គទ្រង់ពុទ្ធដំណើរចេញទៅកាន់ចារិកជនបទខាងក្រៅ ៗ ក្នុងថ្ងៃនោះ នាងវិសាខា គ្រាន់តែបានឮដំណឹងថា ព្រះបរមសាស្ដា ទ្រង់យាងចេញទៅតាមទ្វារខាងជើងហើយ ក៏ស្ទុះម្នីម្នាតាមទៅក្រាបថ្វាយបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស, ខ្ញុំព្រះករុណាម្ចាស់ បានបរិច្ចាគទ្រព្យចំនួនប្រើនឲ្យគេសាងវិហារមួយថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ព្រះមេត្តាយាងត្រឡប់វិញ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលវិសាខា, ដំណើរដែលតថាគតទៅនេះ ជាដំណើរមិនត្រឡប់វិញទេ ៗ នាងវិសាខា ជាស្ត្រីមានប្រាជ្ញាឈ្លាសវៃ គិតឃើញថា ព្រះតថាគតទ្រង់ឃើញជនណាមួយដែលមានឧបនិស្ស័យគួរបានសម្រេចមគ្គផលដោយពិតហើយ បានជាព្រះអង្គមិនទ្រង់ត្រឡប់វិញ, ទើបនាងក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោសបើដូច្នោះសូមព្រះអង្គទ្រង់ចាត់ភិក្ខុមួយរូបដែលជាអ្នកចេះដឹងយល់ការគួរធ្វើនិងការពុំគួរធ្វើ ឲ្យដល់ខ្ញុំម្ចាស់ ហើយសឹមព្រះអង្គយាងទៅចុះ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលវិសាខា, ការនេះសម្រេចនៅលើនាងចុះ បើនាងពេញចិត្តនឹងភិក្ខុណា ចូរទទួលបាត្ររបស់ភិក្ខុនោះទៅ ៗ នាងវិសាខាធ្លាប់ស្រឡាញ់រាប់អានព្រះអានន្ទត្ថេរ ជាយូរមកហើយក៏ពិតមែន ប៉ុន្តែ នាងគិតថា ព្រះមហាមោគ្គល្លានត្ថេរ មានឥទ្ធានុភាពច្រើន បើបានលោក

មកជួយមើលការកសាងរបស់អាត្មាអញ ការនោះមុខជានឹងបានសម្រេចឆាប់ពុំខាន, លុះគិតឃើញដូច្នោះហើយ ក៏ទទួលយកបាត្រនិមន្តព្រះមហាមោគ្គល្លានទៅ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន, អ្នកចូរនាំយកភិក្ខុ ៥០០ រូបជាបរិវាររបស់អ្នក ត្រឡប់ទៅវិញចុះ ។ ព្រះមហាមោគ្គល្លាន ក៏បានថ្វាយបង្គំលាព្រះមានព្រះភាគ ហើយនិមន្តទៅកាន់ទីកន្លែងដែលនាងវិសាខាកសាងវិហារនោះឯង ។ ដោយអានុភាពនៃព្រះមហាមោគ្គល្លានត្រូវជាអ្នកចាត់ការ មនុស្សទាំងឡាយ ទៅនាំយកឈើនិងថ្មធំៗជាច្រើន ដោយទេះ អំពីព្រៃ ចម្ងាយផ្លូវ ៥០ យោជន៍ខ្លះ ៦០ យោជន៍ខ្លះ បានមកដោយសុខស្រួល ឥតមានលំបាក ឬគ្រោះថ្នាក់បាក់ភ្លៅទេះឡើយ ។ ការកសាងនោះ មិនយូរប៉ុន្មាន ក៏បានធ្វើប្រាសាទមួយមានជាន់ពីរហើយស្រេច, ជាន់ខាងក្រោមមានបន្ទប់ ៥០០, ជាន់ខាងលើ មានបន្ទប់ ៥០០ រួមជាប្រាសាទប្រដាប់ដោយបន្ទប់ ១.០០០ ។ នាងវិសាខា យល់ឃើញថា បើមានតែប្រាសាទមួយពេលតែឯងយ៉ាងនេះ ពុំសូវសមល្អឡើយ, នាងក៏បានបង្គាប់ឲ្យគេធ្វើប្រាសាទជាប្រធាន ៥០០ ប្រាសាទតូច ៥០០ និងសាលាវែង ៥០០ ទៀត បិតនៅព័ទ្ធជុំវិញប្រាសាទធំពីរជាន់នោះឯង, ឯកំពូលប្រាសាទនីមួយៗ នាងបង្គាប់ឲ្យគេធ្វើដោយដុំមាសទាំងអស់ ។

គ្រានោះ ព្រះបរមសាស្តា ដែលទ្រង់យាងទៅកាន់ចារិកជនបទ

អស់ ៩ ខែ ហើយយាងត្រឡប់មកក្រុងសាវត្ថីវិញ ទ្រង់គង់ក្នុងមហាវិហារជេតពន ។ ការកសាងប្រាសាទរបស់នាងវិសាខា បានប្រព្រឹត្តទៅអស់ ៩ ខែដែរ ទើបបានសម្រេច, នាងឮថា ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់យាងមកដល់វត្តជេតពនហើយ នាងក៏ទៅធ្វើបច្ចុគ្គមនាការទទួលព្រះអង្គ ហើយក៏អារាធនានិមន្តព្រះអង្គយាងមកឯវត្តរបស់ខ្លួន ហើយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស, សូមព្រះអង្គនាំភិក្ខុសង្ឃមកគង់ក្នុងវត្តបុព្វារាមនេះ អស់កំណត់កាល ៤ ខែនេះ ខ្ញុំម្ចាស់នឹងធ្វើបុណ្យសម្ពោធឆ្លងប្រាសាទថ្មីដែលទើបនឹងកសាងហើយនេះ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ទទួលដោយតុណ្ហីភាព ។ ចាប់ដើមពីថ្ងៃនោះតទៅ នាងវិសាខា បានចាត់ចែងធ្វើទានថ្វាយចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានក្នុងវត្ត ជានិច្ចរាល់ថ្ងៃ ។ គ្រានោះ មានស្ត្រីម្នាក់ជាសំឡាញ់នឹងនាងវិសាខា បាននាំយកសំពត់មួយមានតម្លៃមួយពាន់កហាបណៈ បំរុងនឹងក្រាលក្នុងប្រាសាទនោះដែរ ប៉ុន្តែបានឃើញប្រាសាទពេញដោយកម្រាលទាំងអស់ស្រេច ក៏មកនិយាយនឹងនាងវិសាខាថា នែសំឡាញ់! ខ្ញុំចង់បកកម្រាលខ្លះក្នុងប្រាសាទរបស់នាងចេញ ហើយយកសំពត់នេះក្រាលជាជំនួសត្រង់កន្លែងនោះវិញ សូមនាងមេត្តាប្រាប់កន្លែងកម្រាលដែលគួរបកយកចេញនោះដល់ខ្ញុំ ។ នាងវិសាខាឆ្លើយថា ល្អហើយសំឡាញ់! នាងចូរដើរគន់មើលក្នុងប្រាសាទទាំងពីរជាន់ និងបន្ទប់ទាំង

១.០០០ ឲ្យសព្វគ្រប់ដោយខ្លួនឯងចុះ បើឃើញកម្រាលត្រង់កន្លែងណាមិនល្អ ចូរនាងបកកម្រាលត្រង់នោះចេញ ហើយយកសំពត់នាងទៅក្រាលជាជំនួសវិញចុះ ។ នាងនោះ បានកាន់សំពត់តម្លៃមួយពាន់កហាបណៈនោះ ដើរពិនិត្យសព្វកន្លែងក្នុងប្រាសាទទាំងពីរជាន់ មិនឃើញកម្រាលណាដែលមានតម្លៃថោកអន់ថយជាងសំពត់ខ្លួនសោះ, នាងគិតថា ឱ! អាត្មាអញ ខានបានចំណែកបុណ្យក្នុងប្រាសាទនេះហើយតើ, លុះគិតឃើញដូច្នោះហើយ ក៏អាក់អន់តូចចិត្ត ទៅឈរយំក្នុងទីមួយតែម្នាក់ឯង ។ គ្រានោះ ព្រះអានន្ទត្ថេរ បានឃើញនាងនោះឈរយំ ក៏សួរថា ព្រោះហេតុអ្វី បានជានាងយំ? ។ នាងនោះក៏បានទូលសេចក្តីនោះសព្វគ្រប់ ។ ព្រះអានន្ទត្ថេរប្រាប់ថា នាងកុំគិតឡើយ! មក, អាត្មានឹងប្រាប់កន្លែងឲ្យនាងក្រាល, នាងចូរក្រាលត្រង់កន្លែងនេះចុះ ព្រោះភិក្ខុទាំងឡាយគ្រប់អង្គដែលលាងជើងរួចហើយ តែងមកឈរជូតជើងនៅកន្លែងក្បែរជណ្តើរឡើងនេះមុនគេ ហើយទើបនិមន្តចូលទៅខាងក្នុង, កន្លែងនេះ សំខាន់ណាស់ ទោះភិក្ខុណាក៏ដោយដែលនិមន្តមក គង់តែជាន់ត្រង់ទីនេះមិនខាន, ចូរនាងក្រាលត្រង់កន្លែងនេះទៅ, នាងនឹងបានបុណ្យច្រើនជាងកន្លែងឯទៀត ព្រោះកន្លែងនេះនាងវិសាខាពុំបានជាចាប់ភ្លុក នឹកពុំឃើញឡើយ ។ នាងនោះ បានយកសំពត់របស់ខ្លួនទៅក្រាលត្រង់កន្លែងដែលព្រះអានន្ទបង្ហាញរួចហើយ ក៏

មានសេចក្ដីត្រេកអរសប្បាយរីករាយ ។

នាងវិសាខា បានធ្វើទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់ ៤ ខែក្នុងវត្តបុព្វារាម ក្នុងឱកាសដែលសម្ពោធឆ្លងប្រាសាទថ្មី លុះដល់ថ្ងៃទីបំផុតបុណ្យ នាងបានប្រគេនសាដកសំរាប់ធ្វើចីវរមានចំនួនច្រើនដល់ភិក្ខុសង្ឃ ព្រមទាំងបច្ច័យដទៃទៀត មានភេសជ្ជបច្ច័យផង ។ នាងបានបរិច្ចាគទ្រព្យក្នុងព្រះពុទ្ធសាសនា កសាងសមិទ្ធផលផ្សេងៗ អស់ចំនួនជាច្រើន គឺបរិច្ចាគទ្រព្យទិញដីកសាងវត្តបុព្វារាម អស់ ៩ កោដិកហាបណៈ, បរិច្ចាគទ្រព្យទិញទព្វសម្ភារៈធ្វើសេនាសនៈផ្សេងៗ មានប្រាសាទជាដើម អស់ ៩ កោដិកហាបណៈ, រួមការបរិច្ចាគទាំងអស់ត្រូវជា ២៧ កោដិកហាបណៈ ។

គួរឲ្យស្ងើចសរសើរចំពោះនាងវិសាខា ដែលជាអ្នកមានប្រាជ្ញាឈ្លាសវៃ សូម្បីនាងបិតនៅក្នុងភេទជាស្ត្រី មានស្វាមីហើយមកនៅក្នុងផ្ទះនៃមិគារសេដ្ឋីជាឪពុកក្មេកដែលជាមនុស្សមិច្ឆាទិដ្ឋិ មិនជឿកាន់ព្រះពុទ្ធសាសនាសោះ នាងចេះធ្វើឧបាយផ្ចាញ់ទូន្មានឪពុកក្មេក ដរាបដល់ឪពុកបានលះបង់គំនិតដែលយល់ខុសនោះចេញ ហើយងាកមកជឿកាន់ព្រះពុទ្ធសាសនាវិញ មិនតែប៉ុណ្ណោះឡើយ នាងបានបរិច្ចាគទ្រព្យសម្បត្តិជាច្រើន តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ពុំមានស្ត្រីដទៃណាមួយដូចនាងវិសាខាបានឡើយ ។

ក្នុងថ្ងៃដែលសម្ពោធឆ្លងវិហាររួចស្រេចហើយ, វេលាថ្ងៃរសៀលល្ងាច នាងវិសាខាដោយមានកូនចៅចោមរោមហែហមផង នាងបានគិតថា កិច្ចការណាដែលអាត្មាអញបានផ្គងទុកពីមុនមក កិច្ចការទាំងអស់នោះក៏បានសម្រេចចប់សព្វគ្រប់អស់ហើយ នាងដើរក្រឡឹងជុំវិញប្រាសាទថ្មីដែលទើបនឹងធ្វើហើយ ដោយមានសេចក្តីត្រេកអររីករាយខ្លាំង ក៏បន្លឺឧទានវាចា ដោយសំឡេងដ៏ពីរោះ ៤ បទថា :

១– សេចក្តីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎! អាត្មាអញនឹងបានកសាងប្រាសាទថ្មីដែលបូកលាបដោយកំបោរ ឲ្យជាវិហារទាន គំនិតនោះ អាត្មាអញក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

២– សេចក្តីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎! អាត្មាអញនឹងបានធ្វើគ្រែ តាំង ពូក និងខ្នើយ ឲ្យជាសេនាសនភណ្ឌ, គំនិតនោះអាត្មាអញក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

៣– សេចក្តីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎! អាត្មាអញនឹងបានតាក់តែងនូវសលាកភត្តដែលលាយបដោយសាច់ដ៏ស្អាត ឲ្យជាភោជនទាន, គំនិតនោះ អាត្មាអញ ក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

៤– សេចក្តីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎! អាត្មាអញនឹងបានឲ្យសំពត់ដែលនាំមកអំពីដែនកាសី, សំពត់ដែលធ្វើអំពីសរសៃ

សំបកឈើ និងសំពត់ដែលធ្វើអំពីកប្បាស ឲ្យជាចីវរទាន, គំនិតនោះ អាត្មាអញក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

៥– សេចក្តីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎ អាត្មាអញនឹងបានឲ្យទឹកដោះខាប់ ទឹកឃ្មុំ ប្រេង និងទឹកអំពៅ ឲ្យជាភេសជ្ជៈទាន, គំនិតនោះ អត្មាអញក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

ភិក្ខុទាំងឡាយ បានឮសំឡេងនៃនាងវិសាខានោះហើយ ក៏នាំគ្នាទៅក្រាបបង្គំទូលព្រះបរមសាស្តាថា សូមទ្រង់ព្រះមេត្តាប្រោស, អស់កាលជាយូរមកហើយ, ខ្ញុំព្រះអង្គទាំងឡាយ ពុំដែលធ្លាប់បានឮនាងវិសាខាច្រៀងឡើយ, ទើបតែក្នុងថ្ងៃនេះ នាងវិសាខា ដែលមានកូននិងចៅចោមរោមជាបរិវារ ច្រៀងដើរក្រឡឹងព័ទ្ធជុំវិញប្រាសាទ, ក្រែងនាងវិសាខាកើតប្រមាត់ទៅជាឆ្កួតទេដឹង? ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ; នាងវិសាខា ជាធីតានៃតថាគត មិនមែនច្រៀងទេ, អធ្យាស្រ័យរបស់នាងវិសាខា បរិបូណ៌ដោយការបំពេញកុសលបានច្រើនយ៉ាង, នាងមានសេចក្តីសប្បាយចិត្ត ព្រោះបានឃើញសេចក្តីប្រាថ្នាដែលខ្លួនបានតម្កល់ទុកមកទាំងប៉ុន្មាន ក៏បានសម្រេចដោយសព្វគ្រប់ ទើបបន្លឺឧទានវាចាយ៉ាងនេះឯង ។

ព្រះបរមសាស្តា ទ្រង់មានបន្ទូលចំពោះភិក្ខុទាំងឡាយនោះរួចហើយ ទើបទ្រង់សំដែងធម៌តទៅទៀតថា :

(តៅអាគត)

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព

## ពិចារណាដើម្បីយល់តក្កវិជ្ជា

(ត)

លោក ហ៊ុន គិមសៀ រៀបរៀង

## ការបែងចែកទស្សនៈ និង ការឲ្យន័យ

*ក– ឲ្យន័យបានសេចក្ដីថា វែកញែកនូវលក្ខណៈឯកឯងនៃទស្សនៈ*

*ខ– ឲ្យន័យយ៉ាងណា ទើបបានត្រឹមត្រូវ?*

*គ– អត្ថន័យនៃការឲ្យន័យ*

*ឃ– បែងចែកទស្សនៈ*

*ង– វិធាននៃការបែងចែក*

*ច– រូបមន្តខ្លះៗ ក្នុងការបែងចែក ។*

ក. យ៉ាងណាដែលហៅថា ការឲ្យន័យ? បានសេចក្ដីថា វែកញែកនូវលក្ខណៈឯកឯង (Privé) នៃទស្សនៈ:-

*នៅក្នុងរឿងនេះ យើងចង់និយាយថា : តើយើងត្រូវធ្វើដូចម្ដេច*

ដើម្បីវែកញែកឲ្យបានច្បាស់នូវលក្ខណៈឯកឯង (Caractère privé) និងលក្ខណៈទូទៅ (Caractère général) នៃទស្សនៈ? ជាបឋមយើងត្រូវអធិប្បាយអំពីរបៀបវែកញែកលក្ខណៈឯកឯង ។

ការវែកញែករកលក្ខណៈឯកឯងនៃទស្សនៈ (Concept) គឺជាការបង្ហាញនូវលក្ខណៈផ្ទាល់នៃវត្ថុនោះ ។ ឯវត្ថុនោះ គឺជាវត្ថុអ្វី? ។

ឧបមាដូចមនុស្សខ្លះ គេសួរយើងឲ្យពន្យល់ន័យអំពីមនុស្ស តើយើងត្រូវឲ្យន័យ (définir) យ៉ាងដូចម្ដេច? ។ យើងមិនអាចឆ្លើយថា: "មនុស្សគឺជាសត្វចេះការប្រពន្ធ ដើម្បីបង្កើតជាគ្រួសារ, ចេះពាក់មួកក្នុងពេលដើរហាលថ្ងៃ... នោះទេ ។ ផ្ទុយទៅវិញ យើងត្រូវឲ្យន័យមនុស្សដូចតទៅទើបត្រឹមត្រូវ ៖ មនុស្សគឺសត្វលោកម្យ៉ាង ចេះបង្កើតឧបករណ៍សម្រាប់ប្រើ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការពិចារណា" ។

បើគេសួរយើងថា : "ទឹកគឺជាអ្វី? ហើយយើងឲ្យន័យថា ទឹកគឺជាវត្ថុរាវសម្រាប់ផឹក" កាលណាគេឮភ្ញាម គេចង់សើច ពីព្រោះការឲ្យន័យនេះវាមិនត្រឹមត្រូវសោះ ។ ផ្ទុយទៅវិញ យើងត្រូវឲ្យន័យទៅតាមវិទ្យាសាស្ត្រដែលបង្រៀនយើងថា ទឹកគឺជាវត្ថុរាវ គ្មានពណ៌ គ្មានក្លិន គ្មានរសជាតិ ហើយថ្លាផង ។ អស់ទាំងនេះហើយដែលយើងហៅថា "ការឲ្យន័យ បានសេចក្ដីថា ការវែកញែកលក្ខណៈឯកឯង" នៃទស្សនៈ ។

យើងបានស្គាល់វត្ថុច្រើនណាស់ ប៉ុន្តែបើគេបង្គាប់ឲ្យយើងឲ្យន័យ

របស់វត្ថុទាំងនោះ យើងមានការពិបាកច្រើនដែរ ពោះបើអ្នកធ្លាប់រៀនសូត្រច្រើនក៏ដោយ ។

## យើងសុំយកឧទាហរណ៍ក្នុងការឲ្យន័យអំពីទឹក

ទឹកគឺជាវត្ថុរាវ, គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិហើយថ្លា ។ តើយើងមានឃើញអ្វីខ្លះ? ។ យើងឃើញសមាសភាពនៃប្រយោគក្នុងការឲ្យន័យរួមមាន :

ទស្សនៈប្រភេទវាជិតបំផុតបូករួមនឹងលក្ខណៈផ្ទាល់របស់វត្ថុនោះ ។ ទឹកជាវត្ថុរាវ ។ វត្ថុរាវ គឺជាទស្សនៈប្រភេទរបស់ទឹក, ស្រា, ទឹកដោះ, ប្រេង... ។ ប្រេងខុសពីទឹក, ស្រាខុសពីទឹកដោះ ពីព្រោះជំពូកវាមានខុសគ្នា ប៉ុន្តែវាមានប្រភេទដូចគ្នា គឺវត្ថុរាវ ។ បើយើងឲ្យន័យថា ទឹកគឺជាវត្ថុ តើត្រូវឬទេ? ក៏ត្រូវដែរ ប៉ុន្តែវាមិនត្រឹមត្រូវដល់វត្ថុរាវទេ ពីព្រោះវត្ថុវាមាន រឹង, ទន់, រាវ, ជ្រាយ ។ បើយើងថា វត្ថុរាវ ទើបវាត្រូវច្រើនជាង ។ ចំណែកឯលក្ខណៈ គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិ គឺជាលក្ខណៈពិសេសនៃជំពូកទឹក ក្រៅពីទឹកគឺគ្មាន ។ មកដល់ត្រឹមនេះ យើងទាំងអស់បានថា : ការឲ្យន័យ សំខាន់ណាស់ បើយើងឲ្យន័យផ្តេសផ្តាសចំពោះវត្ថុមួយ បានសេចក្តីថាយើងយល់វត្ថុនោះមិនទាន់ច្បាស់នៅឡើយទេ ។

សុំជូនឧទាហរណ៍មួយទៀត : ជនជាតិគឺជាអ្វី? ជនជាតិគឺពួក

មនុស្សមួយគ្រួសារធំដែលរស់នៅទាក់ទងគ្នា កើតឡើងក្នុងប្រវត្តិសាស្ត្រ មានការទាក់ទងខាងភាសា, សំដីនិយាយ, អាណាចក្រ, ជីវភាពខាងសេដ្ឋកិច្ច, ខាងការលូតលាស់ក្នុងផ្លូវចិត្ត ដែលរួបរួមគ្នាឲ្យបានទៅជាវប្បធម៌មួយ ។

## ១- ឲ្យន័យយ៉ាងណាទើបបានត្រឹមត្រូវ ?

យើងយកឧទាហរណ៍ "ពលកម្មគឺជាអ្វី?" ពលកម្មគឺជាការចលនាមានគោលបំណងរបស់មនុស្សក្នុងសង្គម ដោយប្រើឧបករណ៍កែប្រែធម្មជាតិ ។

បើនិយាយអំពីរបៀបសរសេរប្រយោគ (phraséologie) យើងយល់ឃើញថា ឃ្លានេះមានពីផ្នែក, ផ្នែកទី ១ គឺយកឧស្សនៈមកឲ្យន័យ ផ្នែកទី ២ គឺប្រើឧស្សនៈក្នុងការឲ្យន័យ ។ ផ្នែកទាំងពីរនេះភ្ជាប់គ្នាដោយពាក្យ "គឺជា" ។ ដូច្នេះយើងយកឧទាហរណ៍ពីរបីមកពិចារណាល្បងមើល?

– ជីវិត គឺជាសាលារៀន,

– ប្រពន្ធបងឯង គឺជាកសិករ... ។ល។ តាមឧទាហរណ៍នេះយើងយល់ថា មិនមែនជាការឲ្យន័យទេ ឬថាការឲ្យន័យមិនត្រឹមត្រូវ ។ តែកាលណាឲ្យន័យមិនត្រឹមត្រូវ យើងមិនអាចចាត់ថាជាការឲ្យន័យបានទេ ។

បើចង់ឲ្យន័យឲ្យបានត្រឹមត្រូវ យើងត្រូវស្គាល់ឲ្យច្បាស់នូវលក្ខណៈនៃវត្ថុ ដែលយើងត្រូវឲ្យន័យ ។ ដូចគ្នានឹងមនុស្សដែលមិនធ្លាប់ស្គាល់ផ្លែខ្នុរ គឺមិនអាចឲ្យន័យបានឡើយ ។ ដូចជាយើងមិនធ្លាប់ហាត់រៀនសម្ភារៈនិយមប្រវត្តិសាស្ត្រ យើងមិនអាចឲ្យន័យបាននូវសម្ភារៈនិយម ប្រវត្តិ-សាស្ត្របានឡើយ ។ ប៉ុន្តែបើយើងគ្រាន់តែស្គាល់វត្ថុ ដើម្បីឲ្យន័យហើយ យើងគ្មានចេះវិធីឲ្យន័យក៏មិនបានដែរ ។

វិធីឲ្យន័យមានបែបផែន ៤ យ៉ាង ហើយការឲ្យន័យណា ដែលមានសភាពប្រហែលៗ នឹងបែបផែនទាំង ៤ ខាងនេះ ទើបយើងចាត់ហៅថា ជាការឲ្យន័យបាន ។

វិធីទី ១– លក្ខណៈទូទៅនៃទស្សន ដែលយើងយកមកឲ្យន័យ និងលក្ខណៈទូទៅនៃទស្សនៈ ដែលយើងប្រើក្នុងការឲ្យន័យ ត្រូវមានតម្លៃស្មើគ្នា ដូចជាយើងឲ្យន័យអំពី "ទឹក" ថាទឹកគឺជាវត្ថុរាវ គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិ ហើយថ្លាដូច្នេះឯង ។ ការឲ្យន័យនេះរាប់ត្រឹមត្រូវ ពីព្រោះពាភាគនៃទឹកនិងវត្ថុរាវ គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិហើយថ្លារាប់ស្មើគ្នា មានលក្ខណៈទូទៅប៉ុនគ្នា ។

បើយើងចង់ដឹងថា តើទស្សនៈពីរនៃការឲ្យន័យ រាប់មានតម្លៃប៉ុនគ្នាឬទេ? យើងត្រូវប្តូរឃ្លានោះល្បងមើល ;

វត្ថុរាវ, គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិហើយថ្លា គឺវត្ថុអ្វី? ។

គ្មានអ្វីក្រៅពីទឹកទេ ។ យ៉ាងនេះ យើងយល់បានថា ការឲ្យន័យនេះ ក៏ត្រឹមត្រូវ ។

ផ្ទុយទៅវិញ យើងយកឧទាហរណ៍ថា :

" ប្រពន្ធបង គឺជាកសិករ" មកពិចារណា យើងឃើញថា មិនមែន "ការឲ្យន័យទេ" ។ យើងផ្ទូរឃ្លានេះល្បងមើល "កសិករ គឺជាប្រពន្ធបង" ។ ស្ដាប់មិនបានសោះ ។ បើដូច្នេះ យើងហៅថា "ការឲ្យន័យមិនបាន" ។

វិធីទី ២– ទស្សនៈប្រភេទប្រើក្នុងការឲ្យន័យ មិនត្រូវឲ្យហួសលក្ខណៈវាទេ ។ ដូចជា "ទឹក" បើយើងថាតែ "វត្ថុ" គ្មានពណ៌, គ្មានក្លិន...មិនមែនទឹកទេ ពាក្យ "រាវ" ជាសំខាន់ណាស់ គឺជាពាក្យបញ្ជាក់លក្ខណៈដាច់ខាត ។ យើងពិនិត្យមើល "វត្ថុរាវ, គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិ គឺកញ្ចក់" តែវត្ថុ "រាវគ្មានពណ៌...គឺទឹក" ។

វិធីទី ៣– បណ្ដាលក្ខណៈដែលយើងយកមកឲ្យន័យ ត្រូវឲ្យស្របនឹងប្រធាន (précis) ត្រូវឲ្យពិតហើយជាក់ ។ ប្រការនេះយើងងាយយល់ទេ ក្នុងការឲ្យន័យខាងប្រភេទ បើយើងប្រើពាក្យមិនចំ ឲ្យន័យមិនចំ គេអាចយល់ខុសទៅថាវត្ថុផ្សេងក្រៅអំពីប្រធាន ។

វិធីទី ៤– ការឲ្យន័យ មិនមែនជាការនិយាយផ្ទុយ បើយើងពន្យល់ដោយប្រើពាក្យផ្ទុយ គឺនាំឲ្យយើងគ្មានបានចេះដឹងអ្វីទាំងអស់ ។

ឧទាហរណ៍ "ដែលហៅថាក្របី គឺមិនមែនគោ, ដែលហៅថា មនុស្ស គឺមិនមែនឆ្កែ" បែបនេះហៅថា "ការឲ្យន័យម្ដេចកើត" ។

វិធីទី ៤– "ការឲ្យន័យ" ត្រូវឲ្យគ្រប់គ្រាន់, ចំៗ, កុំប្រើពាក្យវិលវល់បត់បែនចុះឡើង ។ ឲ្យន័យត្រូវលើកយកតែលក្ខណៈសំខាន់ជាចាំបាច់ ។ ចុះបើយើងថា "មនុស្សមិនមែនជាឆ្កែ" ក៏ម្ដេចកើត ។ ក៏នៅមាន ជ្រូក, មាន់, ទា, ឆ្មា ឯទៀតជាច្រើន ។

## គ- អត្ថន័យនៃការឲ្យន័យ

ការឲ្យន័យមានសារៈសំខាន់ណាស់ក្នុងរឿងដែលយកតាំងឈ្មោះ ។ គេត្រូវចេះថ្លែមលក្ខណៈនៃប្រធាន ក្នុងការឲ្យន័យ ។

ឧទាហរណ៍ យើងយកឧទាហរណ៍ក្នុងអក្សរសាស្ត្រ មួយមកវែកញែក ។

ក–ស្នេហារវាងទុំនិងទាវ គឺជាស្នេហាដែលមានលក្ខណៈ អច្ឆរិយៈ, "អច្ឆរិយៈ គឺជាលក្ខណៈអស្ចារ្យ" ។ ប៉ុន្តែបើយើងចង់ពាក់ពោល យោបល់ខាងលើ យើងត្រូវថែមលក្ខណៈមួយទៀត គឺអស្ចារ្យហើយមនុស្សធ្វើមិនកើតផង ។ ដូច្នេះយើងបានចម្លើយថា "ស្នេហារវាងទុំនិងទាវ ជាស្នេហាដែលមានលក្ខណៈអច្ឆរិយៈម្ដេចកើត បើអច្ឆរិយៈមានន័យថាអស្ចារ្យ មនុស្សធ្វើមិនកើត ។ ចុះបើទុំនិងទាវជាមនុស្សធ្វើកើតទៅហើយ តើស្នេហានេះ ហៅថា"អច្ឆរិយៈ" ដូចម្ដេចបាន? ។

ដល់ត្រង់នេះ យើងទាំងអស់គ្នាយល់បានភ្លាមថា : ការឲ្យន័យមានសារៈសំខាន់ ហើយអនុលោមទៅតាមនិន្នាការថែមទៀតផង ។ ដូចថា : “ចក្រពត្តិ” បើតាមវចនានុក្រម គេពន្យល់ថា : “អំណាចជាធំជិះជាន់លើគេឯង” ប៉ុន្តែបើតាមពួកកុម្មុយនិស្តវិញ បន្ថែមលក្ខណៈ “ជិតស្លាប់” មួយថែមមកទៀត ពីព្រោះគេយល់ថា : តែជិះជាន់ឡើងថ្នាក់ចក្រពត្តិហើយ គឺ “ជិតស្លាប់” ហើយ ។

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

( គ )

ព្រះមហា ចាំង-ខាត់ រៀបរៀង

---

អបករណ នបុំ. កិរិយាបំបាត់, កិរិយាធ្វើឲ្យស្មើ ។

អបករុណ គុ. ដែលមានអាណិតតិច, កាច ។

អបកតិន នបុំ. កិរិយាហែក, កិរិយាកាត់ ។

អបកត្ដ ការក. អ្នកដេរ ។

អបកមិន នបុំ. កិរិយាប្រគល់ឲ្យ. កិរិយាសងបំណុល ។

អបកឞ៌ បុំ. គុណវិបត្តិ, កិរិយាបំបាត់, កិរិយាខ្វះខាត, កិរិយា

ដាក់ចុះ ។ កិរិយាធំឡើង (ផ្ទុ) ។ កិរិយាគិតអនាគត ។

អបកឞ៌ន គុ. ដែលបន្ថយ ។ នបុំ. កិរិយាញែកចេញ, កិរិយា

លើកឡើង ។

អបកឞ៌ិន គុ ដែលបាញ់បន្ថែម ។

អបកលង្ក គុ. ដែលមិនប្រលាក់ ។

អបការ　បុ.　កិរិយាធ្វើឲ្យខុស, សេចក្ដីអន្តរាយ, កិរិយាមើលងាយ ។

-តា ស្ត្រី. ប្រទេច ។

អបការិន៑　គុ.　ដែលធ្វើឲ្យខូចខាត, ដែលដេរប្រទេច ។

អបក្ឫ　ធាតុ.　ញែក, លើកឡើង, ធ្វើឲ្យខុស, ដេរ ។ –ក្ឫត គុ. ដែលធ្វើឲ្យខូចប្រយោជន៍, ញាំញី ។ នបុ. កិរិយាប្រទេច, កិរិយាដេរប្រមាថ ។

អបក្ឫត　ការក.　អ្នកធ្វើឲ្យខូចប្រយោជន៍ ។

អបក្ឫតិ　ស្ត្រី.　កិរិយាដេរ ។

អបក្ឫត្យ　នបុ.　កំហុស ។

អបក្ឫឞ៑　ធាតុ.　ដក, ទាញ ។ យឹត (ធ្នូ) ។ បន្ថយ ។ –ក្ឫឞ៑ ដែលធ្វើឲ្យទៅឆ្ងាយ, ទាប, អាក្រក់, បន្តិចបន្តួច ។

អបក្រមិ　ធាតុ.　ចៀសចេញ, បើកឲ្យ ។ –ក្រាន្ត ដែលថយចេញ, ដែលកន្លងទៅហើយ ។

អបក្រម　បុ.　កិរិយាចរចេញ ។

អបក្រមណ　នបុ　បកត្រា ។

អបក្រិយា ស្ត្រី. កំហុស, វិធីវិលខូច ។

អបក្រី ធាតុ. បានដោយប្រាក់, បាន ។

អបក្រុដ្ឋ គុ ដែលបន្ថោកបន្ទាប ។

អបក្វ គុ. ដែលមិនឆ្អិន ។

អបក្ស គុ. ដែលមិនមានបក្សពួក ។ លោប ឬ _សាទ

បុំ. (អ្នក) មិនបាត់ស្លាប ។

អបក្សិប ធាតុ. ញែកចេញ, បំបែកចេញ ។

អបក្សី ធាតុ. លិចបាត់ (ព្រះចន្ទ្រ) ។ _អបក្សិត គុ. ដែល

លិចបាត់ ។

អបគតិ ស្ត្រី អបគតិ, គតិអាក្រក់ ។

អបគមិ ធាតុ. គេចចេញ, បាត់ទៅ ។ _គិត គុ ដែល

ចេញៈទៅបាត់ ។

អបគម បុំ. កិរិយាចៀសចេញ, កិរិយាចេញទៅ

អបគជិត គុ. ដែលមិនគម្រាម (ផ្ការ)

អបគុណ គុ. អបគុណ, ដែលឥតគុណ ។ កិរិយាបន្ទោស ។

អបគ្រហ៍ ធាតុ. លើកឡើងខ្ពស់, យកចេញ ។

អបយន គុ. ដែលមិនមានពពក ។ បុំ. ខ្ទង

អបប្បុណ៌ គុ. ដែលមិនមានសេចក្តីអាណិត ។

អបង្គតា ស្រ្តី ភាពមិនមានភក់ ។

អបចយ បុំ អបច័យ, កិរិយាបន្ថយ, វិនាស, កិរិយាភាយវៀរ ។

អបចរ៌ ធាតុ. ខុះខាត, ធ្វើខុស ។ _ចរិត នបុំ. កំហុស, កិរិយាប្រមាថ ។

អបចាយិន៑ គុ ដែលមិនគោរព, ដែលធ្វើខុស ។ _ចាយិត្វ នបុំ. ភាពនៃកិរិយាមិនគោរព ។

អបចារ បុំ. កំហុស, កិរិយាប្រមាថ ។ អំពើអាក្រក់, កិរិយាមើលងាយ ៈ សេចក្តីស្លាប់ ។ _ចារិន៑ គុ. ដែលមិនមានភក្តី ។

អបចិ ធាតុ. បន្ថយ ។ _ចិត គុ ដែលបន្ថយ ។

អបចិ ធាតុ រាប់អាន ។ ចិតិ គុ. ដែលគួរគោរព, នបុំ. កិរិយាគោរព, កិរិយាសុំទោស ។

(នៅមានត)

ទុកជាអនុស្សាវរីយចំពោះជនរួមជាតិ

# បណ្តាំកសិករខ្មែរ

ដោយ អ៊ុង-ស៊ុមធ៍

ធ្វើការនៅអគ្គស្នងការដ្ឋានយុវជនរាជសង្គមនិយមខ្មែរ

ខ្ញុំបាទចាស់ហើយ រះគិតមិនស្បើយ ទឹកស្តាយអស្តាយ
កាលវ័យនៅរៀន គ្មានចំសិក្សា ម៉្លោះហើយបញ្ញា
អន់ខ្សោយខ្ទន់ទៅ ។

ពាល់ក្រខ្លាំងណាស់ ចេះពុំជ្រៅជ្រះ ស្មើរល្ងិតល្ងង់ខ្លៅ
រស់ខ្វះវិជ្ជា ប្រដូចប្រៀបទៅ ស្មើខ្វាក់រស់នៅ
ក្នុងរណ្តៅគរថ្ងង់ ។

ខំធ្វៀតសរសេរ នាពេលចំនេរ គ្រាន់កំចាត់បង់
មេរោគអវិជ្ជា ដែលពាញពាក់ចង់ ឲ្យលោកលិចលង់
ក្នុងវដ្តសង្សារ ។

កូនខ្មែរចំរៀន តាមពាក្យទូន្មាន ចាស់ទុំមេបា
គោរពប្រណិបត៌ គ្រូសាស្ត្រាចារ្យ ចប់ការសិក្សា
ធ្វើកសិករ ។

BIBLIOTHEQUE P.P. D'EXTREME ORIENT



កាប់គាស់ករដី កូនខ្មែរប្រុសស្រី ពូជខ្មែរអង្គរ
ធ្វើស្រែចំការ សង់ផ្សារក្រុងល្អ ខ្មែរផុតពាល់ក្រ
ឡើងថ្នាក់អ្នកមាន ។

កាប់គាស់ជីកកាយ ទំនប់ប្រឡាយ ភាពកម្លាំងមាន
នាំគ្នាដោះស្រាយ ជីកព្រែកសង់ស្ពាន ផ្លូវនាំយាន
ចែកជូនអ្នកក្រោយ ។

ធ្វើស្រែចំការ លក់ដូរផលា ខ្លួនរួចរស់ហើយ
កុំនៅទំនេរ ដើរលេងព្រងើយ គិតមើលកុំឲ្យ
ខាតពេលវេលា ។

នៅជិតភូមិផ្ទះ ជីកអណ្តូងស្រះ ចែកទឹកគ្នីគ្នា
ដាំចេកអំពៅ ល្ហុងដូងម្នាស់ បញ្ចឹមមាន់ទា
លក់យកប្រាក់កាស ។

ទំប្រឹងខ្លួនឯង កាប់គាស់លីសែង ដេរប៉ាក់ដុលប៉ះ
កើតមកក្នុងលោក ត្រូវចេះឲ្យច្បាស់ វិជ្ជាសិល្បសាស្ត្រ
ទើបគេឯងគោត ។

ដើរតាមក្បួនច្បាប់ កុំចេះហាប់ ធ្វើតាមការគោត
ផ្សងព្រេងខាតពេល តាមចិត្តលោភលោភ បើទឹងពិសោធ
នៅតាមក្បួនល្អ ។

មុនប្រាជ្ញសរសេរ　ចងក្បួនទុកកេរ្តិ៍　លោកឃើញទោស
សម្រិតសម្រាំង　សម្រេចពូជល្អ　បណ្ដុះបន្ត
តាមសម័យលោក ។

រកស៊ីលោកមាន　បើមិនសូវបាន　គង់រួចបរិភោគ
កុំធ្វើកយមាយ　ដាក់ខ្លួនតាមជោគ　ក្រលុកចូលមក
រកខ្ញុំបុលគេ ។

គំនិតមិនល្អ　កម្មកាយវណ្ណក　ពុំប្រសើរទេ
ខ្ញុំគេមួយគៅ　ត្រៅសេនគេទ្វេ　គ្មានទ្រព្យផ្ទុរផ្ទែរ
ដោះគៅលែងរួច ។

ទំគាប់គាស់ដី　កូនខ្មែរប្រុសស្រី　ចៀសកងទិលខូច
អំពើអាក្រក់　ពាលធក់ប្លន់លួច　នាំកេរ្តិ៍អសោច
ពូជពង្សទេមក ។

ខ្មែរស្មុគត្រង់ណាស់　គោរពធម៌ព្រះ–　ពុទ្ធតាំងអស់គ្នា
ចៀសវាងវៀងបាប　កម្មពៀររវេក　ប្រមូលគ្នាគ្នា
រកបានសួគ៌ខ្មែរ ។

រៀនស៊ីខ្លួនឯង　ទំប្រឹងស្វះស្វែង　រៀងរាល់ថ្ងៃខែ
ដាំតាមវដ្ដ　កោតផលផ្កាផ្លែ　នេះឯងពូជខ្មែរ
លើកកសិករធំ ។

កូនខ្មែរជួយជាតិ ចេះដោះទុកញាតិ ដាំច្រូតស្រូវជុំ
វេរយកដៃគ្នា ខ្មែរតែនិយម នៅតាមស្រុកភូមិ
រួបរួមគ្នាពិត ។

រកទទួលទាន គិតពីបានមាន គ្រប់រូបឆ្ងាយជិត
រស់សុខសប្បាយ ក្នុងកាយជីវិត បបួលគ្នាពិត
រកផ្លូវចំរើន ។

រាជរដ្ឋាភិបាល ចេញជួយគ្រប់កាល ឲ្យបានជឿនលឿន
គ្រប់ផ្នែកវិស័យ ថែជួយរាស្រ្តច្រើន កើនចក្រចំរើន
ទិញផលរាស្រ្តអស់ ។

រាស្រ្តគិតពីដាំ ជ្រើសផលដំណាំ ពូជល្អឥតខ្ចោះ
រាជការរកផ្សារ លក់ដូរលើកបោះ ឃើញប្រាក់ស្រស់ៗ
ហូរចូលជាតិខ្មែរ ។

កុំកាប់ដើមត្នោត ចូរខំដាំជោត តាមដងភ្លឺស្រែ
ត្នោតដុះយូរណាស់ ទំរាំផ្កាផ្លែ រាប់រយឆ្នាំខែ
ទើបហុចផលក្រោយ ។

កូនត្នោតតូចដុះ ហាមកូនស្រីប្រុស ឃាត់គេកុំឲ្យ
កាប់គាស់កំពង់ គ្មានគិតមុខក្រោយ ត្នោតធំដង្ហោយ
ឲ្យផលជាស្ករ ។

ដាក់ក្អមស្រាក់ប៉ោត　　បម្រាញ់ស្ករត្នោត　　ពេញជាស្ករស
ចក្រកំពង់ត្រាំ　　ផ្ទៃប្រស់ទ្វិល្អ　　ធ្វើបានស្ករស
ខ្ចប់ជុំយ៉ាងស្អាត ។

លក់ចែកជូនជាតិ　　ថ្លៃថោកជូនញាតិ　　បំណេញគ្មានខាត
បំណាយបំណូល　　កត់ត្រាតាមខ្នាត　　ជាតិខ្មែរគ្មានខាត
រូបិយប័ណ្ណ ។

ដាំដើមក្រពៅ　　កប្បាសអំពៅ　　ខ្ទឹមស្វាយទៀបបាទ
ម្រេចម្ទេសសារម៉ាវ　　ក្រូចក្រៀរសេមាន់　　គោស៊ូសំខាន់
តាមដីដីល្អ ។

ដីខ្មែរសម្បូរ　　ពលកម្មបង្ហូរ　　ទន្លេហូរហូ
សល់ដីច្រើនណាស់　　ជូនកសិករ　　ជួញមុខរបរ
ខាងកសិកម្ម ។

ហៃអស់ពលរដ្ឋ　　ជួយឲ្យហ្មត់ចត់　　រាជបន្ទូលផ្ដាំ
អង្គព្រះសីហនុ　　កូនចៅចងចាំ　　របរកសិកម្ម
ប្រសើរក្រៃលែង ។

ទៅចាប់ដីថ្មី　　រស់នៅធ្វើអ្វី　　ដីមួយកន្លែង
កើតពីដូនតា　　រើរើហួតហែង　　ដីមួយកន្លែង
គិតគ្នាទំនប់ ។

កូនកើតបន្ត បួនប្រាំតំណ ថែករក្តីមិនគ្រប់
ចាស់បង់ប្អូនឯង ខ្វះគ្មានឈរឈប់ ម្តេចមិនគ្រឡប់
នៅកាន់ដីថ្មី ៗ

ពលរដ្ឋទាំងអស់ កុំភ្លេចឲ្យសោះ យើងរស់ទីងអ្វី
ធ្វើស្រែចំការ កដកស្រ្តមត្រី ឧស្សាហកម្ម
ជោគជ័យជាតិយើង ៗ

កាន់ដីបានធំ ខ្មែររស់ជួបជុំ ចិញ្ចឹមសត្វឡើង
សេះគោក្របី ត្រីមាន់ទាយើង ជួយលើកតំកើង
ដល់សេដ្ឋកិច្ចខ្មែរ ៗ

យន្តក្ពួរកស់ដី សេះគោក្របី អត្តខាត់ហូរហៃ
ចិញ្ចឹមសត្វឡើង តាមភ្នំភូមិស្រែ ហៃអស់កូនខ្មែរ
រកតែឃ្វាលសត្វ ៗ

ស្រែកច្រៀងឆ្ងន់ឆ្ងើយ សូរសម្លេងល្វើយ វង់ធ្វើមប្រមាត់
ខ្មែរច្រៀងឃ្វាលគោ ហួចហៅកោក តាមបំពង់មាត់
ក្តារព្រៃរបោះ ៗ

សប្បាយឆ្នាំងណាស់ ប្រុសស្រីក្មេងចាស់ ខ្មែរយើងទាំងអស់
ប្រើងចិញ្ចឹមសត្វ គ្រប់ច្រកកៀនកោះ ជួញយកប្រាក់ប្រោះ
ព្រំគ្រសារខ្មែរ ៗ

ភ្ជួររាស់យន្តចក្រ　ប្រូតកាត់លើកដាក់　មិនគ្រប់គ្នាទេ
តាមស្ថានភាពដី　ភ្ជុំបំការស្រែ　ពលរដ្ឋក្រស្តខ្មែរ
ត្រូវការប្រើគោ ៗ

សេះឬក្របី　ដឹកផលដំរី　ធ្វើរាល់ភ្ជួរ
ភ្ជួររាស់ជីកដី　ទឹមក្របីគោ　ទិញជាក់លក់ផ្លូវ
រហូតរៀងទៅ ៗ

ខ្លះប្រើយន្តចក្រ　ខ្លះក្រអន់គ្យ　គួរគិតឱ្យជ្រៅ
ប្រើគោក្របី　បានការគ្រប់ផ្លូវ　ចិញ្ចឹមសត្វទៅ
ជំនួយផលជាតិ ៗ

ភ្ជួរស្រែល្ងឹងល្ងើយ　កុំនៅព្រងើយ　អស់ខ្មែរសង្វាត
ឆ្លៀតដាំកូនឈើ　បង្កើនដីជាតិ　សង្កែកង់ស្អាត
ក្រសាំងអង្កាញ់ ៗ

ម្លប់ឈើត្រជាក់　ទាញទឹកភ្លៀងធ្លាក់　ដីកើតជីខ្លាញ់
ដាំដំណាំល្អ　កសិករគេស់អញ　យកផលចំពញ
មួយភាគយ៉ាងធំ ៗ

ពីកូនឈើស្រស់　ទន្ទ្រានទេត្តស្រស់　លាមកមូត្រជ្រាំ
ចំបើងកញ្ជ្រាំង　កុំដុតចោលគម្ពុ　ធ្អឹងសត្វតូចធំ
ផ្សំផ្សំធ្វើជី ៗ

វះគិតឲ្យគ្រប់ កុំតាមទម្លាប់ ដុតរាលខ្ទេចខ្ទី
ពេលរដូវប្រាំង ឃើញភ្លើងឆេះរី រាលពេញដីធ្លី
រាលដល់ព្រៃស្បាត ។

ភ្លើងឆេះរាលស្រែ កូនឈើដុះក្បែរ រោលឆេះរលីស្អាត
ពីគល់ដល់ចុង ជាធ្យូងសុទ្ធសាធ តើនរណាខាត
គឺកសិករខ្មែរ ។

ប្រាជ្ញលោកពោលថា ដីជីអស្ចារ្យ តាមចំការស្រែ
ដាំដុះឈើស្រស់ ដីរស់វិញទេ ម្តេចដុតរាលស្រែ
ដីហិលរលីខាត ។

នាយព្រានប្រមាញ់ កុំដើរបរបាញ់ រុកកនពគត្បាត
បង្ហិនសត្វព្រៃ បក្ស-ទ្វិបាទ ទាំសត្វបង់ខាត
ព្រាត់គូស្រករ ។

ទន្សោងគោព្រៃ ឈ្លូសប្រើសក្របី រមាំងខ្ទីងវល្លិ
ទុកឲ្យគ្នារស ក្ដាន់ស្វានពានរ បាញ់ទាល់តែក្រ
ព្រឹក្សព្រៃខេមរ ។

កុំតាមសប្បាយ ត្រូវទាញចិត្តកាយ កុំដើរប្រហារ
សត្វស្លូតគ្មានពិស ម្តេចមិនមេត្តា សីលប្រាំទៅណា
នាយព្រានកំហូច ។

ស្តាយសត្វស្រុកព្រៃ ទ្រព្យធម្មជាតិថ្លៃ គ្មានអ្វីប្រៀបដូច
បាញ់បំផ្លាញអស់ បានអ្វីតពូជ សូមកុំប៉ុនលួច
វិនាសទ្រព្យជាតិ ។

តំណតទៅ ពាលខូចរឹងនៅ បំផ្លាញសត្វជាតុ
សត្វកាចពិសពុល គួរយេងពិឃាត សត្វស្លូតជាញាតិ
ទុកលំអព្រៃ ។

ប្រាប់ប្រាមកូនចៅ សត្វធំរស់នៅ ចាកផុតទុក្ខភ័យ
ត្រូវមានមេត្តា ករុណាប្រណី កុំទៅប្រល័យ
ចងពៀរព្យាបាទ ។

រស់ជាខេមរា ក្រុងកម្ពុជា រស់រួមមិត្តញាតិ
កិច្ចធំបំផុត រស់បំរើជាតិ សាសនាពុំឃ្លាត
ព្រះរាជបល្ល័ង្ក ។

ពន្លឺភ្លើងចន្ទ្រះនៅស្រុកស្រែ

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

ដែលមាននៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

លោក ញ៉ុក–ថែម រៀបរៀង

( ក )

**បំណងជើង :** „ សាស្ត្រា សេចក្ដីអរិយសត្ថា[១] „

**អ្នកនិពន្ធ :** ព្រះអរិយសត្ថា (?) ។

**កាលបរិច្ឆេទ :** គ្មានបញ្ជាក់ក្នុងអត្ថបទ ។

**របៀបនិពន្ធ :** ពាក្យកាព្យ បទកាកគតិ ។

**ប្រភពរឿង :** ដូចសាស្ត្រាក្រមច្បាប់ ។

**លក្ខណៈឯកសារ :** សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៣ សន្លឹកកន្លះ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកពីវត្តខ្វង កំពង់ចាម

ចុះលេខសាស្ត្រា ៦៦៧ ។

**អត្ថបទផ្ដើម :** បទកាកគតិ ។ អរិយសត្ថា គន់គិតថែងការ បង់ទុក

ជាច្បាប់ ឲ្យអស់សិស្សផង គ្រាប់គ្រងសណ្ដាប យកជាតម្រាប់

តម្រង់អាត្មា ។ ឲ្យមានប្រយោជន៍ ប្រយ័ត្នអសោចន៍

គល់រូបអ្នកណា អម្បាលមករៀន រៀនសាស្ត្រា ប្រយ័ត្នអាត្មា

ការក្ដ័រលោកិយ ។ . . . ល។

---

១ កវីនេះ បានសន្មតយកគោរម្យងាររបស់ខ្លួន ធ្វើជាឈ្មោះអត្ថបទបំណងជើង ។ កវីនេះ ប្រហែលជាបព្វជិត មានសមណសក្តិ ទីរាជាគណៈ ងារជា «ព្រះអរិយសត្ថា» ។

អត្ថបទបញ្ចប់ : អរិយសត្វ គន់គិតថែងការ ថែងចប់សេចក្តី

តម្រង់តម្រាប់ ជាច្បាប់យ៉ាងថ្មី ជាសតៀនស្រដី លើសព្វប្រការៗ

កូនគិតរករៀន កិច្ចការរបៀន របស់ក្សត្រា តាមច្បាប់ទំពាន

ខ្ញុំនាងអាត្មា គ្រប់សិល្បសាស្ត្រា សូមរបចប់ហោង ។

×××

បំណងជើង : "សេចក្តីគម្ពីរច្បាប់ក្រាម([១])"

អ្នកនិពន្ធ : រកមិនបានឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ (បទកាកគតិ) និង ពាក្យកាយ ពន្យល់

ន័យក្នុងសាស្ត្រាច្បាប់ក្រម ។

ប្រភពរឿង : សុជីវធម៌ និង សីលធម៌ ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ៨ ខ្សែ ខ្សែ ១ មានសន្លឹក ៦, ទី ២ មានសន្លឹក ៩, ទី ៣ មានសន្លឹក ១០, ទី ៤ មានសន្លឹក ៩, ទី ៥ មានសន្លឹក ១៣, ទី ៦ មានសន្លឹក ១១, ទី ៧ មានសន្លឹក ១៦, ទី ៨ មានសន្លឹក ១៣ ។ លេខសាស្ត្រា ១៣៧៧ ។

---

១ អត្ថបទពន្យល់ អធិប្បាយ សាស្ត្រាច្បាប់ក្រមនេះ ប្រហែលជាគេទើបនិពន្ធឡើងជាន់ក្រោយទេ ។ អត្ថបទនេះ មានវិបត្តិទាំងអក្ខរាវិរុទ្ធទាំងពាក្យពេចន៍ និង អត្ថន័យ ច្រើនអន្លើណាស់ គេមិនអាចស្ដាប់តាប់យកសេចក្តីបានដូចម្ដេចទេ ។

អត្ថបទផ្ដើម : នេះគឺច្បាប់ក្រម ប្រសើរឧត្ដម ឲ្យនានអ្នកផង ប្រើឲទលំពោន កុំបីមានគ្គង ប្រាជ្ញាបុណ្យផង កើតដោយប្រណិបតន៍ ។

ក្រមគឺស្រឡាញ់ មានអត្ថ ២ មានសេចក្ដីអធិប្បាយដូចម្ដេចខ្លះ ហះអ្នក? . . . . . . . . ។ល។

អត្ថបទបញ្ចប់ : ស្វែងធម៌ជាផ្លូវ ទៅកាន់បរលោក ចូលមហា-បាតិមោក្ខ គឺនិព្វានហោង ។

នេះដូចសត្វលោកយើងសព្វថ្ងៃ គណនាដូចសត្វបក្សីចាប បានកាប់សំបុកទុកកូនទៅ ។ លុះព្រឹកស្វាងកាលណាហើយ ក៏ហើរចរយាត្រា ទៅរកចំណីស៊ីចំអែតអាត្មា នាំអស់ផលាហារ វិលចូលមកសំបុកវិញ ។ ខេមំ ។ គ្រៀមក្បាន្ទដោយអរិយមគ្គ ប្រាសចាកទុក្ខ ។ ខំស្វែងរកធម៌ជាផ្លូវ ទៅមកបានហើយ ទៅកាន់មហាបាតិមោក្ខ គឺចូលហើយចេញ ហើយចូលមកវិញ។ ពុំនោះសោតបីដូចរូបយើងទាំងឡាយរាល់គ្នា សព្វ (ថ្ងៃ) នេះ មានតែព្រះនិព្វានធម៌នោះជាទីពឹង ព្រោះកើតហើយស្លាប់ ស្លាប់ហើយកើតឡើងវិញ មិនមានខ្លះអ្នកឯណាឡើយ ហៅថាព្រះនិព្វានហោង ។ អត្ថទី ១០ ឯវំ ចប់ដោយប្រការអម្បាលណោះហោង ។

×

× ×

បំណងជើង : " សាស្ត្រា ទាវឯក "

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ ៧ (និង បទកាកគតិ បទពំនោល) ។

ប្រភពរឿង : ព្រឹត្តិការណ៍១ក្នុងសម័យលង្វែក (ចលនាទេវនិយម) ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត អក្សរជ្រៀង ទំព័រនីមួយ ១ មាន ៥ បន្ទាត់ ១ខ្សែបច់ ចំនួនសន្លឹក ៣៤ ។ ឯកសារនេះមាន នៅវត្តព្រែកក្រើស ខេត្តកំពត ។

អត្ថបទដើម : នេះទីងថ្វាថ្ងៃពីនេនទុំ នៅខេត្តបាភ្នំដែនដីស្រែ
សង្កាត់សូត្ររៀនចប់អត្ថប្រែ ស្រុកស្រែលង្វែគ្រប់សព្វដែនដី ។
បួសនេននៅវត្តវិហារធំ ចិន-ខ្មែរក្មេងកុំទាំងប្រុស-ស្រី រៀនសូត្រ
ធម៌អាថ៌សាស្ត្រាគម្ពីរ បទបែបបាលីសឹងចេះព្រម ។ មាននេន
មួយសោតឈ្មោះនេនពេជ្រ រៀនសព្វសេចគ្រប់មានរូបឆោម
រ៉ែងចំណោះចេះយ៉ាងល្មម រូបឆោមមុខល្អយ៉ាងកណ្ដាល ។ . .
. . . . . . . . . ។ល។

---

• ខុសចាប់ចុងចួន នៅចុងទី ៣ គួរ "ពាលពលស្រែក្រៅ,, ទើបអាចចាប់ចុងចួនបាន។ ការភ្ជាំងភ្ជាត់ ប្រហែលកើតឡើងដោយការចារចម្លងតៗគ្នា?

សូមជំរាបថា រឿងទុំទាវតែមួយ តែមានចំណងជា "ទាវឯក" ក៏មាន ជា "ទុំទាវ" ក៏មាន ប៉ុន្តែអត្ថន័យប្រហែលជាមានប្លែកៗពីគ្នាខ្លះៗ សូមប្រៀបធៀបមើល ។

អត្ថបទបញ្ចប់ : ថាចិត្តខេះមានះ ពះលោពពះ ពុំគោតបេស្ដា អាង តែអាពុក បានជាទុកញ៉ា អវជូននោះណា ជាស្ដេចត្រាញ់ក្រៅៗ សម្ងាប់ឲ្យអស់ ក្រៅលែងពីនោះ ឲ្យមើលតែឈ្មោះ ដោយ ញាតិជិតឆ្ងាយ ញាតិដីដូនមួយ ពាលពលសង្រេក(១) ៗអស់ ញាតិណា ១ ដែលម្ចាស់មេត្តា ទុកជីវិតនៅ ស្ដេចឲ្យចូលជា អ្នកងារវិញទៅ ប៉ុន្មានដែលនៅ ខេត្តត្បូងឃ្មុំហោង ៗ

អ្នកកុំគុចនូបទុម ចារចម្លងចប់ នៅថ្ងៃពុធ ៥ កេច ឆ្នាំមមី ឆស័ក ព.ស. ២៤៨១, ៗ

×××

បំណងជើង : " សាស្ត្រា ច្បាប់ចាស់ „

អ្នកនិពន្ធ : ព្រះអង្គសត្ថា ៗ

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ៗ

របៀបនិពន្ធ : ពាក្យកាព្យ បទកាកគតិ ៗ

ប្រភពរឿង : ធម្មសង្វេគ តាមគោលពុទ្ធនិយម ៗ

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ ៤ សន្លឹក ៗ ពុទ្ធសាសនបណ្ឌិត្យ បានចារចម្លងអំពីវត្តស្វាយតូង ខេត្ត កំពង់ចាម ចុះលេខសាស្ត្រា ៦៣៩ ៗ

---

១ ពាក្យនេះមិនត្រឹមត្រូវសោះ តែច្បាប់ដើមដូច្នេះ ។

អត្ថបទផ្ដើម : នេះបទកាក ។ សូរ្យសែនរង្សី ត្រឡប់រស្មី ស្រយុត
ចាបទៅ ផះជិតជនភ្នំ ស្រទំនិត្យនៅ រមិលមើលទៅ
ពពកសាត់ឆ្ងាយ ។

ទះទុអនិច្ចា ព្រះសែនសូរ្យា ដូចរូបចាំងឡាយ រីឯពពក
សាត់ជ្រកទៅឆ្ងាយ បីដូចរូបកាយ វិញ្ញាណយើងឯង ។

. . . . . . . ។ល។ . . . .

អត្ថបទបញ្ចប់ : ធ្វើបុណ្យទុកទៅ ទាន់ខ្លួនរស់នៅ ចែកចាយធនធាន
ជីវិតជាមនុស្ស រស់នៅវិញ្ញាណ រក្សាសីលទាន
សំរាប់ខ្លួនចាស់ ។

ព្រះអង្គសង្ឃ គន់គិតថែនបារ ចង់ជាច្បាប់ច្បាស់
តាំងទុកសណ្ដាប់ សម្រាប់ក្មេងចាស់ ឲ្យដឹងជាក់ច្បាស់
ដោយច្បាប់នេះហោង ។

XXX

បំណាំងជើង : " សាស្ត្រា ចៅគាំព្រា "

អ្នកនិពន្ធ : រកមិនបានឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធន៍ : បទកាកគតិ ។

ប្រភពរឿង : ច្បាប់សីលធម៌–សុជីវធម៌តាមប្រពៃណីនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៧ សន្លឹក ។

ឯកសារនេះ គេចារជាតួអក្សរល្អិត ។ មាន ៤ បន្ទាត់ក្នុង ១ ទំព័រ ពុទ្ធសាសនបណ្ឌិត្យបានឯកសារនេះ អំពីវត្ត . . . . (រលប់បាត់) ខេត្តបាសាក់ ( កូសាំងស៊ីន ) ចុះលេខសាស្ត្រា ៦១៨ ។

អត្ថបទផ្ដើម : នេះបទកាកគតិ ។ នុំពៅកំព្រា ពន្ធកស្ងួនភ្ញា សម្ភាញ់អាពុក បណ្ដូលសាច់ត្រួយ តែមួយជាមុខ ការកើត ការស្រុក ស្រែក្ដីសាច់ផៅ ។ អាពុកមានស្ងួន ព្រលឹងខ្ញុំ ខ្ញុំន សង្ឃឹមតែពៅ ជាច្បងបង្អស់ អំណោះវែងពៅ អាពុក ឥឡូវ ខ្ញុំនចាស់ហើយណា ។ . . . . ។ល។

អត្ថបទបញ្ចប់ : ច្បាប់នេះសូរេច ចែនចប់សេចគ្រេច

អស់អាថ៌ដំកល់ ពោះអ្នកឯណា

ប្រាជ្ញាឈ្វេងយល់ រំពឹងឆ្ងាយសល់

ប្រុងប្រាជ្ញាវៃ ។

ត្រិះរិះបំរុង គ្បិតកើតមកក្នុង

បច្ចុប្បន្ននេះនៃ ប្រែខុសជាគាប់

ក្រឡាប់ពេកក្រៃ    កើតក្តីលោភ័យ .
គួរតែអនិច្ចា ។

បើអ្នកណាបាន    ឮបទនេះទូន្មាន
ទុកខ្លួនហើយណា    អ្នកនោះនឹងបាន
រួចពីទុក្ខា    ទោសក្តីលោភា
និរទោសនរភ័យ ។

ប្រកបទូរទ្រព្យ    ធនធានគ្រាន់គ្រប់
ខ្ញុំប្រុសខ្ញុំស្រី    តាមគួរដោយធម៌
ធម៌ប្រធានថ្ងៃ    បរិបូណ៌ស្រេចនៃ
ដល់និព្វានហោង ។

XXX

## បំណាងជើង : "សាស្ត្រា ពេជ្ជតា[1] "

---

១ រឿងពេជ្ជតានេះ មានដំណើរផ្ទៃរឿងប្រហែលនិងរឿងសព្វសិទ្ធិដែរ ។ រឿងនេះដំណាល ពីសត្វប្រពេចញី–ឈ្មោល កាប់សំបុកពង លើមែកព្រឹក្សា ភ្លើងព្រៃឆេះរោលរាលមក ប្រពេចញីសុខចិត្តស្លាប់ជាមួយនិងពងអាត្មា ហើយមុនស្លាប់សច្ចាថាធម្មតាប្រុស កុំឲ្យខ្លួននិយាយរកស្ត្រីសោះ ។ ឯប្រពេចឈ្មោលបានឮដូច្នេះ ក៏តាំងសច្ចាថា សុំឲ្យជួបបញ្ញាជាគូប្រចាំជីវិតតទៅមុខទៀត ហើយហក់ចូលទៅស្លាប់ទៅ ។

ប្រពេចញីបានទៅកើតជារាជបុត្រក្សត្រាអង្គ តាំងពីកើតមកដល់ធំ ឥតនិយាយរកប្រុសណាសោះ សូម្បីព្រះរាជបិតាព្រះនាងក៏មិននិយាយរកដែរ ។ ឯប្រពេចឈ្មោលបានទៅកើតជាបុត្រក្សត្រអង្គដែរ ប៉ុន្តែតួព្រេងតែងបិនព្រាត់ ។ នៅទីបំផុតតួអង្គប្រុស មានចំណេះវិជ្ជាខាងសិល្បសាស្ត្រ ប្រើទាំងបញ្ញាឈ្លាសវៃឆ្លៀង ធ្វើឲ្យព្រះនាងជាតួព្រេងនិយាយរកទាល់តែបាន ។ តួព្រេងនេះ ក៏ត្រូវបានអភិសេកជាមួយគ្នា រួមសុខទុក្ខជាមួយគ្នាតទៅទៀត ។

អ្នកនិពន្ធ : ភិក្ខុធម្មបញ្ញា ម៉ែន

កាលបរិច្ឆេទ : ថ្ងៃអង្គារ៍ ៩កេច ខែអាសាធ ឆ្នាំមមែ ព.ស. ២៤០១

(គ.ស. ១៨៥៨) ។

របៀបនិពន្ធ : ពាក្យកាព្យ (បទកាកគតិ -ពំនោល -ព្រហ្មគីត -

កុដុម្ពលីលា និង លោមនាង ។

ប្រភពរឿង : រឿងនេះមានទំនងជារឿងជាតកមួយដែរ ប៉ុន្តែគ្មាន

បញ្ជាក់អំពីការសេជាតិ ដូចជាជាតកនានាទេ ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៣៦ សន្លឹក ។

ឯកសារនេះពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត កងតាណាំង

ខេត្តកំពង់ចាម ចុះលេខសាស្ត្រា ៦១២ ។ ឯកសារនេះចាស់

គ្រាំគ្រាពេក ខូតស៊ុសន្លឹកស៊ឹករឹតអស់ច្រើន ។

អត្ថបទផ្ដើម : នេះបទកាកគតិ ។ យើងខ្ញុំបង្គំ ក្រុញក្រាបប្រណម្យ

ដោយដាក់សិរសា ឆ្ពោះស្ពោះតម្រង់ ព្រះអង្គគតរ់ ក្រុញក្រាប

វន្ទា ប្រក្រតីសព្វថ្ងៃ ។ ត្បិតខ្ញុំនេះកាត់ ចិត្តខ្ចាំងពេកក្ដាត់

លាក់លេសនៃ មកបួសសំណាក់ កងពុទ្ធញាណញោយ្យ

សេក្របស់សព្វថ្ងៃ តាមពុទ្ធវចនា . . . ។ល។

អត្ថបទបញ្ចប់ : ប្រពេចញីខឹង គន់គិតជញ្ជឹង សច្ចាផ្ដេជា មិនឲ្យស្រដី ទឹងប្រុសណាៗ ដល់កើតជាតិជា មនុស្សប្រុសស្រដី ។ ប៉ុន្តែ ប្រពេច ឈ្មោលចិត្តមិនដាច់ ពីគ្នាឡើយនៃ សច្ចាឲ្យបាន ឈ្មោះស្រីទីទៃ មើបបានមូលមៃ ជាគូគ្នាវិញ ។ ចប់មួយនិទាន លោកប្រើឲ្យបាន ដឹងអាថ៌នោះវិញ ទើបគិតលើកគ្នា លោកប្រែចែងចេញ ចប់និទានមិញ និដ្ឋិតសូរេច ។

×××

ចំណងជើង : " សាស្ត្រាព្រះចានយសកេត្តិ "

អ្នកនិពន្ធ : រកពុំបានឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ - បទកាកគតិ - ពំនោល - ព្រហ្មគីតិ - ភុជង្គលីលា ។

ប្រភពរឿង : រឿងជាតកមួយ (ប៉ុន្តែគ្មានបញ្ជាក់) ថាឋិតនៅក្នុងក្រុមជាតកណាទេ ។ ឯចលនារឿងមានកំសត់ ព្រាត់ប្រាស លទ្ធកម្មផល ពៀរវេរា ដូចរឿងក្នុងសុភមិត្រដែរ ប៉ុន្តែសកម្មភាពរបស់តួអង្គប្លែកផ្សេងគ្នា ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ២ ខ្សែចប់ដុំជាតក ។ ខ្សែទី ១

មាន ៤៣ សន្លឹក, ខ្សែទី ២ មាន ២២ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តកំពោរវៃក្មេង ( អានដោយស្មាន អក្សរលុបអស់ច្រើន ) ខេត្តកំពង់ចាម លេខ ៦០៨ ។

**អត្ថបទផ្ដើម :** នេះបទកាកគតិ ។ លុះលើកកំបង់ . អញ្ជលីផ្គង់
ថ្វាត់ថ្វាយវន្ទា ព្រះអង្គត្រាស់ត្រេច សារពេជ្ញសាស្ដា
បុណ្យបារមីតា លើសលើកពន្ត្រៃ ។ ព្រះអង្គឧត្តម
ខះខំសន្សំ ព្រះបារមីថ្លៃ ព្រះអង្គបានត្រាស់
ច្បងច្បាស់ញាណត្រៃយ្យ ជាព្រះពុទ្ធថ្លៃ បុណ្យបារមីតា ។
ខ្ញុំសូមបង្គំ ព្រះធម៌ឧត្តម . . . . ។ល។

**អត្ថបទបញ្ចប់ :** ឯរាជកុមារ អង្គអញ្ញតថា . គតឯងនោះនៃ
បានត្រាស់ប្រាជ្ញា សារពេជ្ញញាណត្រៃយ្យ ជាព្រះពុទ្ធថ្លៃ
ប្រោសសព្វសត្វផង ។ ឯស្ដេចវិលោ ចិត្តច្រើសលោភោ
រីងរូសកន្ទង ចេះវិលវឹងមក យោនយកជាតិហោង
ទៅទត្តច្រើសឃ្នង ប្រមាថពុទ្ធអង្គ ។

ព្រះអង្គពេជ្ញញាណ ស្ដេចនាំនិទាន កាលជាតិកន្លង
ឆ្ងាយទៅលង់ក្លាត់ ប្រមូលមកផ្គង ជុំជាតកហោង
សូត្រពេម៉្មេះណា ។ (ទៅអាគត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ឡូ-គានជ

ប្រែ-រៀបរៀង

(៣)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

— យូរ—អ៊ុន —

ព្រោះយើងគិតយល់គួរទៅដល់ប៉ូឆ្វូណាស់ ព្រោះពីដើមស្រុកទេសរាស្ត្រកើតបះបោរចលាចលពាល់តែខ្ទេចខ្ទីវិនាសអស់ បណ្ដារាស្ត្រក៏តែទៅជ្រកកូនដោយព្រៃភ្នំក្រំថ្ម លុះតែប៉ូឆ្វូលើកទ័ពទៅបង្ក្រាបបង្ក្រាមសឹកសត្រូវ ទើបបានស្រុកភូមិរាបទាបផាសុកមកដល់ឥឡូវនេះ គ្រានេះអស់បុណ្យប៉ូឆ្វូទៅហើយ បានប៉ូគីជំនួសបិតា មានសតិបញ្ញាអានុភាពលើសជាងបិតាទៅទៀត អាណាប្រជានុរាស្ត្រទាំងពួង ក៏និយមរាប់អានស្រឡាញ់ពេញចិត្តស្មគ្រ សុំឲ្យអ្នកឡើងសោយរាជសម្បត្តិជំនួសយើងចុះ លុះធ្វើរួចក៏ចាត់ប្រើខៀវអ៊ុយ ឲ្យនាំព្រះរាជសារនិងត្រាសម្រាប់រាជ្យទៅប្រគល់ឲ្យប៉ូគី ។

ប៉ូគីបានឃើញព្រះរាជបន្ទូលដូច្នោះ ក៏មានអំណរណាស់ ទើបនិយាយនឹងកាសៀងថា៖ ព្រះចៅហៀនតេ ប្រគល់ត្រាសម្រាប់រាជ្យមកឲ្យយើងដល់២ដងហើយ បើនឹងទទួលយកវេលានេះ ក៏មិនទាន់ផុតអស់

សេចក្តីទិន្នា កាសៀនឆ្លើយថា បើទ្រង់នៅបារម្ភពុំអស់ព្រះទ័យ ត្រូវត្រាស់ប្រើទៀវអ៊ុមឲ្យនាំយកត្រាទៅថ្វាយវិញម្តងទៀត ឲ្យទៀវអ៊ុមនិយាយនឹងហ៊្វីហ៊ុម ឲ្យទូលព្រះចៅហៀនតេថា៖ បើព្រះអង្គទ្រង់ព្រមប្រគល់រាជសម្បត្តិឲ្យចូកីប្រាកដហើយ. ចូរឲ្យចាត់ការសង់កេងពិធីអភិសេកឲ្យខ្ពស់មានថ្នាក់៣ជាន់ ប្រដាប់ទីទៅនៅតាម ប៉ៃមន់ ទង់ ឆ័ត្រតូតនានា តាមបូរាណរាជប្រពៃណីធម្មតាឲ្យសព្វគ្រប់ លុះបានឫក្សពេលល្អ ក៏ត្រូវឲ្យប្រជុំនាម៉ឺនសព្វមុខមន្ត្រីតូចធំឲ្យព្រមគ្នា ទៅប្រជុំក្នុងកេងរាជពិធី ហើយឲ្យចូកីឡើងអង្គុយលើមហាបុស្បុកដែលខ្ពស់ អស់នាម៉ឺនក្រៅពីនោះ ឲ្យក្រាបថ្វាយបង្គំជុំពីក្រោមរាជបល្ល័ង្ក ហើយត្រូវព្រះចៅហៀនតេ ទ្រង់ស្រោចទឹកសង្ខប្រគល់ព្រះខ័នទិនត្រាសម្រាប់រាជ្យថ្វាយព្រះចៅចូកី ជាទីរាជាភិសេកឯកក្សត្រិយ៍សោយរាជសម្បត្តិតទៅ បើព្រះចៅហៀនតេធ្វើតាមដូច្នេះហើយ ទ្រង់ក៏នឹងអស់សេចក្តីគរហោទិន្នា ។

ចូកីបានឮកាសៀនទូលដូច្នោះ ក៏ពេញព្រះទ័យណាស់ ទើបត្រាស់ប្រើទៀវអ៊ុមឲ្យនាំត្រាទៅថ្វាយព្រះចៅហៀនតេទៀត ឲ្យហ៊្វីហ៊ុមនាំឡើងទៅទូលតាមពាក្យកាសៀនគ្រប់ប្រការ ព្រះចៅហៀនតេ ទ្រង់សួរអស់នាម៉ឺនខ្ញុំរាជការថា ហេតុម្តេចបានជាចូកីនៅមិនព្រមទទួលរាជសម្បត្តិឲ្យផុតទៅតែម្តង ហ៊្វីហ៊ុមទូលថា ដែលចូកីនៅមិនទាន់ទទួលនោះ ព្រោះឃើញថា ព្រះអង្គប្រគល់រាជសម្បត្តិខុសអំពីទម្លាប់ច្បាប់រាជប្រវេណីបូរាណ

ច្រើនប្រការ ហ្វឹហ៊ុមក៏ពណ៌នាតាមសំដីកាសៀនឲ្យនិយាយនោះ ទូលព្រះចៅហៀនគេគ្រប់ប្រការហើយទូលថា បើព្រះអង្គទ្រង់ប្រគល់រាជសម្បត្តិឲ្យចូកីនោះ ត្រូវចាត់ការធ្វើឲ្យបានដូចសេចក្តីដែលទូលបង្គំទូលនេះ ទើបចូកីព្រមទទួលជាប្រាកដ នោះតាំងខ្លួនព្រះអង្គនិងព្រះញាតិវង្សរបស់ព្រះអង្គ ក៏នឹងបានពឹងបុណ្យចូកីជាសុខតទៅ ។

ព្រះចៅហៀនគេបានទ្រង់ព្រះសណ្តាប់ ក៏គ្រវីព្រះកេសាហើយដកដង្ហើមធំ ទើបបង្គាប់ឲ្យថៃសៀនជាមេការទៅតាក់តែងរៀបពិធីតាមទំនៀមបុណ្យរាជាភិសេកស្រេចហើយ លុះដល់ខែកត្តិកថ្ងៃ ៤ កើត ជាឫក្សជោគជ័យល្អ លុះព្រឹកព្រានស្វាងព្រះទិនករ ក៏អញ្ជើញចូកីឲ្យឡើងគង់លើបល្ល័ង្កបុស្បក អស់ពួកនាម៉ឺនមុខមន្ត្រីតូចធំមកប្រជុំគ្នាប្រហែល ៤០០ ចូលទៅគង់គាល់ជុំវិញពេញរាជពិធីជាមហោឡារិក មានទាហានទាំងពួកជើងគោកជើងទឹកប្រមាណ ១០ ម៉ឺន កាន់នូវគ្រឿងសាស្ត្រាវុធ ព័ទ្ធជាច្រើនជាន់ដើម្បីការពារអន្តរាយផ្សេងៗ ។

ខណៈនោះ ព្រះចៅហៀនគេ ក៏តាំងព្រះជ័យមាឌៈស្ទុះក្រោកកាន់ព្រះសែងគ្របនិងត្រាសម្រាប់រាជ្យ ហើយទ្រង់ព្រះបន្ទូលសញ្ញា ឡើងទៅលើមហាបុស្បក ក៏ហុចប្រគល់ទៅឲ្យចូកី ។ ក៏ទទួលយកហើយហុចព្រះតម្រាស់នោះទៅអាល័ក្ខណ៍សូត្រប្រកាសប្រាប់អស់នាម៉ឺនមុខមន្ត្រី នូវអស់អាណាប្រជានុរាស្ត្រតាសករទាំងឡាយ សឹងថ្វាយសព្វសាធុការពរ

ECOLE FRANCAISE
BIBLIOTHEQUE
P.P.

ជាកោលាហលអើកក្រើកមហិមា សន្មតថ្វាយព្រះនាមថា ព្រះចៅអ៊ួយប៊ូចូគីកំតាំងនៅក្នុងទីសម្មតិក្សត្រិយ៍ទត្តយកវតាំងពីនោះមក (ព.ស.៧៦៣) ព្រះចៅចូគីកំតាំងទីក្រុងហ៊ូគោ ប្រែជាក្រុងតៃយុកុក ហើយត្រាស់ឲ្យលើកលែងយកពន្ធសួយសារអាករអំពីរាស្ត្រប្រជាគំរប់ ៣ ឆ្នាំ និងឲ្យបើកលែងមនុស្សទោសក្នុងគុក ហើយឲ្យចារឹកអក្សរនៅទីអនុស្សាវរីយ៍ ដែលបញ្ចុះសពបិតាជាថ្មី ហៅថាព្រះចៅថៃឡូហ៊ូហង់គេ ហ៊្វូហ៊ឹមនាំយកសេចក្តីក្រាបទូលថា ប្រវេណីបូរាណលោកមិនដែលឲ្យមានម្ចាស់ផែនដីដល់ ២ ព្រះអង្គគង់នៅក្នុងនគរជាមួយគ្នាទេ ដែលទ្រង់នឹងឲ្យព្រះចៅហៀនតេទៅគង់នៅទីដំបន់ណា ឬប្រការម្តេចក៏ត្រូវសម្រេចឲ្យឆាប់ប្រញាប់ទៅ ហើយហ៊ឹមបង្គាប់ឲ្យព្រះចៅហៀនតេម៉បស្តាប់ព្រះតម្រាស់ព្រះចៅចូគី ១ ក៏តាំងព្រះចៅហៀនតេឡើងជាទីវិសេស ហៅថាសាន់អៀងកុង ហើយឲ្យទៅនៅដំបន់សាន់អៀង ទីនោះមិនត្រូវឲ្យមានដំណែងគាល់ហៅឡើយ ឯបៀវត្សសម្រាប់ឆ្នាំក៏មិនត្រូវឲ្យមាន នោះសាន់អៀងកុងក៏លាចេញទៅ ហ៊្វូហ៊ឹមហូតត្របីឡើងកាន់ហើយស្រែកថា ជាទំនៀមប្រវេណីផែនដីរៀងមក បើមួយអង្គទ្រង់រាជសម្បត្តិហើយ ត្រូវកំចាត់មួយអង្គចេញ ព្រះចៅចូគីប្រោសប្រណីទ្រង់ណាស់ ហើយបានជាទុកព្រះជន្មប៉ុណ្ណេះ ថែមតាំងជាទីសាន់អៀងកុងទៀត ជាព្រះតេជះព្រះគុណគ្មានទីបំផុតទេ អំណើះពីនេះទៅ បើមិនមានព្រះតម្រាស់ឲ្យហៅទ្រង់ចូលមកគាល់ទេ នឹងចូល

មកពុំបានជាដាច់ខាត សាន់អៀនកុនទ្រង់ព្រះវិយោគ ក៏ក្រោកលាចេញទៅ ហើយឡើងគង់លើសេះនាំអស់គ្រប់គ្រួទៅទៅឯជំបន់អៀន ខណៈនោះអស់បណ្ដាជនទាំងឡាយ ឃើញសាន់អៀនកុនត្រូវទីវទេសដូច្នោះ ទាំងអស់គ្នាក៏មានសេចក្ដីអាណិតអាសូរពន់ប្រមាណណាស់ សឹងតែយំស្រណោះអាលោះអាល័យក្រៃពេក ៗ

ឯព្រះចៅចូកិតេញទីជាក្សត្រិយ៍ខត្តិយរាជ មានរិទ្ធិអំណាចលើសលុប ទ្រង់ប្រាប្រព្ធទឹងអស់មន្ត្រីទាំងពួងថា : ការដែលយើងធ្វើទាំងអម្បាលនេះ ត្រូវតាមវម្មាប់ទំនៀមបូរាណហើយឬម្ដេច? អស់នាម៉ឺនខ្ញុំរាជការសឹងក្រាបទូលថា ដែលព្រះអង្គទ្រង់តម្រិះដូច្នេះ ជាត្រឹមត្រូវតាមបូរាណរាជប្រវេណីណាស់ហើយ ៗ ក៏នាំគ្នាសរសើរព្រះសតិបញ្ញាជាអនេកប្បការផ្សេងៗ ហើយជាគួរព្រះអង្គទ្រង់តាក់តែងគ្រឿងសក្ការបូជាពលីការទេវតាអារក្សដែលស័ក្តិសិទ្ធិ បំរើនបុញ្ញារិទ្ធិឲ្យចំរុងរឿងឡើងទៀត ព្រះចៅចូកិទ្រង់យល់ឃើញផង ក៏ត្រាស់ឲ្យភ្នាក់ងាររៀបតាក់តែងគ្រឿងសែនព្រេនតាមទំនៀម កាលព្រះចៅចូកិចេញទៅរៀបសែនព្រេននៅទីពិធីនោះ ក៏បណ្ដាលឲ្យកើតជាព្យុះខ្យល់ខ្លាំងធំអស្ចារ្យ បណ្ដាគ្រឿងអាមិសពលីការជាធូបទៀនទាំងឡាយ ក៏រលំលេតខ្ទាតខ្ចាយទៅអស់ ផ្គរបន្លឺរគឹកកងរាលប្រាំតំព្ធពេញអាកាស ដុំថ្មក៏ប្រឡាសខ្ទាតឡើងទង្គិចគ្នាជាកោលាហល ខ្យល់ក៏បក់ផាត់ដើមឈើអស់ទិសទី មេឃមួម៉ៅរលឹមងងឹតមក មនុស្សម្នាក៏គិត

ភ័យតែជ្រកពួនសព្វគ្រា ទនាទាទីងមើល គ្នាក៏ពុំឃើញពុំយល់សោះឡើយៗ

ព្រះចៅចូក៏ភ័យតក់ស្លុតរន្ធត់ស្មារតីដួលសន្ទប់ទៅ លុះអស់ព្យុះខ្យល់ស្ងប់ស្ងាប់វេលាណា បណ្ដានាម៉ឺនមុខមន្ត្រី ក៏ក្រឡេកឃើញព្រះចៅចូកី ដួលសន្ទប់ដូច្នោះ ក៏នាំគ្នាស្ទុះទៅលើកគ្រាហ៍ឡើងបានមួយស្របក់ ទើបព្រឹកដឹងព្រះអង្គ នាម៉ឺនទាំងពួងក៏អញ្ជើញស្ដេចចូលទៅក្នុងព្រះរាជវាំង ព្រះចៅចូកីក៏ទ្រង់ប្រឈួនជាប់រាយូរថ្ងៃ មិនបានចេញស្ដីរាជការ លុះស្បើយព្រះឈួនកាលណាក៏ៗស្រាហ៍មានៈព្រះទ័យចេញទៅកាន់ទីព្រះរាជរោងរម្យ ទ្រង់និយមលើកសរសើរអស់ពួកខ្ញុំរាជការ ហើយឲ្យលឿនយសសក្ដាជាលំដាប់គ្រប់ៗគ្នាតាមគុណានុរូប ឯព្រះរោគនោះក៏មិនទាន់ស្រះជា ព្រះចៅចូកីមានព្រះទយាសន្ទិះសង្ស័យ ក្រែងខ្មោចព្រៃព្រាយបិសាចកាចខ្ចបនៅក្នុងទីព្រះរាជវាំង ច្រើនណាស់មកពាល់ប៉ះធ្វើឲ្យព្រះអង្គទ្រង់អាពាធមិនស្រះជា ព្រះអង្គក៏ទ្រង់ចិន្ដាថា គួរទីងប្រែទីឋានទៅរកវិមានប្រាសាទឯទីដទៃទៀតចុះ លុះគិតដូច្នោះ ក៏ត្រាស់បង្គាប់ភ្នាក់ងារឲ្យម្ចាម៉ា ទៅកសាងវាំងកំពែងឯទីស្រុកឡុកអៀងវិញ អស់ពួកភ្នាក់ងារនោះមិញក៏ចេញទៅចាត់ការកសាងព្រះរាជវាំងថ្មី នៅទីស្រុកឡុកអៀងហើយស្រេច ព្រះចៅចូកីក៏ស្ដេចទៅគង់នៅទីនោះ ខណៈនោះមានបំរើស៊ើបការនាំអាថ៌ពត៌មានទៅក្រាបទូលព្រះចៅឡៅពីថា៖ តាមដំណើរជាប្រាកដថា ចូកីប្រហារជីវិតព្រះចៅហៀនគេ ហើយដណ្ដើមយកបានរាជសម្បត្តិ ឡើង

សោយរាជ្យជាព្រះមហាក្សត្រិយ៍គង់នៅស្រុកឡុកអៀង ។

ព្រះចៅឡៅពីញូដូចោះ ក៏ទ្រង់ព្រះកន្ទ្រេងកិលាបអាណិតអាណាថណាស់ ត្រាស់ឲ្យបង្គាប់សព្វមុខមន្ត្រី និងអាណាប្រជានុរាស្ត្រប្រុសស្រីស្លៀកពាក់សកាន់ទុក្ខ ហើយឲ្យគាត់តែងគ្រឿងសែនព្រះសពតាមទម្លាប់ទំនៀម ហើយឲ្យតារកព្រះនាមព្រះចៅហៀនគេថា ព្រះចៅហៅមិន-ហង់គេ ដាក់ក្នុងក្តារឈើក្រអូបតាំងទុកបូជា តាំងពីនោះមកព្រះចៅឡៅពីក៏ទូរទុកក្តៅក្រហាយពុំមានសប្បាយក្នុងព្រះទ័យសោះ ចាប់ព្រះរោគអាពាធសព្វអស់ព្រះកាយ ទើងចេញនិយាយរាជការក៏ពុំបាន ទ្រង់ប្រទានមុខងារឲ្យខុងបេងចេញនិយាយរាជការជួសព្រះអង្គ ខុងបេងក៏ឲ្យហៅទៅចេង និងដៀវដីវ នូវអស់នាម៉ឺនទាំងពួងមកប្រឹក្សាថា វេលានេះចូកីកាំលាងព្រះចៅហៀនគេសាបសូន្យទៅហើយ គួរយើងលើកព្រះចៅឡៅពីឲ្យពេញទីជាព្រះមហាក្សត្រិយ៍ សោយរាជសម្បត្តិព្រះរាជវង្សព្រះចៅហៀនគេតទៅចុះ ។

ដៀវដីវថា ខ្ញុំបាទបានឃើញខបទ័ណ្ឌសីមាស្រុកសែឈួន មានទីអស្ចារ្យដោយប្រការផ្សេងៗប្លែកច្រើនណាស់ បានឃើញច្បាស់ជាផ្កាយប្រចាំខ្លួនឡៅពីមានទីរុងរឿងដោយពន្លឺស្មើភ្លឺស្មើព្រះចន្ទ្រ ដែលយើងនឹងលើកឡៅពីឡើងកាន់ទីជាក្សត្រិយ៍ ក៏គិតឃើញគួរល្មមណាស់ ព្រោះឡៅពីជាព្រះរាជវង្សស្រាប់ អស់មុខមន្ត្រីទាំងឡាយបានស្តាប់ ក៏យល់

ឃើញត្រូវតាំងរកស៊ីគ្នា ដោយធ្វើរឿងរ៉ាវតាមប្រាជ្ញា លើកទៀតជាទី

ក្សត្រិយ៍បើឲ្យឡើងសោយរាជសម្បត្តិគង់ផែនដី គឺនាំសេចក្តីនោះយកទៅ

ថ្វាយ ទៀតបានឃើញសេចក្តីចុតហ្មាយដូច្នោះ គឺទុកស្តុតខ្លួនតបចិត្តគិត

ថា បណ្តាមន្ត្រីតាំងរកស៊ីនេះ ដែលមកនាំឲ្យយើងធ្វើដូច្នេះ ដើម្បីមិន

ឲ្យតាំងចិត្តដោយស័ក្ស្ទូរធម៌បាន គិតហើយគឺមានវាចាឆ្លើយប្រកែកកុំ

ទទួល ខ្ញុំរបស់គឺក្រាបទូលទៅថា បណ្តាជាខ្ញុំតាំងឡាយដែលទំនូល

ខ្វាយគិតគ្នាតាំងម៉្លេះ ព្រោះយល់ឃើញថា ចុះជាតួដណ្តើមយករាជ

សម្បត្តិជាតិលោហិតរបស់ព្រះអង្គ បានជាចង់លើកឲ្យទ្រង់គង់ជាម្ចាស់

ផែនដីតទៅ ។

ទៀតថា បើយើងព្រមទទួលធ្វើជាម្ចាស់ផែនដីនេះហើយ តោះបី

បើយើងមិនបានដណ្តើមយករាជសម្បត្តិដូចគេ គឺគង់មានគេថាដូចជា

ដណ្តើមរាជសម្បត្តិដូចអាសត្រូវនោះដែរ ថាតែប៉ុណ្ណោះគឺក្រោកឡើងចូល

ទៅក្នុង លុះគន្លងមកពាក្យ ខ្ញុំរបស់ឲ្យប្រជុំអស់នាម៉ឺនមុខមន្ត្រីចូលទៅ

គាល់ព្រមគ្នា ទៅបង្គំទូលថា បណ្តានាម៉ឺន និងបណ្តារាស្ត្រទាំងនាសឹង

មានសេចក្តីស្នេហាស្រឡាញ់ទ្រង់ បង់ឲ្យឡើងសោយរាជសម្បត្តិពិត

ណាស់ ទើបប្រជុំយល់ព្រមគ្នាលើកព្រះអង្គឡើងជាមហាក្សត្រិយ៍សោយ

រាជសម្បត្តិតទៅ ដើម្បីនឹងលើកទ័ពទៅកំចាត់អាសត្រូវចុះឲ្យវិនាសចេញ

បំផ្លាញរាស្ត្រនោះមិញ ជាទីសង្ស័យគង់នូវព្រះទៅមៀនគេឲ្យបាន ។

( នៅមានត )

# ឯកសារ កម្ពុជសុរិយា

(ក)

លោក ឌឹក-គាម ប្រមូលរៀបរៀង

អកតញ្ញូរបស់លោកកម្មបុត្ត : ទ.ក. ១៥, ទំព័រ ៩, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

អក្សរសាស្ត្រខ្មែរសង្ខេប : លោក ក៉យ-ប៊ុក ទ.ក.៩, ទំព័រ ៨២៨, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

អក្សរសាស្ត្រខ្មែរក្រោយសម័យអង្គរ : លោកស៊ិន ហ៊ិន ទ.ក ៤, ទំព័រ ៣៩៧, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

អង្គរកេរ្តិ៍ដំណែលខ្មែរ : លោក ក៉េ-ប៊ុក ទ.ក. ៣, ទំព័រ ១៨៤, ឆ្នាំ ១៩៥០, (ម ៥២/២២) ។

អង្គរក្នុងសតវត្សរ៍ទី ១៣ : ឃុនទិព្វមន្ត្រី ញ៉ុក-ថែម ទ.ក. ១, ទំព័រ ១៥, ឆ្នាំ ១៩៤៤, (ម.៥២/១៦) ។

អង្គរ និង សម័យអង្គរ : លោកផេន-ដើរ ទ.ក. ៧, ទំព័រ ៨២០, ឆ្នាំ ១៩៦២ (ម.៥២/៣៤) ។

អង្គរវត្តក្នុងសតវត្សរ៍ទី១៦-១៧: ហ្លួងទិព្វមន្ត្រី ញ៉ុក-ថែម ក.ទ. ១១, ទំព័រ ៥៦១ ឆ្នាំ ១៩៤៦, (ម.៥២/១៨) ។

អង្គុដ្ឋរកុមារ : លោក លាង-ហ័បអាន ទ.ក. ៣, ទំព័រ ២០៩,
ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។
អដ្ឋង្គិកមគ្គ : អ្នកឧកញ៉ា ពា-សាន ទ.ក. ៦, ទំព័រ ៥០៣,
ឆ្នាំ ៩៦២ (ម.៥២/៣៤) ។
អណ្ដើកនិងស្វា : ទ.ក. ៧ ៨-៩, ទំព័រ ១៥២, ឆ្នាំ ១៩៣៣,
(ម.៥២/៦) ។
អណ្ដើកមាស : លោក លី-ធាមតេង ទ.ក ៨, ទំព័រ ៧៤៧,
ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។
អតិចារិណីយក្ខិនី : លោក ឈឿន-កុល ទ.ក. ៩, ទំព័រ ៦៤១,
ឆ្នាំ ១៩៤៩, (ម.៥២/២១) ។
អត្តកថា : ព្រះមហា សៅរ៍-យ៉យ ទ.ក. ២, ទំព័រ ៨៣, ឆ្នាំ
១៩៥៤, (ម.៥២/២៦) ។
អត្តជាតសុខកថា : ព្រះមហា អ៊ុក-អ៊ុន ទ.ក. ១១, ទំព័រ ៩៦៩,
ឆ្នាំ ១៩៥៨ (ម ៥២/៣០) ។
អត្តនោកម្មការណាកថា : ព្រះមហា អ៊ុក-អ៊ុន ទ.ក. ៩, ទំព័រ
៧៨៧, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។
អត្តបេមកថា : ព្រះមហា ឡេ-ឡាប ទ.ក. ៤, ទំព័រ ២៤៤,
ឆ្នាំ ១៩៥៣, (ម.៥២/២៥) ។

អត្តានុទិដ្ឋិ : ទេកញ៉ សំ-ស៊ុន ទ.ក. ៣, ទំព័រ ១៧៦; ឆ្នាំ ១៩៥២, (ម.៥២|២៤) ។

អត្តានុវត្តគាថា : ព្រះអាចារ្យ ផេង-សុខុំ ទ.ក. ៥, ទំព័រ ៣៣១, ឆ្នាំ ១៩៥៥; (ម.៥២|២២) ។

អត្ថទ្វារគាថា : ព្រះទេពាលិវង្ស សួរ-ហាយ ទ.ក. ៧, ទំព័រ ៦១០, ឆ្នាំ ១៩៥៦, (ម.៥២|២៨) ។

អត្ថន័យនៃការសិក្សា : លោក ស៊ុន-ហ៊ិន ទ.ក. ៣, ទំព័រ ៥៨៤, ឆ្នាំ ១៩៥៩, (ម.៥២|៥) ។

អធិមនោរម្យគាថា ៣ យ៉ាង : ព្រះសាសនមុនី គីម គួរ ទ.ក. ១១, ទំព័រ ១០៨៣, ឆ្នាំ ១៩៦៣, (ម.៥២|៣៥) ។

អធិប្បាយច្បាប់កេរ្តិ៍កាល (កាព្យ) : លោក ស្រ័-អ៊ូ ទ.ក. ៨, ទំព័រ ៧២៦, ឆ្នាំ ១៩៥៨, (ម.៥២|៣ ) ។

អធិប្បាយពុទ្ធភាសិត : លោក លី-ធាមតេង ទ.ក. ៩, ទំព័រ ៧៩៦, ឆ្នាំ ១៩៥៧, (ម.៥២|២៩) ។

អធិប្បាយសុភាសិតៈ យុនទត្តមប្រីជា តាប ពិន ទ.ក ៣, ទំព័រ ៩២៥; ទ.ក. ៤, ទំព័រ ១៦៩, ឆ្នាំ ១៩៤៥. (ម.៥២|១៧) ។

ស្ដើង-ឡូរ ទ.ក. ១០, ទំព័រ ១១៦៦, ឆ្នាំ ១៩៦០, (ម.៥២|៣២) ។

អធិប្បាយសុភាសិតខ្លះ (កាព្យ : លោក ហប-ពិន ទ.ក. ៤, ទំព័រ ៣៦៧, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

អនាមតជមិ : យុទ្ធសុវត្ថិទៅ យូរ អ៊ុន ទ.ក. ៧, ទំព័រ ៦១២, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អនាមយកថា : ខេមរវង្ស ទ.ក. ៣, ទំព័រ២៧, ឆ្នាំ ១៩៤, (ម.៥២/១៣) ។

អនិច្ចកម្មនៃព្រះមហា ឈឹម-ឆង : ទ.ក. ៨, ទំព័រ ៩១៨, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

អនិច្ចកម្មនៃព្រះធម្មមុនី យូរ-ប៉ុណ្ណ : ព្រះទេពសត្ថា សូរ-ហាយ ទ.ក. ១១, ទំព័រ ៨៧១, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

អនិច្ចកម្មនៃព្រះមហា មាស-សុវណ្ណ : ទ.ក. ១០, ទំព័រ ១១៣១, ឆ្នាំ ១៩៦៤, (ម.៥២/៧៦) ។

អនិច្ចកម្មនៃសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិក-និកាយ ទ.ក. ២, ទំព័រ ១៨៨, ឆ្នាំ១៩៥៦ (ម.៥២/២៨) ។

អនុត្តរិយសូត្រ : ព្រះវេជ្ជមាស់ សុធារស ទ.ក. ១, ទំព័រ ២៧, ឆ្នាំ ១៩២៧, (ម.៥២/២)

អនុមោទនវិធី : អាចារ្យ ប៉ែន-សុខ ទ.ក. ១០, ទំព័រ ៩, ឆ្នាំ ១៩៣០ (ម.៥២/៣) ។

អនុស្សាវរីយ៍ចំពោះព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន : លោក អ៊ុង-ស៊ុមន៍ ទ.ក. ៣, ទំព័រ ២១២, ឆ្នាំ ១៩៥៥, (ម.៥២/២២) ។

អនុសិវប្បូរមហាសន្និបាតនៃមន្ត្រីសង្ឃ : ទី ៧ ទ.ក. ២, ទំព័រ១៥១, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។ ទី ១០ ទ.ក. ៣, ទំព័រ ២៣៥, ឆ្នាំ ១៩៥៤ (ម.៥២/២៦) ។ ទី ១១ ទ.ក. ២, ឆ្នាំ ១៩៥៥, (ម.៥២/២៧) ។ ទី ១២ ទ.ក. ១, ទំព័រ ៨៩, ឆ្នាំ ១៩៥៦, (ម.៥២/២៧) ។ ទី ១៣ ឯនប័ន ទ.ក. ៦, ទំព័រ ៦៧៧, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។ ទី ១៥ ទ.ក. ១, ទំព័រ ៩៧, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។ ទី ១៦ ទ.ក. ១, លោក ជង-វង ទំព័រ ៩៨, ឆ្នាំ ១៩៦០, (ម.៥២/៣២) ។ ទី ១៩ ឆ្នាំ ១៩៦២, ទ.ក. ១, ទំព័រ ១០៧, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។ ទី ២០ ទ.ក. ១, ទំព័រ ៩៦, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។ ទី ២១ ទ.ក. ១, ទំព័រ ៧៨, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

អត្ថាយវិទ្ធិនៃសត្វអស្សូគារ : អ្នកឧកញ៉ា ឥស្សរាជ្យ សំ-ស៊ុខ ទ.ក. ២, ទំព័រ ៨៩, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

អន្តរាយកម្ម : ព្រះទេពសត្ថា កឹម គួរ ទ.ក. ៩, ទំព័រ ៨០៣, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

អបរិហានិយធម៌ : លោក ប៊ុ-ប៊ូ ទ.ក. ៩, ទំព័រ ៩៤៩, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

អប្បមាទកថា : ព្រះទេពសត្ថា កឹម-គួរ ទ.ក. ៣, ទំព័រ ២០៣, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អប្បមាទធម៌ : លោក ទ្រិញ-ក៉ញ ទ.ក. ១០, ទំព័រ ៨៧៩, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អបាយមុខ : ព្រះគ្រូសិរីសោភ័ណ កឹម គួរ ទ.ក. ៧, ទំព័រ ៤៩៧, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

អភយធាតុពិសេស : ព្រះឧបាលិវង្ស សូ-ហាយ ទ.ក. ២, ទំព័រ ៨៧, ឆ្នាំ ១៩៥៥, (ម.៥២/២២) ។

អភិធម្មវិភាគ : ព្រះញាណបវរវិជ្ជា អែម .ក. ៨, ទំព័រ ១ ; ឆ្នាំ ១៩២៧, (ម.៥២/២) ។

អភិធម្មត្ថសង្គហ : ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូ ទ.ក. ២, ទំព័រ ១៩, ឆ្នាំ ១៩២៦-២៧, (ម.៥២/១) ។

អភិឆ៌ភាសិត : លោកគ្រូអាចារ្យ អ៊ុក-ជា ទ.ក. ៩, ទំព័រ ១២, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

អត្តជាតករា : ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ ទ.ក. ៨, ទំព័រ ៩៦៥, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

អរិយសច្ចកថា : ព្រះឧបាលិវង្ស ស៊ូ-ហាយ ទ.ក. ៦, ទំព័រ ៥០៣, ឆ្នាំ ១៩៤៧, (ម.៥២/២៩) ។

អរិយសច្ចជាពុទ្ធភាសិត : លោកគ្រូអាចារ្យ ប៉ាង-ខាត់ ទ.ក. ១, ទំព័រ ៤២, ឆ្នាំ ១៩៦៥ (ម.៥២/១៧) ។

អវិជ្ជា : លោក ផេង-ជ្រីវ ទ.ក. ២, ទំព័រ ១២១, ឆ្នាំ ១៩៦២, (ម.៥២/៣៦) ។

អវិជ្ជា និង វិជ្ជា : ព្រះញាណបវរវិជ្ជា អែម ទ.ក. ៣, ទំព័រ ៣៥, ឆ្នាំ ១៩៦៧, (ម.៥២/២) ។

អសារគតសូត្រ : ឧកញ៉ាកត្តិកជា យ៉ាំង ទ.ក. ១-២-៣, ទំព័រ ៦៣, ឆ្នាំ ១៩៣៧, (ម.៥២/៦) ។

អាខ្វាក់អាខ្វិន (រឿងព្រេង) : ទ.ក. ៤-៥-៦, ទំព័រ ១៩៣, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

អាជីវកម្មគឺអ្វី? : ខេមរវង្ស ទ.ក. ៩, ទំព័រ ៣, ឆ្នាំ ១៩៦១, (ម.៥២/១៣) ។

អាធ្មឹង (រឿង) : អ្នកឧកញ៉ាសុត្តន្តប្រីជា ស៊ំ-ស៊ុខ ទ.ក. ១០, ទំព័រ ៥៤៣, ឆ្នាំ ១៩៦៧, (ម.៥២/១៩) ។

អាចារចិត្តជា : ទេគញ្ញាបញ្ញាធំបតិយិន ទ.ក ១-២-៣, ទំព័រ ១៦២ ឆ្នាំ ១៩៣៣, (ម.៥២/៦) ។

អាជីកាំចាំងរបស់ព្រះពុទ្ធសាសនា : លោក ប៊ូ ប៊ូ ទ.ក. ៧, ទំព័រ ៨០. ឆ្នាំ ៩៦៣ (ម.៥២/៣៥) ។

អាណុភាពនៃខ្មែរអតីត : លោក ក៉យ-ប៊ុក ទ.ក. ៩, ទំព័រ ៨០៦, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អាប៊ូលហ្វារ៉ុស្ស : លោក ក៉យ-លុត ទ.ក. ១, ទំព័រ ៤៣, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

អាពុកក្មេកកើសក្ដ ប្រុសារ : ទ.ក.១ - ២ - ៣, ទំព័រ ១២៥, ឆ្នាំ១៩៣៦ (ម.៥២/៨) ។

អាមាត្យរក្សាផ្ទៃព្រះរាជទ្រព្យ (រឿងព្រេង) : ទ.ក. ១៧-១៨, ទំព័រ ៦៦, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

អាយុសម័យនៃពុទ្ធរូប មន-ខ្មែរ-ថៃ : ទ.ក. ២, ទំព័រ ១៩, ឆ្នាំ ១៩៤០. (ម.៥២/១២) ។

អាះយោធនាពោធាស់ : សាស្ត្រាចារ្យ ផេង-ជ្រើរ ទ.ក. ១២, ទំព័រ ៩១៤, ឆ្នាំ ១៩៥[illegible] (ម.៥២/២៣) ។

អារក្សថ្ងៃដើររឿងម្ដៃស្រី (រឿង) : លោក សាំង-សាវេត ទ.ក. ៣, ទំព័រ ៥៤៦, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

សោយរាជ្យជាព្រះមហាក្សត្រិយ៍គង់នៅស្រុកឡុកអៀង ។

ព្រះចៅឡៅពីញូហោះ ក៏ទ្រង់ព្រះកន្សែងកំលាបអាណិតអាណាថណាស់ ត្រាស់ឲ្យបង្គាប់សព្វមុខមន្ត្រី និងអាណាប្រជានុរាស្ត្រប្រុសស្រីស្លៀកពាក់សកាន់ទុក្ខ ហើយឲ្យគាត់តែងគ្រឿងសែនព្រះសពតាមទម្លាប់ទំនៀម ហើយឲ្យតាំងព្រះនាមព្រះចៅហៀនគេថា ព្រះចៅហោមិន-ហង់តេ ដាក់ក្នុងក្ការឈើក្រអូបតាំងទុកបូជា តាំងពីនោះមកព្រះចៅឡៅពីក៏ទូរទំទុកក្តៅក្រហាយពុំមានសប្បាយក្នុងព្រះទ័យសោះ ចាប់ព្រះរោគអាពាធសព្វអស់ព្រះរាងកាយ នឹងចេញនិយាយរាជការក៏ពុំបាន ទ្រង់ប្រទានមុខងារឲ្យឧងបេងចេញនិយាយរាជការជួសព្រះអង្គ ឧងបេងក៏ឲ្យហៅទៅចេង និងជៀវដីវ នូវអស់នាម៉ឺនទាំងពួងមកប្រឹក្សាថា វេលានេះចូកិកវំណាងព្រះចៅហៀនគេសាបសូន្យទៅហើយ គួរយើងលើកព្រះចៅឡៅពីឲ្យពេញទីជាព្រះមហាក្ស ត្រិយ៍ សោយរាជសម្បត្តិគ្រងរាជវង្សព្រះចៅហៀនគេតទៅចុះ ។

ជៀវដីវថា ខ្ញុំបាទបានឃើញខបទំណូសីមាស្រុកសៃឈួន មានទីអស្ចារ្យដោយប្រការផ្សេងៗប្លែកច្រើនណាស់ បានឃើញច្បាស់ជាផ្កាយប្រចាំខ្លួនឡៅពីមានទីរុងរឿងដោយពន្លឺស្មើគ្នីស្មើព្រះចន្ទ្រ ដែលយើងនឹងលើកឡៅពីឡើងកាន់ទីជាក្សត្រិយ៍ ក៏គិតឃើញគួរល្អណាស់ ព្រោះឡៅពីជាព្រះរាជវង្សស្រាប់ អស់មុខមន្ត្រីទាំងឡាយបានស្តាប់ ក៏យល់

ឃើញត្រូវតាំងរស់គ្នា ទើបធ្វើរឿងរ៉ាវតាមប្រាជ្ញា លើកឡើងជាទី
ក្សត្រិយ៍ឲ្យឡើងសោយរាជសម្បត្តិក្នុងផែនដី ក៏នាំសេចក្ដីនោះយកទៅ
ថ្វាយ ឡើងបានឃើញសេចក្ដីចុតហ្មាយដូច្នោះ ក៏ទ្រង់ស្ទុតខ្ទើតចិត្តគិត
ថា បណ្ដាមន្ត្រីតាំងរស់នេះ ដែលមកនាំឲ្យយើងធ្វើដូច្នេះ ដើម្បីមិន
ឲ្យតាំងចិត្តដោយស័ត្យទូរធម៌បាន គិតហើយក៏មានវាចាឆ្លើយប្រកែកពុំ
ទទួល ខ្ញុំបេងក៏ក្រាបទូលទៅថា បណ្ដាជាខ្ញុំតាំងឡាយដែលទំនួល
ខ្វាយតិតគ្នាតាំងម្ទេះ ព្រោះយល់ឃើញថា ចូកីជាគួរដណ្ដើមយករាជ
សម្បត្តិធាតុលោហិតរបស់ព្រះអង្គ បានជាចង់លើកឲ្យទ្រង់គង់ជាម្ចាស់
ផែនដីតទៅ ។

ទៀតថា បើយើងព្រមទទួលធ្វើជាម្ចាស់ផែនដីនេះហើយ តោះបី
បើយើងមិនបានដណ្ដើមយករាជសម្បត្តិដូចគេ ក៏គង់មានគេថាដូចជា
ដណ្ដើមរាជសម្បត្តិដូចអាសត្រូវនោះដែរ ថាតែប៉ុណ្ណោះក៏ក្រោកឡើងចូល
ទៅក្នុង លុះកន្លងមកពាក់ថ្ងៃ ខ្ញុំបេងឲ្យប្រជុំអស់នាម៉ឺនមុខមន្ត្រីចូលទៅ
គាល់ព្រមគ្នា ទៅបេងទូលថា បណ្ដានាម៉ឺន និងបណ្ដារាស្ត្រទាំងអស់
មានសេចក្ដីស្នេហាស្រឡាញ់ទ្រង់ ចង់ឲ្យឡើងសោយរាជសម្បត្តិពិត
ណាស់ ទើបប្រជុំយល់ព្រមគ្នាលើកព្រះអង្គឡើងជាមហាក្សត្រិយ៍សោយ
រាជសម្បត្តិតទៅ ដើម្បីនឹងលើកទ័ពទៅកំចាត់អាសត្រូវចូកីឲ្យវិនាសចេញ
បំបាត់ការនោះមិញ ជាទីសង់សឹកជំនួសព្រះចៅហៀនគេឲ្យបាន ។

(ចៅហន)

ឧប្បត្តិកាជា វិត្តកាបញ្ហា និង មូលការបញ្ហា : ព្រះសិរីសម្មត្តិវង្ស ឯម ទ.ក. ៧.១២; ទំព័រ ១២៤, ឆ្នាំ ១៩.៣១, (ម.៥២/៩) ។

ឧស្សាហកម្មជាគ្រឿងបេះដូងនៃសេដ្ឋកិច្ច : ខេមរវង្ស ទ.ក. ៩, ទំព័រ ៣, ឆ្នាំ ១៩៤០, (ម ៥២/១២) ។

អូបុនជាបុណ្យព្រលឹងខ្មោច ដែលស្លាប់ទៅតាំងប៉ុន្មាន (ជប៉ុន) ក្រមការ ជុំ-មៅ ទ.ក. ១៦, ទំព័រ ២១៦, ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

ឯកភាពនៃមិលិន្ទបញ្ហា : ឃុនទិពន្ធមន្ត្រី ញ៉ក់-ថែម ទ.ក. ៣, ទំព័រ ១៦៥, ឆ្នាំ ១៩៤៤, ម.៥២/១៦) ។

ឯកនិបាតជាតក : អាចារ្យ ហ៊ឹម ទ.ក. ១-២-៣, ទំព័រ ៤៦, ឆ្នាំ ១៩៣៣, (ម.៥២/៦) ។ ទ.ក. ៤-៥ ៦; ទំព័រ ៨១; (ម.៥២/៦) ។ ទ.ក. ១០-១១-១២; ទំព័រ ៤៥, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

ឯក.សហស្សរាត្រី ភាគ : ១៣ ឃុនសុន្ទរមេធី ញុង-សឿន ទ.ក. ៣, ទំព័រ ១១៣; ឆ្នាំ ១៩៤៧ (ម.៥៥/១៩) ភាគ ១៤ ឃុនសុន្ទរមេធី ញុង-សឿន ទ.ក. ៨; ទំព័រ ៤១១; ឆ្នាំ ១៩៤៧

(ម.៥២/១៩) ។ ភាគ ១២ លោក ធុយ ប៊ុនសួ ទ.ក. ៩, ទំព័រ ៤៦៦, ឆ្នាំ ១៩៤៦, (ម ៥២/១៨) ។ ភាគ ១១ ឃុនសុន្ទរមេធី ញ៉ុន-សៀន ទ.ក. ៥, ទំព័រ ៤២៥, ឆ្នាំ ១៩៤៦ (ម ៥២/១៨) ។ ភាគ១០ ហុងទិពទមន្ត្រី ញ៉ុក ថែម ទ.ក. ១, ទំព័រ ១៦, ឆ្នាំ ១៩៤៦, (ម.៥២/១៨) ។ ភាគ១៥ ឃុនសុន្ទរមេធី ញ៉ុន-សៀន ទ.ក. ២, ទំព័រ ១១៩, ឆ្នាំ ១៩៤៨ (ម.៥២/២០) ។ ភាគ ៤ ក្រមការ ដុំ-ម៉ៅ ទ.ក.១-២-៣, ទំព័រ ១ ៧, ឆ្នាំ ១៩៣៣, (ម.៥២/៦) ។

ឃាតករសារសាស្ត្រាស៊ីការីតនិងក្រាំង : លោក ញ៉ុក-ថែម ទ.ក. ៩, ទំព័រ ៨១៦, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

ឃាតអង្គក្សត្រ : ម. រឿងឯកអង្គក្សត្រ ។

ងិកខមហាត្ថ: កថ្ញូ : លោកប៉ាយ ប៊ុក ទ.ក ៣, ទំព័រ ១៦១, ឆ្នាំ ១៩៥០, (ម ៥២/២២) ។

ចក់ខមាតា : ព្រះមហា ឌឿក អមរ ទ.ក. ៧, ទំព័រ ៦៥១, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

ចពុកម្តាយមានឧបការគុណលើកូនមែនឬមិនមែន : លោក ផេង-ជ្រីវ ទ.ក ៦, ទំព័រ ៥៩៤, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

អ្នកកន្ទាលពៀមស្លូតត្រង់ និង ព្រះរាជបិតា . លោក ផេន-ជ្រីវ ទ.ក. ១២, ទំព័រ ១០៦៩, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អ្នកជម្ងឺរបស់ ដាប់ប្រែការតែឯង : លោក គួច-គីឡេន ទ.ក. ៣, ទំព័រ ២៩៧, ឆ្នាំ ១៩៦០, (ម.៥២/៣២) ។

អ្នកជាតិនិយម : លោក ផេន-ជ្រីវ ទ.ក. ៩, ទំព័រ ៩៣៤, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

អ្នកដំណើរពីរនាក់ : ទ.ក. ៤-៥-៦, ទំព័រ ១៦៥, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

អ្នកតាឃុំនមឿង (រឿងព្រេង) : ទ.ក. ១, ទំព័រ ២៤, ឆ្នាំ ១៩៤១, (ម ៥២/១៣) ។

អ្នកតំណាងខេត្តកំពង់ចាម ដង្ហែគម្ពីរ និង វត្ថុផ្សេងៗ ចូលមកព្រះរាជបណ្ណាល័យ : ទ.ក. ៣. ទំព័រ ១១៥, ឆ្នាំ ១៩២៧ (ម.៥២/២) ។

អ្នកនៅផ្ទះភូមិជិតគ្នា (រឿងព្រេង : ទ.ក. ១០-១១-១២, ទំព័រ ១៤៩, ឆ្នាំ ១៩៣៦, (ម.៥២/៨) ។

អ្នកបរិភោគកាម ១៦ ពួក : ទ.ក. ១២. ទំព័រ ១២៤២, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

អ្នកមានគុណ : លោក ហេង-សំអាន ទ.ក. ៣, ទំព័រ ៦៤៩,

ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

អ្នករៀនដើម្បីជាតិ : លោក អាំង ហួន ទ.ក. ៧, ទំព័រ ៨២៥,

ឆ្នាំ ១៩៦២, (ម.៥២/៣ ) ។

អ្នកស្នេហាជាតិ-សាសនា-មហាក្សត្រ : ឃុនបណ្ណាឌិត្យ

ប៊ូ ប៊ូ ទ.ក. ៣, ទំព័រ ២២៨, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

អ្វីជាទ្រព្យរបស់ មនុស្ស : ភិក្ខុ ឡាយ-គ្រី ទ.ក. ៩, ទំព័រ ៩៣៦,

ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

សូមជំរាបថា ៖ ឯកសារបែបនេះ
ពុំទាន់អស់សព្វគ្រប់នៅឡើយទេ
ត្បិតមានអត្ថបទចុះផ្សាយបន្តទៅ
ជាច្រើនទៀត ដែលយើងនឹងចង
ក្រងផ្សាយទៅអនាគត ។

# ជីវប្រវត្តិ

## នៃព្រះមុនីកោសល សូរ-ហាយ

ចៅអធិការ វត្តទេពោធិរង្សី, អធិបតីរងក្រុមជំនុំព្រះត្រៃបិដក

យើងខ្ញុំជាសិស្ស ទាំងពីររូប ដូចមានឈ្មោះ ក្នុងទីបំផុត ជាអ្នកសរសេររៀបរៀងជីវប្រវត្តិ នៃព្រះតេជព្រះគុណ ជាព្រះឧបសម្បទាចារ្យ ដោយការចែកបរិច្ឆេទនៃជីវប្រវត្តិនេះ មាន ៨ បរិច្ឆេទ ដើម្បីឲ្យងាយមើល ចំណាំក្នុងបរិច្ឆេទមួយៗ តាមរយៈកាលនៃជីវភាព និងករណីយកិច្ច របស់លោក ព្រមទាំងងាយស្រួល ក្នុងការសរសេររៀបសេចក្ដីដូចតទៅនេះ៖

១– ជាតិបរិច្ឆេទ កំណត់អំពីការកើត

២– កុមារបរិច្ឆេទ កំណត់អំពីកាលនៅជាកុមារ

៣– បព្វជ្ជាបរិច្ឆេទ កំណត់អំពីបព្វជ្ជា

៤– ឧបសម្បទាបរិច្ឆេទ កំណត់អំពីឧបសម្បទា

៥– សិក្ខាបរិច្ឆេទ កំណត់អំពីការសិក្សា

៦– ភារធុរបរិច្ឆេទ កំណត់អំពីការទទួលបាននូវសក្តិ

៧– ពុទ្ធវឌ្ឍិបរិច្ឆេទ កំណត់អំពីការធ្វើសេចក្ដីចម្រើនក្នុងព្រះពុទ្ធសាសនា

៨- សេនាសនភណ្ឌបរិច្ឆេទ កំណត់អំពីការ កសាងសេនាសនភណ្ឌ ទុកបម្រើព្រះពុទ្ធសាសនា ។



ព្រះមុនីកោសល សួរ-ហាយ

អធិបតីរងក្រុមជំនុំព្រះត្រៃបិដក

## សេចក្តីរាយការណ៍នៃបរិច្ឆេទមួយៗ ដូចតទៅនេះ ៖

### ១ ជាតិបរិច្ឆេទ កំណត់អំពីការកើត ។

ព្រះមុនីកោសល សួរ-ហាយ កើតក្នុងភូមិតូចមួយ ឈ្មោះ ភូមិឫស្សីជួរ ក្នុងសង្កាត់ក្រាលគោ ឋិតៈនៅក្នុងទិសខាងលិចវត្តបឹងពៃ ចំនួនជាង ២ គ.ម. ក្នុងកាលណោះ ភូមិនោះមានផ្ទះចំនួនតែ ៩ ខ្នង ។ មាតារបស់លោកឈ្មោះ ម៉ុង-ទុក ជាស្ត្រីមានសីលតាំងពីក្មេង, បិតាឈ្មោះ សៅ-សួរ មានលំនៅដើមឈ្មោះភូមិកន្ទួតប្រាំង សង្កាត់ស្វាយជ្រំ ស្រុក ខេត្ត ស្វាយរៀង ។ មាតាបិតានៃព្រះមុនីកោសល មានរបរអាជីវៈខាងកសិកម្មថ្នាក់មធ្យម ។ ទារក សួរ-ហាយ កើតនៅថ្ងៃព្រហស្បតិ៍ ៨ កើត ខែពិសាខ ឆ្នាំរោងឆស័ក ព.ស. ២៤៤៨ គ.ស. ១៩០៤ មានបងប្អូន ៦ នាក់ គឺស្រី ៤ នាក់ ប្រុស ២ នាក់ ។

ស្រី ៤ នាក់នោះគឺ ១– សួរ-នួន ២- សួរ-យួន ៣ សួរ-ថៅ ៤– សួរ ឡុត ។ ប្រុស ២ នាក់គឺ ១– សួរ ហុង, ២– សួរ-ហាយ ។ ទារក សួរ-ហាយ ជាកូនពៅរបស់មាតាបិតា ដែលបានទទួលការសង្គ្រោះថ្នាក់ថ្នមអំពីមាតាបិតាជានិច្ចទាំងអស់ ។

### ២- កុមារបរិច្ឆេទ កំណត់អំពីកាលនៅជាកុមារ ។

កុមារ សួរ-ហាយ មានអាយុ១០ឆ្នាំ ទើបមាតាបិតាបាននាំយកទៅឲ្យសិក្សាអក្សរសាស្ត្រជាតិ តាមប្រពៃណីឯវត្តបឹងពៃ ក្នុងសំណាក់លោក

គ្រូសូត្រនាម ទេព-យ៉ិន ព្រោះលោកគ្រូសូត្រ ទេព-យ៉ិន លាភាគសិក្ខា-បទៈទៅជាគ្រហស្ថ ក៏មកនៅរៀន ក្នុងសំណាក់លោកគ្រូនាយ សុខ-ហាម ទៀត លុះដល់អាយុ១៣ ឆ្នាំ បានចូលការសិក្សាអក្សរសាស្ត្របរទេសផ្ទួសម ខាងមើលបានសរសេរកើត ទើបត្រឡប់មកនៅឯផ្ទះវិញ ដើម្បីជួយបំពេញកិច្ចការបន្តិចបន្តួចរបស់មាតាបិតា តាមទំនៀមនៃត្រកូលកសិករ ។

## ៣- ពេញ្ញាបរិច្ឆេទ កំណត់អំពីបព្វជ្ជា ។

កុមារ ស្វរ-ហាយ លុះដល់អាយុ ១៧ ឆ្នាំ ក៏ត្រឡប់ទៅសិក្សាធម៌វិន័យឯវត្តបទៃវិញ ដើម្បីទីនឹងបួសជាសាមណេរ ដោយឧមន្ទលោកគ្រូចៅអធិការនាម កែវ-ទិត ជាព្រះឧបជ្ឈាយ៍ បួសក្នុងថ្ងៃ ៨កើត ខែពិសាខ ព.ស. ២៤៦៦ គ.ស. ១៩២២ លុះបានទទួលផ្នួសជាសាមណេរគោព នៅក្នុងវត្តនោះតែ ១ វស្សា ក៏សូមលាព្រះឧបជ្ឈាយ៍ចេញអំពីវត្តបទៃ មកនៅរៀនវេទ្ទញាមស្រូត តាមសម័យនោះឯវត្តបរីសាគរ កំពង់ត្របែក បានចំនួន ៤ ខែ រួចចេញពីវត្តបរីសាគរ មកនៅរៀនវត្តព្រៃកងាម ក្នុងស្រុកកាមុក ខេត្តព្រៃវែង ក្នុងសំណាក់លោកគ្រូបាលីនាម មុត ។ បានរៀនប្រមូលក្បាយខៈសម្ពន្ធមូលនាម ចំនួន ៤ ខែ ក៏ចេញអំពីទីនោះមករៀនឯវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩២២ នៅក្នុងក្រុមលោកគ្រូព្រះមហា ហម-ណុន អតីតចៅអធិការវត្តឧណ្ណាលោម ។

កាលនៅសិក្សា នាវត្តឧណ្ណាលោមក្នុងសម័យនោះ រៀនប្រមូល

កច្ចាយនៈ ក្នុងសំណាក់លោកគ្រូព្រះមហា សោម-ឈុន និង លោកគ្រូអាចារ្យ ម៉ៅ-នុត នៅរៀនអស់ពីរឆ្នាំ ទើបចប់មូលកច្ចាយនៈ ។ បន្ទាប់មកកើតជម្ងឺគ្រុនចាញ់ជាខ្លាំង ត្រឡប់ទៅ ឯវត្តកំណើតដើមវិញ ដើម្បីព្យាបាលរោគគ្រុនរាំងរាង ១ ខែ ទើបជាសះស្បើយ រួចក៏ទៅនៅរៀនឯវត្តស្វាយព្រៃកូត ក្នុងសង្កាត់គោកព្រីង ស្រុក-ខេត្ត ស្វាយរៀង ក្នុងសំណាក់លោកគ្រូអាចារ្យ ខាម ទៀង បាន ១ វស្សាគត់ ក៏វិលត្រឡប់មកវត្តខ្ណារលាម ក្រុងភ្នំពេញវិញ នៅក្នុងកុដិក្នុងក្រុមដដែលដូចមុន បានសូមរៀនប្រែគម្ពីរធម្មបទដ្ឋកថាបុព្វភាគ ក្នុងសំណាក់ លោកគ្រូព្រះមហាសោម-ឈុន និងលោកគ្រូអាចារ្យ ម៉ៅ នុត ដរាបដល់អាយុ ២១ ឆ្នាំ ទើបត្រឡប់ទៅបំពេញឧបសម្បទា ជាភិក្ខុ ឯវត្តបឹងរ៉ៃ ជាវត្តដើមកំណើតរបស់ខ្លួនវិញ ។ សាមណេរ សួរ-ហាយ ជាបព្វជិតមានចិត្តស្វះស្វែងហើយមកនៅដល់ក្រុងភ្នំពេញ ព្រោះសម័យនោះ ពុំមានសាមណេរណាមួយនៃខេត្តស្វាយរៀងមកនៅវត្តខ្ណារលាម ក្រុងភ្នំពេញទេ ។ ជីវិតក្នុងការព្យាយាមនៃសាមណេរ សួរ-ហាយ ឃើញថាវិលវល់អណ្តែតអណ្តូកកំសត់រកាសរដែរ ទំពាំងឯងបានស្រួល ត្រូវក្រាបផ្កាត់ សាបុះសាឡើងអស់ប្រើឡើងត្រឡប់ ។

## ៤- ឧបសម្បទាបរិច្ឆេទ កំណត់អំពីឧបសម្បទា ។

មុនឧបសម្បទា សាមណេរ សួរ-ហាយ មានជម្ងឺឫសដូងបាត

នៅពេលនោះ បានលាព្រះឧបជ្ឈាយ៍ចាកសិក្ខាបទទៅជាគ្រហស្ថ ដើម្បីព្យាបាលរោគបួសដូងបាត ក្នុងសំណាក់គ្រូម៉ា នៅភូមិដំណាក់កន្ទួត ក្នុងសង្កាត់ស្វាយយារ ចំនួន ១ខែ លុះជាសះស្បើយចាករោគនោះហើយទើបមកសូមឧបសម្បទាឯវត្តបឹងវ៉ា ក្នុងថ្ងៃ ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ សប្តស័ក ព.ស. ២៤៦៩ គ.ស. ១៩២៥ មានលោកគ្រូចៅអធិការ កែវ-ទិត ជាព្រះឧបជ្ឈាយ៍ លោកគ្រូសូត្រ សុខ ហែម និង លោកគ្រូសូត្រ ជួន-ស៊ិន ជាព្រះឧបសម្បទាចារ្យ លុះបានទទួលឧបសម្បទាជាភិក្ខុហើយ កំត្រឡប់វិលមករៀនឯវត្តឧណ្ណាលោមវិញ នៅក្នុងកុដិក្រុមជដែល ។

## ៤– សិក្ខាបរិច្ឆេទ កំណត់អំពីការសិក្សា ។

ភិក្ខុ ស្វរ-ហាយ បានសិក្សាព្រះបរិយត្តិធម៌ជាប់មាំមួនដោយមានសុខភាពបរិបូណ៌ តាំងអំពីកាលដែលបានទទួលឧបសម្បទាជាភិក្ខុមក លុះដល់ គ.ស. ១៩២៧ បានទៅរៀនឯវត្តជយនារីចុងកោះសំរោង ខេត្តកំពង់ចាម អស់ ១ វស្សា ក្នុងសំណាក់លោកគ្រូអាចារ្យនាម ប៉ែន-សុខ សព្វថ្ងៃលោកមានសមណសក្តិ ជាព្រះបិដកសោភ័ណ “ រាជាគណៈពិសេស ” ។

ការសិក្សាព្រះបរិយត្តិធម៌ក្នុងសម័យនោះ នៅជារបៀបទម្រង់ចាស់នៅឡើយ ពុទ្ធិកវិទ្យាល័យក្នុងជំនាន់នោះហៅថា សាលាបាលីជាន់ខ្ពស់ មានព្រះតេជព្រះគុណ ព្រះមហាវិមលធម្មព្រះនាម ថោង ជាចាងហ្វាង

មានលោកគ្រូបង្រៀនប្រចាំថ្នាក់ច្រើនរូប មានសម្តេចព្រះសង្ឃរាជជាដើម កាលនៅជាព្រះគ្រូសង្ឃសត្ថា ។ ការសិក្សានៅសម័យនោះ មានកម្មវិធីសិក្សាមិនច្រើនល្អិតហ្មត់ចត់ដូចសម័យសព្វថ្ងៃនេះទេ ។ កាលបើបេក្ខ-សមណៈប្រឡងប្រដែងចូលជាប់ ត្រូវរៀនតាមកំណត់ច្បាប់សាលា ក្នុងសម័យនោះអស់ប្រាំឆ្នាំទើបប្រឡងចេញ ។ ភិក្ខុ សូរ-ហាយ ជាបេក្ខ-សមណ មួយរូប បានចូលប្រឡងប្រដែងក្នុងឆ្នាំ ១៩២៩ បានជាប់ជាសិស្សសុទ្ធ ពីព្រោះកាលនោះ រាជការកំណត់សិស្សប្រឡងជាប់តែចំនួន ២៥ រូបប៉ុណ្ណោះ ហើយបន្ថែមសិស្សស្តាប់ ៥ រូបទៀត ។

ការសិក្សាព្រះបរិយត្តិធម៌នៃភិក្ខុ សូរ-ហាយ មានជោគជ័យល្អគួរសមដែរ គឺថាចេះតែមានសុខភាពបរិបូណ៌ ពុំដែលមានជម្ងឺកាត់អ្វីឡើយ រហូតដល់ឆ្នាំ ១៩៣៣ ទើបប្រឡងចេញ ។ តាមលេខរៀងនៃលោកអ្នកប្រឡងជាប់បានពិន្ទុគ្រប់វិញ្ញាសានៃការប្រឡងនោះ ភិក្ខុ សូរ-ហាយ បានជាប់លេខ ៣ ។

លុះភិក្ខុ សូរ-ហាយ បានប្រឡងចេញជាប់ហើយ សម្តេចព្រះសង្ឃរាជ កាលព្រះអង្គនៅជាព្រះសាសនសោភ័ណ បានចាត់ឲ្យទៅធ្វើអាចារ្យបង្រៀនសាលាបាលីរង ឯវត្តបរិវាស សង្កាត់សំពង់ ស្រុកបន្ទាយមាស ខេត្តកំពត អស់ ៥ ខែ គឺតាំងពីខែជេស្ឋ រហូតដល់រនោចនៃខែអស្សុជ ក៏ត្រឡប់មកវត្តឧណ្ណាលោម ក្រុងភ្នំពេញវិញ ដោយពុទ្ធសាសនបណ្ឌិត្យ

គម្រោងមិនទាន់មកធ្វើជាក្រុមជំនុំព្រះត្រៃបិដក ក្នុងខែតុលា ១៩៣៧ ពីព្រោះ បានប្រឡងជាប់ជាក្រុមជំនុំព្រះត្រៃបិដកនោះ តាំងពីខែកញ្ញា ប៉ុន្តែពេលនោះនៅក្នុងស្រុកនៅឡើយ លុះបវារណាចេញវស្សាហើយ ទើបមកភ្នំពេញ ចូលធ្វើការក្នុងក្រុមជំនុំព្រះត្រៃបិដកតាំងពីកាលណោះដរាបមក ។

៦ ឋានន្តរបរិច្ឆេទ កំណត់អំពីការទទួលឋានន្តរស័ក្តិ ។

ភិក្ខុមហា ស៊ូរ.បាយ បានទទួលនាទីជាព្រះបាឡាត់ពុទ្ធញាណជាបាឡាត់នៃព្រះពុទ្ធវង្ស សោម ឈុន ក្នុង ព.ស. ២៤៨១ គ.ស. ១៩៣៧ ។

—បានទទួលន.ទីជាព្រះគ្រូឃុំឡញាណ ក្នុង គ.ស. ១៩៤២ ។

—បានទទួលនាទីជាព្រះទេពសត្ថា ជាគណៈថ្នាក់ទី ៤ ដោយព្រះរាជក្រឹត្យលេខ ៩៣ ប.រ. ចុះថ្ងៃទី ២៦ មេសា ឆ្នាំ ១៩៤៨ ។

—បានទទួលនាទីជាព្រះបាលិវង្ស ជាគណៈថ្នាក់ទី ៣ ដោយព្រះរាជក្រឹត្យលេខ ៥ ប.រ. ចុះថ្ងៃ ២១ ខែមករា ឆ្នាំ ១៩៥៤ ។

—បានទទួលនាទីជាព្រះមុនីកោសល ជាគណៈថ្នាក់ទី ២ ដោយព្រះរាជក្រឹត្យលេខ ២៣ ព.រ. ចុះថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ១៩៦០ ។

—បានចូលជាសមាជិកនៃគណៈកម្មការវប្បធម៌ខ្មែរ ដោយព្រះរាជ-ក្រមលេខ ៣៩៣ ន.ស. ចុះថ្ងៃទី ២១ វិច្ឆិកា ឆ្នាំ ១៩៤៧ ។

—បានចូលជាសមាជិកថេរសភា ដោយព្រះរាជក្រឹត្យលេខ ១១១៣ ប.រ. ចុះថ្ងៃទី៩ កញ្ញា ឆ្នាំ ១៩៥៨ ។

-បានទទួលនាទីជាអធិបតីរង នៃក្រុមជំនុំព្រះត្រៃបិដក ដោយព្រះសង្ឃដីកានៃសម្ដេចព្រះពោធិវង្ស លេខ ១៨៥ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ១៩៥៩ ។

-បានទទួលនាទីជាចៅអធិការ វត្តទិពោធិវង្ស ដោយសញ្ញាប័ត្រ លេខ ៣ ៩៧ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ១៩៦១ ។

៧- ពុទ្ធវិវិធប្រវេណី កំណត់ការធ្វើសេចក្ដីចម្រើនក្នុងព្រះពុទ្ធសាសនា ។

ព្រះមុនី កោសល ស្វរ-ហាយ បានធ្វើមប្រយោជន៍នៃការប្រឡងសមណសិស្ស យកវិញ្ញាបនប័ត្រពុទ្ធិកបឋមសិក្សា, សមណសិស្សប្រឡងចូលពុទ្ធិកវិទ្យាល័យ ព្រមទាំងសមណសិស្ស ប្រឡងយកសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សាជៀងរាល់ឆ្នាំ តាំងពី ព.ស. ២៤៧៨ គ.ស. ១៩៣៤ ដរាបមកដល់សព្វថ្ងៃនេះ ។

-បានធ្វើជាសាស្ត្រាចារ្យបង្រៀនសាលាបាលីរង វត្តបរិពស ស្រុកបន្ទាយមាស ខេត្តកំពត ពីឆ្នាំ ១៩៣៣ ។

-បានប្រឡងជាប់ជាក្រុមជំនុំត្រៃបិដកពីឆ្នាំ ១៩៣៣ ។

-បានធ្វើជាប្រធានគណៈកម្មការសង្ឃ វត្តខណ្ឌលោម ជាជំនួស ក្រោមព្រះរាជអាជ្ញាកាពនៃសម្ដេចព្រះសង្ឃរាជ ។

-បានធ្វើជាសាស្ត្រាចារ្យបង្រៀនសមណសិស្សវត្តខណ្ឌលោម ដែលបម្រុងប្រឡងប្រណាំងចូលរៀនក្នុងពុទ្ធិកវិទ្យាល័យ ។

-បានធ្វើជាសមាជិកគណៈកម្មការរៀបរៀងធម៌វិន័យ ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះសង្ឃរាជ ។

-បានធ្វើជាសមាជិកគណៈប្រតិភូជាមួយនឹងសម្តេចព្រះសង្ឃរាជទៅក្រុងរង្គូន ប្រទេសភូមា ដើម្បីធ្វើឆដ្ឋសង្គាយនាពុទ្ធសាសនាពីឆ្នាំ ១៩៥៤ ។

-បានធ្វើជាប្រធានគណៈកម្មការ ពិនិត្យអត្ថបទធម៌ បោះពុម្ពចែកជាធម្មទានក្នុងឱកាសបុណ្យធំជន្មាយុពុទ្ធសាសនា ២៥០០ វស្សា ។

-បានចូលជា ជនសមាជិក នៃពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ តាំងពីការបង្កើតជាដំបូងដរាបមក ។

-បានធ្វើជាសមាជិកតែងអត្ថបទបោះពុម្ពជាក់ក្នុងទស្សនាវដ្តី កម្ពុជសុរិយា និង ពន្លឺពុទ្ធចក្រ ។

-បានធ្វើសន្និសីទអំពីសីលធម៌អប់រំយុវជន វត្តទណ្ណលោម ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃរាជ ។

-បានចូលជាសមាជិកនៃសមាគមតិលានុបដ្ឋានព្រះមហាក្សត្រិយានី "ពេទ្យព្រះសង្ឃ" ។

-បានធ្វើកឋិនទាន ដង្ហែទៅវត្តបឹងរៃ ១១ ដង គឺតាំងពីឆ្នាំ ១៩៥៧ រហូតដល់ឆ្នាំ ១៩៦៧ ។

-បានធ្វើកឋិនទានដង្ហែទៅវត្តឈើទាល ស្រុកស្វាយទៀបពីរដង ។

-បានធ្វើកឋិនទានជាមួយពុទ្ធបរិស័ទ ដង្ហែទៅវត្តសិរីសាគរ កំពង់ត្របែកម្ពង ។

- បានចូលជាសមាជិកសមាគមមិត្តពុទ្ធិកវិទ្យាល័យ តាំងពីដំបូង ។

- បានចូលជាសមាជិកនៃសមាគម មតកសង្គ្រោះក្នុងក្រុមពុទ្ធបរិស័ទ សាលាសន្សំសុខ សង្កាត់លេខ១៥ ក្រុងភ្នំពេញ ។

## ឈ្មោះសៀវភៅធម៌ដែលព្រះមុនីកោសលបានរៀបរៀង

១- វិសុទ្ធិកថា

២. បទពិចារណាពុទ្ធាភិសេក

៣- បទពិចារណាធម៌វិន័យ

៤- អធិប្បាយប្រជុំកង់ធម៌ ភាគ១ ភាគ២ ថ្នាក់ទោ

៥- អធិប្បាយចតុប្បារិសុទ្ធិសីល

៦- ពុទ្ធបារមីកថា

៧- គិហិសមណសុខកថា

៨- ទានសកម្មកថា

៩- កាលិកវិនយកថា

១០- សីលធម៌របស់មនុស្ស

១១- សាមគ្គីកថា

១២- សិប្បកថា

១៣- អរិយសច្ចកថាសង្ខេប

១៤- ពុទ្ធោវាទកថា

១៥- ជីវិតធម្មកថា

១៦- កតញ្ញូកតវេទិកថា

១៧- ព្រហ្មវិហារធម្មកថា

១៨- សាសនាប្រៀបធៀប ។

អត្ថបទធម៌ភាសាផ្សេងៗ ដែលបោះពុម្ពក្នុងទស្សនាវដ្ដីកម្ពុជសុរិយានិង ពន្លឺពុទ្ធចក្រ ក៏មានច្រើន ស្ទើរតែគ្រប់សៀវភៅ ។

៨-សេវាសង្គមបរិច្ចេទ កំណត់អំពីការកសាងសេវាសង្គមប្រយោជន៍ ទុកបម្រើជាតិ, ព្រះពុទ្ធសាសនា ។

ព្រះមុនីកោសល ស៊ូរ-ប៉ាយ បានបបួលសិស្សគណកសាងកុដិ ១ ខ្នង មានពីរជាន់ ដោយគ្រឿងបេតុងអារម៉េ ក្នុងវត្តឧណ្ណាលោមជាកុដិលេខ ៣៨ មានបណ្ដោយ ១៨ ម. ទទឹង ៨ ម. ពី គ.ស. ១៩៥៦ អស់បច្ច័យផ្ទាល់ខ្លួនចំនួន ៣០ ម៉ឺនរៀល បច្ច័យសិស្សគណ, ពុទ្ធបរិស័ទ ចំនួន ៤៦ ម៉ឺនរៀល បូករួមជា ៥៦០ ០០០៛០០ ។

-បានជួយទំនុកបម្រុងកសាងសាលាបឋមសិក្សា សង្កាត់ក្រោលគោ តាំងពីឆ្នាំ ១៩៤៧ មក អស់ចំនួន ៣០.០០០៛០០ ។

-បានចូលកសាងមហាកុដិ វត្តឧណ្ណាលោម សម្រាប់សម្ដេចព្រះសង្ឃរាជគង់នៅ អស់ចំនួន ១០ ០០០៛០០ ។

-បានចូលកសាងវិហារវត្តឧណ្ណាលោម អស់ចំនួន ១៥.០០០៛០០ ។

-បានចូលកសាងវិហារវត្តព្រៃគុម្ព ខេត្តកំពត ជាមួយនិងលោកវរៈសេនីយឯក ស្រី-សាម៉ន ចំនួន ៦.០០០៛០០ ។

-បានកសាងឧបដ្ឋានសាលាវត្តបឹងរៃ ជាវត្តកើតដំណែល (ស្វាយ-រៀង) ១ ខ្នងដោយគ្រឿងបេតុងអារមេ ជាមួយនិងពុទ្ធបរិស័ទជើងវត្ត អស់បច្ច័យផ្ទាល់ខ្លួនចំនួនជាង ២០០.០០០៛ (២០ម៉ឺន) ។

-បានជួយកសាងកុដិ ១ ខ្នង មាន ២ ជាន់ សម្រាប់លោកគ្រូចៅអធិការវត្តបឹងរៃ អស់បច្ច័យចំនួន ៣០.០០០៛០០ ។

-បានចាប់កសាងវិហារវត្តបឹងរៃ ជាមួយនិងពុទ្ធបរិស័ទជើងវត្ត ពីឆ្នាំ ១៩៦៦ អស់បច្ច័យផ្ទាល់ខ្លួនរួចហើយចំនួន ១៥០.០០០៛០០ ។ ប៉ុន្តែវិហារនោះពុំទាន់ហើយនៅឡើយ ជិតរួចដែរហើយ ។

-បានចូលជួយកសាងអនុវិទ្យាល័យ ស្វាយជ្រំ ស្រុកខេត្តស្វាយរៀង ក្នុង ១ ឆ្នាំចំនួន ២ ពាន់រៀល ឥឡូវនេះបាន ៤ ឆ្នាំហើយ ត្រូវជា ៨ ពាន់រៀល សន្យាថានឹងចូលជួយជាប់ដល់តែហើយស្រេចទើបឈប់អស់ចំនួនបច្ច័យ ១៥.០០០៛០០ ។ ស្វាយជ្រំនេះជាលំនៅជាតិភូមិនៃញោមប្រុស ។

-បានចូលជួយកសាងមន្ទីរពេទ្យព្រះសង្ឃនៅទីក្រុងស្វាយរៀងអស់បច្ច័យចំនួន ៤.១០០៛០០ ។ ចូលជួយកសាងវត្តសាមគ្គីរង្សី ៣៧០០៛០០ ។

-បានដឹកនាំលោកអ្នកឧកញ៉ា ឧត្តមភោគី លឹម-ហួត ឲ្យកសាងកិលានដ្ឋាន និងផ្សារក្រោលគោ ស្រុកស្វាយរៀង ហើយបាន

ក៏បង្កើនខាងសម្ភារៈផ្សេងៗ មានគ្រែ តុ ជាដើមសម្រាប់គិលានដ្ឋាន នៃលោកអ្នកឧកញ៉ា ឧត្តមភោគី អស់ចំនួន ៤៥.១០០ រៀល ។

-បានបរិច្ចាគបច្ច័យប្រចាំខែ ៩០០ រៀល សម្រាប់បំពាក់ភិក្ខុសាមណេរនិងក្មេងនៅក្នុងកុដិលេខ ៣៨ ក្នុងវត្តឧណ្ណាលោម តាំងពីឆ្នាំ ១៩៦៣ ដែលលោកមកគង់នៅឯវត្តនិគ្រោធវង្ស ដល់មកឆ្នាំ ១៩៦៦ បន្ថយមកវិញនៅតែ ៧៥០ រៀលវិញ ព្រោះភិក្ខុសាមណេរនិងក្មេងក្នុងកុដិនោះ ក៏មានចំនួនតិចជាងមុនដែរ ។

-បានជំនុំផ្តើមកសាងអនុវិទ្យាល័យស្តីសម្តេច៥ នៅជិតវត្តព្រែកឯង ស្រុកកៀនស្វាយ ហើយបានចូលបច្ច័យក្នុង ១ ឆ្នាំ ១០០០ រៀលៗ ដរាបដល់តែហើយស្រេច ឥឡូវនេះបានចូលអស់បីឆ្នាំហើយ ព្រមទាំងបច្ច័យជាភោគទាន ដែលកើតអំពីធម្មទេសនាជាច្រើនដង រួចចូលបន្ថែមទៀតត្រូវជាប្រាក់ ៤០០០ រៀលហើយ ។

-បានកសាងកុដិឈើប្រក់ក្បឿង ១ ខ្នងអស់បច្ច័យ ៥០.០០០៛០០ (៥ ម៉ឺនរៀល) ក្នុងវត្តនិគ្រោធវង្ស ។

-បានកសាងបង្ហើយវិហារវត្តនិគ្រោធវង្ស ដោយបច្ច័យនៃពុទ្ធបរិស័ទអ្នកជាប់ជ្រះថ្លា មានលោកជំទាវ ឧត្តមសេនីយ លន់-ណុល ជាដើមអស់បច្ច័យចំនួន ២៥ ម៉ឺនរៀល (២៥០.០០០៛០០) ។

-បានកសាងកុដិឈើ ១ ខ្នង នៅវត្តបុស្សីស្រស់ សម្រាប់លោក

អាចារ្យបង្រៀនពុទ្ធិកបឋមសិក្សា អស់បច្ច័យចំនួន ៤ ម៉ឺន ៨ ពាន់ហាសិបរៀល (៤០.៨៥០រ០០) ។

-បានចូលកសាងអនុវិទ្យាល័យ កំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ក្នុងមួយឆ្នាំ ១០០០រ០០ សន្យាថា ចូល ១០០០រ០០ ក្នុងមួយឆ្នាំ ដកបតាល់តែហើយស្រេច ។

-បានជួលគេជីកអណ្តូង ១ ក្នុងវត្តនិរោធរង្សី អស់បច្ច័យចំនួន ៦.០០០ រៀល ។

ព្រះមុនីកោសល បានទាក់ទងនឹងគេហបតី លី ប៊ុន រួចក៏គេហបតីបានកសាងបណ្ណាល័យ ១ ខ្នង សម្រាប់តម្កល់គម្ពីរក្នុងវត្តនិរោធរង្សី អស់បច្ច័យ ៤០០.០០០រ០០០ ។

-បានចូលជួយទិញស៊ីម៉ង់, ឥដ្ឋ, ក្រួស, ខ្សាច់ ធ្វើឧបដ្ឋានសាលាវត្តនិរោធរង្សីអស់បច្ច័យចំនួន ៣០.០០០រ០០ ។

-បានទិញក្រួសក្រហមសម្រាប់ក្រាលជុំវិញវិហារវត្តនិរោធរង្សី អស់បច្ច័យចំនួន៣៤.០០០ រៀល តែពុំទាន់ហើយទេ នៅពុំទាន់ដឹងថាអស់ប៉ុន្មានទៀតទេ ដែលជួលកម្មករប្រចាំខែឲ្យគាប់គាស់ស្មៅ ព្រមទាំងក្រាលក្រួសក្រហមនោះ ។

៩ ឥស្សរិយយសនៃព្រះមុនីកោសល

១ មេដាយ អស្សរិទ្ធិមុនីសារភ័ណ្ឌ ដោយគុណបំណាច់នៃការប្រែព្រះត្រៃបិដក បោះពុម្ពព្រះត្រៃបិដក ។

២- មេដាយព្រះរាជាណាចក្រជាទីសេនា (Officier de l'ordre royale du comboge) ដោយគុណបំណាច់នៃការសាធារណការ ដោយគុណបំណាច់នៃការសាធិតលានដ្ឋាន និង អនុវិទ្យាល័យ ។

៣- មេដាយស្ពាបនាជាតិ ៣ ទៀត ដោយចេញតម្លៃមួយៗ ៣៥០ រៀល ។

ចប់ ជីវប្រវត្តិតែប៉ុណ្ណេះ ។

# ទស្សនៈនៃខ្ញុំក្នុងជីវប្រវត្តិនេះ

ខ្ញុំករុណា ខ្ញុំបាទ "ភ្លួច គឹមឡេង" ជាសិស្សនៃព្រះតេជព្រះគុណ ព្រះមុនីកោសល សូមរៀបរាប់នៃកម្រងជីវប្រវត្តិ នៃព្រះតេជព្រះគុណអង្គនេះ តាមទស្សនៈ (ការយល់ឃើញ) របស់ខ្ញុំដោយឡែកទៀត ដូចតទៅនេះ ៖

ខ្ញុំករុណា ខ្ញុំបាទ កាលនៅជាបព្វជិត កំពុងរៀបចំដំណើរទៅរៀនឯប្រទេសឥណ្ឌា ដោយសម្តេចព្រះសង្ឃរាជជ្រើសរើសរកលោក ដែលប្រឡងចេញពីសាលាបាលីជាន់ខ្ពស់ថ្មីៗ មានសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា ហើយ ឲ្យរៀនអក្សរអង់គ្លេស ដើម្បីអប់រំឲ្យចេះដឹងគួរសម នឹងបញ្ជូនទៅរៀនប្រទេសឥណ្ឌា ។ ក្នុងសម័យនោះ សម្តេចព្រះសង្ឃរាជ ខ្នះខ្នែងតាក់តែងខ្លាំងណាស់ ដោយព្រះរាជហឫទ័យចង់ឲ្យសមណនិស្សិតជាតិខ្មែរ បានទៅរៀនប្រទេសឥណ្ឌា ទ្រង់បានធ្វើព្រះសង្ឃដីកាតាក់តែង និង ព្រះរាជរដ្ឋាភិបាល ព្រមទាំងទូតឥណ្ឌា ទាល់តែបានសម្រេចសព្វគ្រប់ ដូចបំណង ។

ក្នុងដំណើរចេញទៅប្រទេសឥណ្ឌា ជាលើកដំបូងបង្អស់នោះ ត្រូវលើខ្ញុំករុណា ខ្ញុំបាទ និងព្រះមហា ឆាយ-ភន ជាសិស្សនៃព្រះតេជព្រះគុណព្រះមុនីកោសល ព្រោះកាលណោះ លោកដែលបានប្រឡងចេញថ្មីៗ មានសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សានៃសាលាបាលីជាន់ខ្ពស់ ជាសិស្សនៃព្រះមុនីកោសលនោះមាន ៤ អង្គ សុទ្ធតែនៅក្នុងសំណាក់

កុដិ លេខ ៣៨ ជាមួយគ្នា ជាសិស្សនៃព្រះមុនីកោសល ឃើញថាកុដិនេះ មានលេខរៀង ៣៨ ត្រូវគ្នានឹងមង្គល ៣៨ ប្រការ ព្រោះហេតុដូច្នេះទើបនឹង បានជាកុដិនេះមានជោគជ័យសិរីមង្គលគ្រប់បែប ទាំងពួកក្មេងកូនកុដិនេះ ដែលរៀនអក្សរសាស្ត្រជាតិកូនសាលាខាងអាណាចក្រ ក៏បានការច្រើន នាក់ដែរ ។ លុះដល់សម្តេចព្រះសង្ឃរាជ ជ្រើសរើសគេសមណនិស្សិត ដើម្បីឲ្យទៅប្រទេសឥណ្ឌានោះ រើសបានទាំង ៤ អង្គ គឺ ១- ខ្ញុំករុណា ខ្ញុំបាទ "គួច.គីឡេង", ២- មហា ចាយ-ជន, ៣- មហា អ៊ុង-មាន ៤- មហា សោម ឯន ។ ប៉ុន្តែនៅសម័យនោះ លោកដែលបានទៅឥណ្ឌា លើកដំបូងនោះតែពីររូបសិន គឺ គួច-គីឡេង ១, ចាយ-ជន ១, ក្រៅពីនេះចាំទៅលើកក្រោយទៀត ។

នៅឱកាសដ៏ខ្លីមុនពេលចេញដំណើរទៅប្រទេសឥណ្ឌា ៣ ថ្ងៃ ព្រះតេជព្រះគុណព្រះមុនីកោសល បានឲ្យឱវាទជាខ្លឹមសារល្អៗណាស់ ព្រមទាំងឲ្យពរចំពោះខ្ញុំករុណា ខ្ញុំបាទ ជាសិស្សកាលនៅជាបព្វជិត ជាពិសេសត្រង់ឱវាទខាងចុងថា : «លោក កាលបើបានរៀនវិជ្ជាណាមួយសម្រេចហើយ ត្រឡប់មកប្រទេសយើងវិញ លោកកុំសឹក លោកត្រូវប្រើគំនិតឲ្យវែងឆ្ងាយ កុំបណ្តោយគំនិតឲ្យគិតខុសគិតខ្លី គួរនៅជាបព្វជិតបម្រើព្រះពុទ្ធសាសនា ទើបប្រសើរជាងការបម្រើកាមគុណ ព្រោះថាគ្រហស្ថអ្នកបម្រើកាមគុណមានច្រើននាក់ណាស់ហើយ មិនខ្វះទេ» ប៉ុណ្ណោះជាដើមៗ

ការវែកញែកក្នុងជីវប្រវត្តិនៃព្រះតេជព្រះគុណ ព្រះមុនីកោសលអគ្គ នេះ ឃើញថាមានស្នាមគំនូសល្អច្រើនណាស់ ដូចយ៉ាងការគ្រប់គ្រងកិច្ចសាមណេរនិងពួកក្មេងអ្នករៀនក្តី ការឧបត្ថម្ភចិញ្ចឹម ដោយស្បៀងអាហារក្តី សុទ្ធតែប្រព្រឹត្តទៅដោយស្រួលល្អទាំងអស់ គឺថាព្រះថេរៈអង្គនេះមានហឫទ័យបង្គួរទូលាយ ទទួលដឹងសុខទុក្ខរបស់សិស្សគណដោយសេចក្តីស្រឡាញ់រាប់អានស្មើល្អណាស់ ជាព្រះថេរៈប្រកបដោយការឈ្លាសវៃប៉ិនប្រសប់ដោយការស្គាល់យល់ចរិតអធ្យាស្រ័យរបស់សិស្សគណ ៗ

ក្នុងកាលដែលខ្ញុំករុណា ខ្ញុំបាទ នៅកំពុងរៀនសូត្រឯប្រទេសឥណ្ឌា ព្រះតេជព្រះគុណអង្គនេះ បានផ្ញើស្បង់ចីវរបច្ច័យទៅឲ្យជារឿយ ៗ ជាពិសេសគ្រង់សំបុត្រស្នាមសួរសុខទុក្ខចំពោះខ្ញុំករុណា ខ្ញុំបាទ គំលោកផ្ញើទៅជាញឹកញយ ហើយច្រើនតែដាស់តឿនឲ្យយកចិត្តទុកដាក់ក្នុងការរៀន ទាំងទូន្មានរំលឹកប្រាប់ហេតុផលថា លោក ខំតែរៀនឲ្យមែនទែនទៅចុះ ខ្ញុំនៅឯណេះនឹងធ្វើកុដិបម្រុងទុកឲ្យលោកនៅ លុះធ្វើកុដិរួចហើយ ខ្ញុំនឹងធ្វើគ្រែដេកឲ្យមានកន្ទេលខ្នើយមុងទុកបម្រុងឲ្យលោកសព្វគ្រប់ ៗ លុះខ្ញុំករុណា ខ្ញុំបាទវិលត្រឡប់អំពីប្រទេសឥណ្ឌាមកវិញ ក៏មានកុដិថ្មី គ្រែ កន្ទេល ខ្នើយ មុងថ្មីៗ រៀបឲ្យពិតប្រាកដមែន ៗ ព្រះថេរៈអង្គនេះដឹងសុខទុក្ខនិងករណីយកិច្ចរបស់សិស្សគណដោយពិត សមគួរដល់ឋានៈជាគ្រូអាចារ្យរបស់ខ្ញុំករុណា ខ្ញុំបាទគ្រប់ភាគរយឥតខ្វះចន្លោះឡើយ ៗ

ក្នុងការស្ថាបនានូវសំណង់សេនាសនៈ សម្រាប់ជ្រកកោននៅអាស្រ័យ ទុកបម្រើជាតិ សាសនា នោះឃើញថា ព្រះតេជព្រះគុណអង្គនេះ ផ្តួចផ្តើមកសាងបានច្រើនណាស់ អស់ប្រាក់ពប់លានរៀល ដូចក្នុងជីវប្រវត្តិ ត្រង់បរិច្ឆេទទី ៨ ស្រាប់ គួរឲ្យកោតសរសើរក្រៃលែង គួរជាទិដ្ឋានុគតិ យកជាគម្រាប់បាននៃបុគ្គលអ្នកត្រូវការពហានទៅមុខ ដើម្បីសេចក្តីចំរើន លូតលាស់របស់ប្រទេសជាតិ សាសនា ជាពិតប្រាកដ ។ ជីវិតនៃព្រះតេជព្រះគុណអង្គនេះ ពាក់ទងដោយបេសកកម្ម មានប្រយោជន៍ទាំងខាងផ្លូវលោក ទាំងខាងផ្លូវសាសនា ឈ្មោះថាជាជីវិតទទួលបម្រើដោយគោរព ឥតសំចៃ ឥតលាក់លៀមចំពោះជាតិសាសនា និង ព្រះរាជបល្ល័ង្ក ដើម្បីវឌ្ឍនភាពជាស្ថាពរ យូរអង្វែងតទៅអនាគត ។

អ្នកតែងសេចក្តីជីវប្រវត្តិ និង ទស្សនៈនៃខ្ញុំ "ក្លួច គីឡេង"

មហា ក្លួច-គីឡេង

មហា អ៊ុង-យាន

# សុន្ទរកថា

នៃភិក្ខុមហា ម៉ា-សុន្ទរ ថ្លែងក្នុងឱកាសបុណ្យចំរើនជន្មាយុ
នៃព្រះមុនីកោសល សួរ-ហាយ ថ្ងៃទី ១៨-១៩ កុម្ភៈ ១៩៦៣

*បពិត្រសម្តេចព្រះពោធិវង្ស!*

*ព្រះករុណា ទាំងឡាយគ្រប់ព្រះអង្គ!*

*អស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយ!*

នៅឱកាសបុណ្យចំរើនជន្មាយុ នៃព្រះតេជព្រះគុណព្រះមុនីកោសល ជាចៅអធិការវត្តឧះរាជរង្សីនេះ ខ្ញុំព្រះករុណា អាត្មាភាព ក្នុងនាមនៃគណៈកម្មការសមាគមវត្ត មានលោកតំណាងរាស្ត្រ តាន់ ឈាងលឹម ជាដើម ក្នុងនាមនៃពុទ្ធបរិស័ទជើងវត្តមានលោកអាចារ្យវត្តជាដើម សូមប្រកាសទទួលអំណរអរសប្បាយក្រៃលែង ចំពោះសម្តេច ដែលមានព្រះហឫទ័យទទួលនិមន្តមកប្រទានធម្មទេសនា ទាំងសម្តេចព្រះសង្ឃរាជ ក៏ទ្រង់ព្រះមេត្តាប្រោសទទួលយាងជាព្រះរាជាធិបតី ស្រោចស្រង់ទឹកសុគន្ធ-វារីក្នុងថ្ងៃស្អែកដែរ ដើម្បីសុភមង្គលដល់ព្រះតេជព្រះគុណព្រះមុនីកោ-សលផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង ចំពោះព្រះករុណាគ្រប់ព្រះអង្គមានព្រះតេជព្រះគុណមេគណ ខេត្តកណ្តាលជាដើម និងអស់លោកអ្នកសប្បុរសទាំងឡាយ ដែលបាននិមន្ត អញ្ជើញមកជួយបំពេញកិច្ចអនុ-មោទនាបុណ្យ ជួយលើកកិត្តិយសនៃបុណ្យកុសលចំរើនជន្មាយុ នៃព្រះ

តេជព្រះគុណព្រះមុនីកោសលនេះ នាំឲ្យខ្ញុំព្រះករុណា អាត្មាភាព មាន បីតិសោមនស្ស រីករាយចិត្តអស្ចារ្យណាស់ ។

ខ្ញុំព្រះករុណា អាត្មាភាព ជាតំណាងនាមនៃពុទ្ធបរិស័ទអ្នកផ្តើមបុណ្យ ដែលព្រមព្រៀងគ្នាជាមួយគ្នានិងសិស្សគណ ញាតិមិត្តសាលោហិតរបស់ ព្រះតេជព្រះគុណព្រះមុនីកោសល ខ្ញុំព្រះករុណា អាត្មាភាព សូមធ្វៀត ឱកាសបន្តិច ដើម្បីថ្លែងសុន្ទរកថា រៀបរាប់អំពីមូលហេតុនៃបុណ្យនេះ ប្រគេនជូនជាសណ្តាប់ដោយសេចក្តីយ៉ាងខ្លីដូចតទៅនេះ :

១ តាមប្រពៃណីនិយមនៃយើងអ្នកកាន់ព្រះពុទ្ធសាសនា កាលបើ ព្រះថេរៈអង្គណាមួយ បានទទួលនាទីជាចៅអធិការ មានសញ្ញាប័ត្រតាម ផ្លូវការហើយ គេតែងនាំគ្នាធ្វើបុណ្យប្រសិទ្ធពរ ចំពោះព្រះថេរៈអង្គនោះ មានកិច្ចស្រោចស្រង់ទឹកជាដើម ចំពោះចៅអធិការថ្មី ដើម្បីឲ្យ លោកបានទទួលប្រសិទ្ធភាពអំពីផលានិសង្សបុណ្យកុសល ដែលទុកជាជា វិភាគទានមួយដ៏ប្រសើរ ។ ឥឡូវនេះព្រះមហាថេរអង្គនេះ បានទទួល ឋានៈជាចៅអធិការតាំងពីឆ្នាំ ១៩៦១ ប៉ុន្តែមកគង់ជាប់នៅវត្តនេះ ពីឆ្នាំ ១៩៦៣ បើគិតអំពីឆ្នាំដែលបានទទួលសញ្ញាប័ត្រចៅអធិការចំនួន ៦ ឆ្នាំ ហើយ ប៉ុន្តែពុទ្ធបរិស័ទ សិស្ស គណ ពុំទាន់បានធ្វើកិច្ចកុសលណាមួយ ប្រគេននៅឡើយ ។

អាស្រ័យហេតុដូចរៀបរាប់មកនេះ ទើបខ្ញុំព្រះករុណាទាំងឡាយ

បានជំនុំព្រមព្រៀងគ្នាផ្តើមធ្វើបុណ្យក្នុងឱកាសនេះ ដើម្បីជាសក្ខីភាពនៃសេចក្តីគោរពសេចក្តីជ្រះថ្លាចំពោះលោក ។ ការជំនុំអំពីបុណ្យនេះមុនដំបូងមូលមតិគ្នាជាឯកច្ឆន្ទហើយ ទើបបានចូលមកពិតលោកអំពីកិច្ចបុណ្យចំរើនជន្មាយុនេះ លោកបានឃាត់យើងពល់គ្នាអស់វារៈពីរដង ប៉ុន្តែយើងខ្ញុំចេះតែខំទូលអង្វរព្រះទ័យ ទាល់តែលោកព្រមដោយតុណ្ហីភាព ។

២– សកម្មភាពនៃព្រះតេជព្រះគុណឃើញថា មានការចំរើនលូតលាស់ក្នុងវត្តគួរសមណាស់ហើយ ដែលតាំងពីលោកមកគង់វត្តនេះ យើងខ្ញុំពុំទាន់បានបំពេញករណីយកិច្ចជាកុសល ចំពោះលោកសោះ ដើម្បីជាកិច្ចកតញ្ញូកតវេទិតា តាមប្រពៃណីដែលយើងធ្លាប់អនុវត្តមកហើយ ហៅថាបុណ្យចំរើនជន្មាយុចំពោះព្រះមហាថេរ ដែលយើងគួរគោរព ។ ព្រះតេជព្រះគុណអង្គនេះ មានសកម្មភាពល្អ ជឿនលឿនឈានទៅមុខជាដរាប ចំពោះកិច្ចស្ថាបនាទាំងកិច្ចគ្រប់គ្រងវត្តអារាម និងកិច្ចសាមណេរ ។

ក្នុងករណីដូចថ្លែងមកនេះ បណ្តាលឲ្យយើងខ្ញុំជាពុទ្ធបរិស័ទសិស្សគណ បបួលគ្នាផ្តើមធ្វើបុណ្យចំរើនព្រះជន្មាយុ ចំពោះព្រះមហាថេរអង្គនេះ ឲ្យសមគួរដល់កិត្តិយសនៃលោក ពីព្រោះកាលអំណើះព្រះតេជព្រះគុណព្រះមុនីកោសល សោម-ឈុន ដែលទទួលអនិច្ចធម្មទៅ ក្នុងកាលខាងក្រោយដែលបូជាព្រះសពរួចហើយ យើងខ្ញុំបានសូមនិមន្តធ្វើជាចៅអធិការនោះ ព្រះតេជព្រះគុណអង្គនេះ ចេះតែប្រកែកជាច្រើនដង លុះ

តែយើងខ្ញុំបបួលគ្នាទៅឯវត្តឧណ្ណាលោម ថ្វាយបង្គំគាល់សម្តេចព្រះសង្ឃ-រាជ ហាក់ដូចជាបាតុកម្ម ទ្រង់ក៏បានជួយឧបត្ថម្ភដោយព្រះឧបាយដ៏ប្រពៃ ទាល់តែបានសម្រេចដូចបំណង ។

៣ - ព្រះតេជព្រះគុណមហាថេរអង្គនេះ ដែលយើងដឹងមកថា តាំងពីលោកចូលធ្វើការនៅក្នុងក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យ ពីឆ្នាំ ១៩៣៣ ចេះតែមានសុខភាពកាយស្រួលល្អណាស់ ពុំដែលឮថា លោកមានជម្ងឺដម្កាត់ណាមួយឡើយ បើគិតអំពីឆ្នាំនោះមកដល់ឆ្នាំនេះ ៣៤ ឆ្នាំហើយ ពុំដែលឃើញថាលោកមានអាពាធ ដល់ថ្នាក់សឹងពេទ្យនោះទេ ទើបតែឥឡូវនេះ រវាងជិត ១ ឆ្នាំហើយ ស្រាប់តែមានអាពាធដំបៅមួយ គឺរោគរលាកបំពង់ក បានឲ្យគ្រូពេទ្យពិនិត្យមើលថារោគនេះ តាមពាក្យបារាំងហៅថា អ៊ុលសេរ (រោគរលាក) រាប់ថាជារោគក្រមួយដែរ បើមិនប្រញាប់ព្យាបាលមែនទែន នឹងអាចក្លាយទៅជារោគកង់សេរ "រោគមហារីក" បានដែរ ។ រោគក្នុងកាយនៃព្រះតេជព្រះគុណអង្គនេះ នាំឲ្យយើងខ្ញុំមានសេចក្តីទុក្ខព្រួយរមែងជាមួយណាស់ បានព្យាបាលដោយឱសថដ៏វិសេសច្រើនមុខអស់រវាង ៣ ខែមកហើយ ឥឡូវនេះបានធូរស្រាលគ្រាន់បើដែរហើយ ។

ហេតុការណ៍ដូចរៀបរាប់ប្រគេនជូនមកនេះ បានជាយើងខ្ញុំពុំងឹងរកមធ្យោបាយណាមួយដែលប្រសើរវិសេសជាងការព្យាបាលរោគ និងការធ្វើ

បុណ្យនេះឯ ៗ ការធ្វើបុណ្យនេះ ទុកថាជាកិច្ចសម្បូរសម្រេចប្រសិទ្ធិពរ ប្រគេនចំពោះព្រះមុនីកោសល សូមរោគាពាធក្នុងរាងកាយ ព្រះតេជព្រះគុណនេះ បានជាសះស្បើយល្ហើយ ជ្រះស្រឡះ តាំងពីពេលនេះតទៅ ដោយអំណាចគុណព្រះរតនត្រ័យ និងបុណ្យកុសលនេះ!

សម្ដេចព្រះពោធិវង្ស ព្រះករុណាទាំងឡាយ លោកអ្នកពុទ្ធបរិស័ទទាំងឡាយ សូមជួយតាំងព្រះទ័យ តាំងចិត្តប្រសិទ្ធិពរ ប្រគេនជោគជ័យសិរីមង្គលចំពោះព្រះមុនីកោសល ដោយព្រះទ័យដោយចិត្តដ៏បរិសុទ្ធគ្រប់អង្គ គ្រប់ៗគ្នា ដើម្បីរម្ងាប់រោគនៃព្រះតេជព្រះគុណព្រះមុនីកោសលឲ្យជាសះស្បើយធុតពាប់រួសកន់ ឲ្យមានសុខភាពបរិបូណ៌ឡើងវិញ អំពីពេលនេះតរៀងឆ្ងាយទៅ! សូមសម្ដេច សូមព្រះករុណាគ្រប់ព្រះអង្គ សូមលោក-អ្នកទាំងឡាយ ជួយបញ្ចេញក្រសែជូនចិត្តដ៏បរិសុទ្ធ ឲ្យដោតដៅត្រង់ឆ្ពោះទៅរកព្រះតេជព្រះគុណព្រះមុនីកោសល ដែលកំពុងមានរោគរោគបំពង់ក ឲ្យបានជាស្រាកស្រាន្តធូរស្រាលសះស្បើយ ដោយអំណាចតេជះគុណព្រះរតនត្រ័យ និងអានុភាពនៃចិត្តដ៏បរិសុទ្ធក្នុងបុណ្យកុសលនេះ កុំបីឃ្លៀងឃ្លាត!

សុន្ទរកថានៃខ្ញុំព្រះករុណា អាត្មាភាព ដែលថ្លែងមកនេះ កាលបើលោកអ្នកពុទ្ធិកជនមានសេចក្ដីពេញចិត្តជូនចំណងប្រាថ្នានេះហើយ សូមតាំងសច្ចាធិដ្ឋានដោយចិត្តស្មោះត្រង់ ហើយបន្លឺនូវវាចាជាពីសក្ដាំងថា សាធុបីដងឲ្យព្រមៗគ្នាទៅហោង! ចប់ ។

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## សកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ
## ក្នុងខែ មិថុនា និង កក្កដា ១៩៦៧

១– ចលនាបុគ្គលិក.–

សហ. គុយ-សូត្រ បានចូលនិវត្តន៍តាំងពីថ្ងៃ ២១–៦ ៦៧ តាមអំណាចប្រកាសក្រសួងមហាផ្ទៃលេខ ១៣៣៨ ចុះថ្ងៃទី ៣–៦–៦៧ ។

សហ. ខឹម សួរ អ្នកនិពន្ធតែងសេចក្តី ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ បានត្រូវតែងតាំងជាលេខាធិការ ជំនួស សហ. គុយ-សូត្រតាមអំណាចប្រកាសក្រសួងហេរញ្ញវត្ថុ លេខ ១៧៣៤ ចុះថ្ងៃ ២១-៦-៦៧ ។

សហ. លឹម-លាងជិន អត្តលេខ ៥១៧៤ គ្រូបង្រៀនថ្នាក់បំពេញវិជ្ជា ថ្នាក់លេខ ១ ជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ត្រូវបានច្បាប់ឈប់សម្រាកពិសេសចំនួនពីរខែ តាមសេចក្តីសុំរបស់សាមីខ្លួន ដើម្បីទៅឈរឈ្មោះជាបេក្ខជនបោះឆ្នោតរើសតំណាងរាស្ត្រ; តាមលិខិតអនុញ្ញាតនៃក្រសួងធម្មការ លេខ ១១ ប. ចុះថ្ងៃ ២៩-៧-៦៧ ។

២– ការទាក់ទងផ្សេងៗ.–

ក្រៅពីការទាក់ទងសំបុត្រស្នាមជាមួយក្រសួង និង ក្រុមរាជការនានា វិជ្ជាឋានបានធ្វើអំណោយសៀវភៅព្រះត្រៃបិដកមួយចប់ ទៅតម្កល់ទុកនៅ

ក្រុងប៉ារីឡាំង តាមសេចក្តីស្នើសុំនៃឯកអគ្គរាជទូតយើង ប្រចាំក្រុងមូស្គូ ហើយដែលក្រសួងការបរទេសបានស្នើបន្តមក ។

បានប្រគេនតាមសេចក្តីសុំនូវ សៀវភៅធម៌ផ្សេងៗ ចំនួន ១០០០ ក្បាល ចំពោះសម្តេចព្រះសង្ឃនាយក ដើម្បីព្រះអង្គចែកទៅតាមវត្តនានាដែលព្រះអង្គនិមន្តទៅតាំងមេគណ-អនុគណ ខាងគណៈធម្មយុត្តិកនិកាយ ។

៣- ខាងផ្នែកបោះពុម្ពផ្សាយ.-

បានបើកការដេញថ្លៃបោះពុម្ពព្រះត្រៃបិដក តាំងពីភាគ ៩១ ដល់ភាគ ១០១ ។ សព្វថ្ងៃការបោះពុម្ពនេះ កំពុងប្រព្រឹត្តទៅយ៉ាងទៀងទាត់ ដើម្បីសេចក្តីត្រេកអរនៃពុទ្ធសាសនិកយើង ដែលតែងរង់ចាំឲ្យបោះពុម្ពឲ្យបានចប់ឆាប់ៗ ព្រោះពីដើមមក ក្នុងមួយឆ្នាំបោះបានតែ ២ ឬ ៣ ភាគប៉ុណ្ណោះ ។

ក្រៅពីព្រះត្រៃបិដកដប់ភាគនេះ វិជ្ជាឋានបានចាត់ការបោះឡើងវិញនូវសៀវភៅផ្សេងៗ ចំនួន ៦ មុខទៀត ដែលបោះពីលើកមុនហើយលក់អស់ទៅ គឺសៀវភៅប្រជុំរឿងព្រេងភាគ ១-ភាគ ៦, រឿងក្រុងសុភមិត្រ, ពន្លឺអាស៊ីទ្វីប, ពិធីទូខសមាសជាភាសាបារាំង និង គិហិបដិបត្តិ ។

៤- បណ្ណាល័យ.-

ក្នុងរយៈពីរខែនេះ បណ្ណាល័យបានទទួលសៀវភៅថ្មីមកទៀតចំនួន

៦៩១ ។ មានអ្នកចូលមកអានចំនួន ៤៣៨ និងអ្នកមកខ្ចីសៀវភៅឯកសារផ្សេងៗ ៤១ នាក់ ។

៥– ការទទួលភ្ញៀវបរទេស.–

ក្នុងពេលពីរខែនេះ វិជ្ជាឋានបានទទួលភ្ញៀវបរទេសពីរដងគឺ :

ពីថ្ងៃ២៩ មិថុនា ១៩៦៧ បានទទួលលោក ហ្វា-វ៉ាន់ ក្វាង និង លោក ង្វៀង-វ៉ាន់ ម៉ាយ ជាតំណាងទីភ្នាក់ងារយ៉ាយហ្វុង ធ្វើការនៅស្ថានតំណាងរណសិរ្សសេរីការជាតិវៀតណាមខាងត្បូងប្រចាំក្រុងភ្នំពេញ ដែលអញ្ជើញមកជួបគួរសម និង ស្រង់យកពត៌មាន ខាងវប្បធម៌ និង អរិយធម៌ខ្មែរ ។

ថ្ងៃ ៣១ កក្កដា ១៩៦៧ បានទទួលលោក រ៉ាំងសង់-ម៉ុងតី នាយកវិជ្ជាឋានខាងគោលនិយមអាហ្វ្រិកខ្មៅ នៅប្រទេសសេណេហ្គាល់ ដែលលោកត្រូវធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសកម្ពុជាយើង ។

# ពិធីប្រគល់បរិញ្ញាបត្រនៃពុទ្ធិកមហាវិទ្យាល័យ

សេចក្ដីរាយការណ៍របស់ សហ. លី-ធាមតេង

ថ្ងៃ ទី ១៩ សីហា ១៩៥៧ វេលាម៉ោង ៨ ព្រឹក នៅក្នុងបណ្ណាល័យនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មានការជួបជុំគ្នារវាងមន្ត្រីសង្ឃរាជាគណៈហនានុក្រមព្រមទាំងសាស្ត្រាចារ្យ បព្វជិតនិងគ្រហស្ថ, ឥស្សរជនស៊ីវិលជាច្រើនរូបដែលបាននិមន្ត និង អញ្ជើញមកជួបជុំក្នុងពិធីប្រគល់បរិញ្ញាបត្រនៃពុទ្ធិកមហាវិទ្យាល័យជាលើកដំបូង ចំពោះសមណនិស្សិតដែលទើបប្រឡងជាប់ចំនួន ៨ រូប ។ ពិធីនេះ បានប្រព្រឹត្តទៅ នៅក្រោមអធិបតីភាព នៃសម្ដេចព្រះពោធិវង្ស និង សហជីវិនទេសរដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងធម្មការ ។

នៅម៉ោង ៨ កន្លះ ភ្ញៀវកិត្តិយសបាននិមន្ត អញ្ជើញមកជួបជុំក្នុងកន្លែងប្រារព្ធពិធី ដែលគេសង្កេតឃើញផ្នែកខាងព្រះសង្ឃ មានៈ ព្រះរាជតំណាងសម្ដេចព្រះសង្ឃរាជ ព្រះតំណាងសម្ដេចព្រះសង្ឃនាយក, សម្ដេចព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សាព្រមទាំងព្រះសង្ឃរាជាគណៈហនានុក្រម និងព្រះសង្ឃជាសាស្ត្រាចារ្យច្រើនព្រះអង្គ ផ្នែកខាងគ្រហស្ថ មានជាអាទិ សហជីវិន អ៊ុង-ហ៊ុងសាត ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ, សហជីវិន ចៅ សេង ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងសេដ្ឋកិច្ចជាតិ និង ជាអធិបតីនៃពុទ្ធិកមហាវិទ្យាល័យ, សហជីវិន វណ្ណ-មូលីវណ្ណ រដ្ឋមន្ត្រីក្រសួងអប់រំជាតិ, សហជីវិន គីង-គុន

មហាវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទ, សហជីវិន អ៊ុក-ម៉ុត អនុរដ្ឋលេខាធិការក្រសួងធម្មការ, អស់លោកសាស្ត្រាចារ្យសំខាន់ ៗ មន្ត្រីអ្នករាជការខ្លះ នៅក្រសួងធម្មការ ព្រមទាំងអស់លោក ជាភ្ញៀវកិត្តិយសច្រើនទៀត ដែលយើងសុំអភ័យទោស ដោយកប់ទាមមិនបាន អស់នៅក្នុងពេលនេះ ។

ពិធីនេះផ្តើមឡើង គឺមានសហជីវិន កែ-ម៉េងហាប់ ជាអគ្គលេខាធិការ នៃពុទ្ធិកមហាវិទ្យាល័យ ថ្លែងសុន្ទរកថាមួយ ហើយបន្ទាប់មក សហជីវិនទេសរដ្ឋមន្ត្រី ក៏បានថ្លែងឆ្លើយតបវិញ ។ សុន្ទរកថាទាំងពីរនេះ មានសេចក្តីដូចតទៅ ៖

សុន្ទរកថារបស់សហជីវិន អគ្គលេខាធិការ
ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ថ្លែងក្នុងឱកាសពិធី
ប្រគល់បរិញ្ញាប័ត្រ ចំពោះនិស្សិត ពុទ្ធិកវិទ្យាល័យ ព្រះសីហនុរាជ

---

សូមប្រណិបតន៍សហជីវិនទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ
សូមក្រាបថ្វាយបង្គំព្រះរាជគណៈសម្តេចព្រះសង្ឃរាជ, ព្រះ
គណៈសម្តេចព្រះសង្ឃនាយក, សម្តេចព្រះពោធិវង្ស
ព្រមទាំងព្រះថេរានុត្ថេរគ្រប់ព្រះអង្គ
សូមគោរព សហជីវិន សហជីវិនី,

ថ្ងៃសៅរ៍ ១៩ ខែសីហា គ.ស. ១៩៦៧ នេះ ជាថ្ងៃមួយប្រកប

ដោយនក្ខត្តឫក្សជោគជ័យសិរីមង្គល ចំពោះពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ព្រោះជាថ្ងៃដែលសមណនិស្សិត ពុទ្ធិកមហាវិទ្យាល័យ ផ្នែកទុតិយភូមិ ត្រូវទទួលជាផ្លូវការនូវបរិញ្ញាបត្រដែលជា ជោគជ័យនៃជំហានទី ២ របស់ពុទ្ធិកមហាវិទ្យាល័យ បន្ទាប់ពីជោគជ័យនៃជំហានទី ១ ដែលពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ បានទទួលកាលពីឆ្នាំ ១៩៦២ ក្នុងឱកាសធ្វើពិធីប្រគល់សញ្ញាបត្រ ពុទ្ធិកឧត្តមសិក្សា បឋមភូមិ ។

ក្នុងនាមនៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និងយ៉ាងស្មោះស្ម័គ្របំផុត ជូនចំពោះសហជីវិនទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ ដែលបានអញ្ជើញមកជាអធិបតី ក្នុងពិធីប្រគល់បរិញ្ញាបត្រជាគ្រាដំបូង ចំពោះសមណនិស្សិតនៃពុទ្ធិកមហាវិទ្យាល័យ ញ៉ាំងពិធីនេះ ឲ្យរឹងរឹតតែមានភាពឧឡារិកឡើង ព្រមទាំងថ្លែងនូវអំណរគុណប្រគេន-ជូនចំពោះព្រះថេរានុត្ថេរៈ សហជីវិនី សហជីវិន គ្រប់ព្រះអង្គ គ្រប់រូប ដែលបាននិមន្ត អញ្ជើញមកជាកិត្តិយសទទួលអបអរសាទរក្នុងពិធីនេះ ដែលជានិមិត្តនៃជោគជ័យថ្មីមួយទៀតរបស់ពុទ្ធិកមហាវិទ្យាល័យ ។

បន្ទាប់ពីនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុញ្ញាតអំពីសហជីវិនទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ ដើម្បីថ្លែងដោយសង្ខេបនូវដំណើរការណ៍ នៃការសិក្សារបស់ពុទ្ធិកមហាវិទ្យាល័យ ដំណើរការណ៍ដែលបានប្រព្រឹត្តទៅដោយជោគជ័យសិរីមង្គល ។

កាលពីឆ្នាំ ១៩៥៣ សម្តេចព្រះពោធិវង្ស កាលមានសមណស័ក្តិជាព្រះពោធិវង្ស បានទទួលព្រះបរមរាជានុញ្ញាត ពីព្រះករុណា, ព្រះបាទសម្តេចព្រះនរោត្តម សីហនុ គឺសម្តេចព្រះប្រមុខរដ្ឋ កាលព្រះអង្គទ្រង់គង់នៅក្នុងព្រះរាជសម្បត្តិនៅឡើយ ឲ្យទៅពិនិត្យមើលការសិក្សា ខាងព្រះពុទ្ធសាសនា នៅបរទេសអស់រយៈកាល ១ខែ ។ លុះត្រឡប់មកវិញ សម្តេចព្រះពោធិវង្សបានធ្វើសេចក្តីរាយការណ៍ យ៉ាងពិស្តារថ្វាយព្រះករុណាជាម្ចាស់ជីវិត ដើម្បីទ្រង់ជ្រាប ។ ព្រះករុណាជាម្ចាស់ជីវិត លុះទ្រង់បានជ្រាបសេចក្តីរាយការណ៍នោះហើយ ទ្រង់បានព្រះរាជបញ្ជាទៅក្រសួងធម្មការ ឲ្យចាត់ការបង្កើតគណៈកម្មការ ជំនំពិនិត្យដោយរួសរាន់ ។ គណៈកម្មការនោះបានជំនុំពិគ្រោះគ្នារួចហើយ បានធ្វើសេចក្តីរាយការណ៍ថ្វាយព្រះករុណាជាម្ចាស់ជីវិត ដោយស្នើសុំបង្កើតពុទ្ធិកមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា ។ ព្រះករុណាជាម្ចាស់ជីវិត ព្រះបាទ នរោត្តម សីហនុ កាលទ្រង់បានជ្រាបសេចក្តីរាយការណ៍របស់គណៈកម្មការសព្វគ្រប់ហើយ ទ្រង់សព្វព្រះរាជហឫទ័យសម្រេចឲ្យបង្កើតពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ដោយព្រះរាជក្រមលេខ ៨៧៩ ន.ស. ចុះថ្ងៃទី ១ ខែកក្កដា គ.ស. ១៩៥៤ ។ ដោយខ្វះអគារសិក្សា ដោយមិនទាន់មានកម្មវិធីសិក្សា និងដោយមិនទាន់មានសមណនិស្សិតដែលមានចំណេះវិជ្ជាអាចចូលមកសិក្សាបាននៅឡើយ លុះដល់មក គ.ស. ១៩៥៩ ទើបពុទ្ធិកមហាវិទ្យាល័យ បានបើកទ្វារទទួល

សមណនិស្សិតជាលើកដំបូង ៗ ចាប់តាំងពី គ.ស.១៩៥៩ នោះមក ពុទ្ធិកមហាវិទ្យាល័យបានចំរើនលូតលាស់ជាដរាបរៀងមក ៗ

| | | | |
|---|---|---|---|
| នៅឆ្នាំសិក្សា | ១៩៥៩-៦០ | មាននិស្សិត ចំនួន | ៤០ រូប |
| — | ១៩៦០-៦១ | . . . . . | ៨០ — |
| — | ១៩៦១-៦២ | . . . . . | ១០៧ - |

នៅដំណាច់ឆ្នាំសិក្សា ១៩៦១-៦២ សមណនិស្សិតជំនាន់ទី ១ បានសិក្សាចប់ថ្នាក់ផ្នែកបឋមភូមិ ហើយបានប្រឡងជាប់សញ្ញាប័ត្រ ពុទ្ធិកឧត្តមសិក្សាបឋមភូមិបានចំនួន ២៤ រូប ៗ ក្នុងឆ្នាំនោះពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ បានរៀបចំធ្វើពិធីប្រគល់សញ្ញាប័ត្រជាឱឡារិកម្ពង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះប្រមុខរដ្ឋ ដែលជានិមិត្តរូបនៃជោគជ័យទី ១ របស់ពុទ្ធិកមហាវិទ្យាល័យ ក្នុងដំណើរការសិក្សារបស់ខ្លួន ៗ សមណនិស្សិតជំនាន់ក្រោយបន្តមកទៀត បាននាំគ្នាសិក្សាជាលំដាប់លំដោយរៀងរាល់ឆ្នាំមក ដែលជាហេតុនាំឲ្យមានសមណនិស្សិតថ្មីៗ ទៀត បានប្រឡងជាប់សញ្ញាប័ត្រ ពុទ្ធិកឧត្តមសិក្សាបឋមភូមិ រៀងរាល់ឆ្នាំជាបន្តបន្ទាប់មក ដូចតទៅនេះ ៖

| | | | |
|---|---|---|---|
| ឆ្នាំ | ១៩៦៣ | ប្រឡងជាប់បាន | ៣២ រូប |
| — | ១៩៦៤ | . . . . | ៣៦ — |
| — | ១៩៦៥ | . . . . | ២៥ — |

ឆ្នាំ ១៩៦៦ ប្រឡងជាប់ ២៧ រូប

– ១៩៦៧ . . . . ២៥ –

បូករួមទាំងអស់មកដល់ឆ្នាំ ១៩៦៧ នេះ សមណនិស្សិតដែលបានប្រឡងជាប់សញ្ញាប័ត្រ ពុទ្ធិកឧត្តមសិក្សា បឋមកម្ម មានចំនួន១៦៥ រូបៗ

សមណនិស្សិត ដែលបានប្រឡងជាប់សញ្ញាប័ត្រ ពុទ្ធិកបឋមកម្មខ្លះ បានសុំចុះឈ្មោះបន្តការសិក្សាខាងផ្នែកទុតិយកម្មទៀត ។ ស្ថិតិនិស្សិតផ្នែកទុតិយកម្ម មានដូចតទៅនេះ ៖

ឆ្នាំសិក្សា ១៩៦២ ៦៣ មានចំនួន ១២ រូប

– ១៩៦៣–៦៤ . . . ១៥ –

– ១៩៦៤–៦៥ . . . ២១ –

– ១៩៦៥–៦៦ . . . ៣២ –

– ១៩៦៦–៦៧ . . . ៤៤ –

– ១៩៦៧–៦៨ . . . ៤៨ –

ការសិក្សានៅផ្នែកទុតិយកម្មនេះ មានការចែកជាបរិញ្ញាផ្សេងៗ គ្នាតាមឯកទេសភាពនៃវិជ្ជានីមួយៗ ។ ដើម្បីឲ្យបានសញ្ញាប័ត្រ នៃផ្នែកទុតិយកម្មនេះ សមណនិស្សិតត្រូវសិក្សា ៤ ឆ្នាំយ៉ាងតិច គឺត្រូវប្រឡងជាប់វិញ្ញាបនប័ត្រឧត្តមសិក្សាចំនួនទាំងអស់ ៤ ។ និស្សិតទាំង ៨ រូប ដែលបានប្រឡងជាប់បរិញ្ញាមុនគេ ហើយដែលមានកិត្តិយសនឹងបានទទួល

យកសញ្ញាប័ត្រក្នុងពេលបន្តិចទៀតនេះ សុទ្ធតែជ្រើសរើសយកបរិញ្ញាខាងទស្សនវិជ្ជា ។

ដូច្នេះ សមណនិស្សិតទាំង ៨រូប បានប្រឡងជាប់វិញ្ញាបនប័ត្រឧត្តមសិក្សាចំនួន ៤ គឺ:

- វិញ្ញាបនប័ត្រ ឧត្តមសិក្សា ទស្សនវិជ្ជាទូទៅ
- វិញ្ញាបនប័ត្រ ឧត្តមសិក្សា ទស្សនវិជ្ជាបស្ចិមប្រទេស
- វិញ្ញាបនប័ត្រ ឧត្តមសិក្សា ទស្សនវិជ្ជាបូព៌ាប្រទេស
- វិញ្ញាបនប័ត្រ ឧត្តមសិក្សា សាសនាប្រៀបធៀប ។

សមណនិស្សិតខ្លះទៀត បានជ្រើសរើសយកបរិញ្ញា ខាងវិជ្ជាដទៃៗទៀត ដូចបរិញ្ញាខាងបុរាណភាសាជាដើម ។ ក៏ប៉ុន្តែ សមណនិស្សិតទាំងនោះ ពុំទាន់ដល់គ្រប់ឆ្នាំនឹងប្រឡងយកវិញ្ញាបនប័ត្រ នៅឡើយ ។ ជាសង្ខេបទៅ ឃើញថា តាំងពីបានចាប់បដិសន្ធិឡើង នៅឆ្នាំ ១៩៥៩ រហូតមកដល់ឆ្នាំ ១៩៦៧ នេះ ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ បានបញ្ចេញសញ្ញាប័ត្រ ពុទ្ធិកឧត្តមសិក្សា បឋមភូមិ បានចំនួនទាំងអស់១៦៥, សញ្ញាប័ត្រទុតិយភូមិ គឺបរិញ្ញាប័ត្របានចំនួន ៨ ។ សមណនិស្សិតខ្លះ ដែលបានប្រឡងជាប់បរិញ្ញាប័ត្រ មានបំណងនឹងបន្តការសិក្សាទៅខាងផ្នែកតតិយភូមិទៀត គឺថ្នាក់បណ្ឌិត ។ ដូច្នេះ ក្នុងអនាគតកាលដ៏ខ្លីខាងមុខនេះ ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ មានសេចក្ដីសង្ឃឹមថា នឹង

បានបញ្ចេញសញ្ញាប័ត្រគតិយភូមិ គឺសញ្ញាប័ត្របណ្ឌិត តទៅទៀត ។ ម្ល៉ោះហើយ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមសន្និមទុកជាមុនថា សហជីវិនទេសរដ្ឋមន្ត្រីមុខជានឹងបានអញ្ជើញមកជាអធិបតីនៃពិធីប្រគល់សញ្ញាប័ត្រថ្នាក់បណ្ឌិត របស់ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ក្នុងពេលដ៏ខ្លីខាងមុខនេះទៀត ជាពុំខានឡើយ ។

បើគិតទៅតាមកាលបរិច្ឆេទ ជោគជ័យនៃជំហានទី ១ ក្តី ជោគជ័យនៃជំហានទី ២ ដែលយើងរៀបចំធ្វើពិធីនេះជានិមិត្តរូបក្នុងពេលនេះក្តី ជាជោគជ័យដែលបានកើតឡើង ក្រោយពីប្រទេសខ្មែរយើងបានឯករាជ្យដ៏បរិបូណ៌ ដោយស្នាព្រះហស្តនៃសម្តេចព្រះនរោត្តម-សីហនុ ហើយជាពិសេស ក្នុងសម័យដែលប្រទេសយើងឋិតនៅក្រោមការដឹកនាំ របស់ចលនាសង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះប្រមុខរដ្ឋ ជាព្រះប្រធាន ។

ដូច្នេះ ជោគជ័យទាំងអស់នេះ ជាជោគជ័យរបស់សង្គមរាស្ត្រនិយម ដែលយើងត្រូវរាប់បញ្ចូលទៅក្នុងសមិទ្ធិដ៏ច្រើនឥតគណនា របស់សង្គម-រាស្ត្រនិយម ក្នុងការស្ថាបនាជាតិឲ្យបានទៅជាអារ្យប្រទេស ។

ក្នុងសម័យសង្គមរាស្ត្រនិយម ពុទ្ធិកសិក្សា តាំងពីថ្នាក់តូច រហូតដល់ឧត្តមសិក្សា បានកែរៀបចំឲ្យមានទម្រង់ថ្មីស្របតាមកាលៈទេសៈហើយ ។ គួរកត់សំគាល់ថា ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ជាព្រឹទ្ធសាកលវិទ្យាល័យ បានកើតឡើងមុនគេបង្អស់ក្នុងចំណោមសាកលវិទ្យាល័យទាំង

ឡាយ នៃព្រះរាជាណាចក្រកម្ពុជាយើង ។ ដោយព្រះតម្រិះរបស់សម្តេច ព្រះពោធិវង្ស ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ តាំងតែពីបានកើតឡើង បានយកភាសាខ្មែរមកធ្វើជាភាសា យានក្នុងការបង្ហាត់បង្រៀន ។ ក្នុងសម័យនេះ ដែលក្រសួងអប់រំជាតិ ត្រូវរៀបចំធ្វើខេមរយានកម្មក្នុងការសិក្សាស្របតាមសេចក្តីសម្រេចនៃសមាជជាតិ ពុទ្ធិកមហាវិទ្យាល័យ បានក្លាយទៅជាទីពន្សូចក្នុងចលនាៈខេមរយានកម្មនេះ ពីព្រោះសាស្ត្រាចារ្យទាំងឡាយ ដែលធ្លាប់មានការពិសោធន៍ក្នុងបញ្ហានេះ ខាងពុទ្ធិកសិក្សា បានយកការពិសោធន៍របស់ខ្លួន ទៅអនុវត្តធ្វើសហប្រតិបត្តិការយ៉ាងពេញទំហឹង ក្នុងចលនាជាតិនៃខេមរយានកម្ម ដោយសាស្ត្រាចារ្យខ្លះ បានចូលជាសមាជិករបស់គណៈកម្មាធិការជាតិ សាស្ត្រាចារ្យខ្លះទៀត ធ្វើជាប្រធានឬសមាជិករបស់គណៈកម្មការបច្ចេកទេស នៃខេមរយានកម្ម ដែលក្រសួងអប់រំជាតិ កំពុងតាក់តែងប្រតិបត្តិការ ដើម្បីធ្វើការអនុវត្តន៍ឲ្យបានទាន់នៅបវេសនកាលខាងមុខនេះ ។

ម្យ៉ាងវិញទៀត ចាប់តាំងពីពេលដែលពុទ្ធិកមហាវិទ្យាល័យ បានបញ្ចេញសញ្ញាបត្រនេះមក ពុទ្ធិកមហាវិទ្យាល័យ មានសេចក្តីរីករាយពេញចិត្តនឹងជោគជ័យរបស់ខ្លួនជាអនេក ពីព្រោះពុទ្ធិកមហាវិទ្យាល័យ បានបំពេញបេសកកម្មខ្លួនយ៉ាងហ្មត់ចត់ ស្របទៅតាមព្រះរាជបំណងរបស់ព្រះអគ្គមគ្គុទ្ទេសក៍របស់ខ្លួន ដែលមានព្រះរាជបន្ទូលក្នុងសុន្ទរកថារបស់ព្រះអង្គក្នុងឱកាសសម្ពោធពុទ្ធិកមហាវិទ្យាល័យ ថា :

ការដែលប្រទេសកម្ពុជាយើង បានបង្កើតឲ្យមានពុទ្ធិកមហាវិទ្យាល័យនេះ ជាការដ៏ប្រសើរមួយ ដែលត្រូវតែត្រាទុកក្នុងប្រវត្តិសាស្ត្រនៃជាតិយើង នៃប្រទេសយើង ដែលអំណើះតទៅសាកលលោកសន្មតបានថា មានវឌ្ឍនធម៌ខ្ពង់ខ្ពស់ក្នុងពុទ្ធិកសិក្សា ស្មើបាននឹងអារ្យប្រទេសឯទៀត ដែលកាន់លទ្ធិសាសនាដូចគ្នា ។

ជាការពិតណាស់ អំណើះតទៅ ជាមួយនឹងបរិញ្ញាប័ត្រ ដែលសហជីវិនទេសរដ្ឋមន្ត្រី នឹងប្រគល់ចំពោះទៅនិស្សិតក្នុងពេលបន្តិចទៀតនេះ ពុទ្ធិកមហាវិទ្យាល័យ បានក្លាយខ្លួនទៅជាគ្រឹះស្ថានឧត្តមសិក្សាមួយពេញលក្ខណៈ ដែលនឹងធ្វើឲ្យប្រទេសយើង ដែលតំកល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ មិនខ្មាសប្រទេសឯទៀត ដែលកាន់ព្រះពុទ្ធសាសនាដូចយើង ហើយថែមទាំងធ្វើឲ្យប្រទេសយើងរឹងរឹតតែមានកិត្យានុភាពខ្ពង់ខ្ពស់ឡើងទៀតៗ

ជោគជ័យរបស់ពុទ្ធិកមហាវិទ្យាល័យ បានចង្អុលឲ្យឃើញម្យ៉ាងទៀតថា នៅក្នុងកម្ពុជរដ្ឋយើង ពុទ្ធចក្របានរីកយ៉ាងលឿនស្របគ្នា នឹងអាណាចក្រ ។ នេះជាភស្តុតាងមួយបញ្ជាក់យ៉ាងច្បាស់លាស់ថា សង្គមរាស្ត្រនិយម ក្រោមការដឹកនាំយ៉ាងកេងវៃរបស់សម្ដេចព្រះនរោត្តម-សីហនុ ពុំបានភ្លេចក្នុងវិស័យណាមួយទេ ក្នុងការកសាងជាតិ ក្នុងវិស័យពុទ្ធចក្រ ក៏ដូចជាក្នុងវិស័យអាណាចក្រដែរ ។

គឺដោយសារការដឹកនាំ និង ការឧបត្ថម្ភគ្រប់បែបយ៉ាង របស់សង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះប្រមុខរដ្ឋ ជាព្រះប្រធាននេះ ហើយ ដែលនាំឲ្យសមណនិស្សិតបានខំប្រឹងប្រែងព្យាយាមយកចិត្តទុកដាក់ក្នុងការសិក្សារៀនសូត្រ ដែលនាំឲ្យអស់លោកសាស្ត្រាចារ្យ ទាំងបណ្ឌិត ទាំងគ្រហស្ថ ព្រមទាំងបុគ្គលិកនៃមន្ទីរបាត់ការពុទ្ធិកវិទ្យាល័យ ខំប្រឹងប្រែងចង្អុលបង្រៀន និង ខំប្រឹងប្រែងបំពេញកិច្ចការផ្សេងៗ យ៉ាងហ្មត់ចត់ នាំឲ្យពុទ្ធិកមហាវិទ្យាល័យ បានស្គាល់នូវជោគជ័យដ៏ប្រសើរ ដែលខ្ញុំព្រះករុណា ខ្ញុំបាទ បានរៀបរាប់ដោយសង្ខេបអម្បាញ់មិញនេះ ។ អាស្រ័យហេតុនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុញ្ញាតអំពីសហជីវិនទេសរដ្ឋមន្ត្រី ដើម្បីធ្វើឱកាសនេះ ថ្លែងនូវអំណរគុណ យ៉ាងស្មោះស្ម័គ្រ និងសេចក្តីសរសើរយ៉ាងកក់ក្តៅចំពោះសមណនិស្សិត ចំពោះអស់លោកសាស្ត្រាចារ្យ និងចំពោះបុគ្គលិកនៃមន្ទីរចាត់ការ ដែលបានបំពេញពលិកម្មគ្រប់បែបយ៉ាង ក្នុងការបំរើពុទ្ធិកសិក្សាឲ្យបានជោគជ័យ ដូចបានបញ្ជាក់ប្រគេន-ជូន រួចមកហើយ ។

ម្យ៉ាងវិញទៀត ជោគជ័យរបស់ពុទ្ធិកមហាវិទ្យាល័យ បានកើតមកពីការជ្រោមជ្រែងជួយឧបត្ថម្ភរបស់ពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ ដូចជាការឧបត្ថម្ភរបស់គហបតី ប៉េ.យ៉ាន ជាដើម ដែលបានកសាងអគារសិក្សាមួយខ្នងយ៉ាងធំ ទុកជាសម្បត្តិរបស់រដ្ឋ នៅក្នុងបរិវេណនៃពុទ្ធិកមហាវិទ្យាល័យ

ដើម្បីជាអនុស្សាវរីយ៍របស់លោក ក្នុងការស្ដួយព្រះពុទ្ធសាសនាឲ្យបានរុងរឿងឡើង មួយផ្នែកទៀត ដោយសារការខំប្រឹងប្រែងឥតឈប់ឈររបស់សម្ដេចព្រះពោធិវង្ស. អគ្គាធិការ ពុទ្ធិកសិក្សា ដែលព្រះអង្គបានបរិច្ចាគឥតសំច័យនូវកម្លាំងព្រះកាយ និង កម្លាំងព្រះទ័យ ទុកណាជាព្រះអង្គមានព្រះជន្មវស្សាក្រាស់ក្រៃលណាស់ទៅៈហើយក៏ដោយ ហើយជាពិសេសបំផុត គឺដោយសារព្រះបរមពុទ្ធូបត្ថម្ភគ្រប់កាលៈទេសៈ ទាំងខាងផ្លូវចិត្តនិងខាងផ្លូវសម្ភារៈ នៃព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ សម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចព្រះប្រមុខរដ្ឋ ដែលព្រះអង្គយកព្រះទ័យទុកដាក់ជាពិសេសចំពោះពុទ្ធិកសិក្សានេះ ។

ដើម្បីជាកិច្ចតបស្នងសងព្រះមហាករុណាធិគុណដ៏ធ្ងន់នេះ ខ្ញុំព្រះករុណាខ្ញុំបាទ ក្នុងនាមនៃពុទ្ធបរិស័ទទាំងអស់ ទាំងបព្វជិត ទាំងគ្រហស្ថ សូមបួងសួងចំពោះវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាស្វេតច្ឆត្រជាដើម សូមជួយទ្រទ្រង់អភិបាលសម្ដេចព្រះមហាក្សត្រិយានី និង សម្ដេចព្រះប្រមុខរដ្ឋ សូមព្រះអង្គបានប្រកបដោយព្រះសុខភាពបរិបូណ៌ ឈ្នះអស់មារសត្រូវគ្រប់ទិសទី មានព្រះជន្មាយុយឺនយូរពេប់រយព្រះវស្សា ដើម្បីបានជាម្លប់ដ៏ត្រជាក់នៃកូនចៅរបស់ព្រះអង្គតរៀងទៅ ។ មួយចំណែកទៀត សូមឲ្យវត្ថុស័ក្តិសិទ្ធិទាំងនោះ ជួយទ្រទ្រង់ពុទ្ធបរិស័ទទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងបព្វជិត ទាំងគ្រហស្ថ ឲ្យបានប្រកប

ដោយពុទ្ធពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សេចក្ដីគួរពុំគួរ សូមសហជីវិនទេសរដ្ឋមន្ត្រី សូមសម្ដេចជាអម្ចាស់ សូមព្រះថេរានុត្ថេរ សូមសហជីវិនី សហជីវិន មេត្តាប្រោសប្រណី ។

---

# សុន្ទរកថា

សហជីវិនទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ

សូមនមស្សការ ដោយគោរព ចំពោះសម្ដេចព្រះពោធិវង្ស

សូមនមស្ការ ចំពោះព្រះថេរានុត្ថេរៈ

សូមគោរព ចំពោះសហជីវិនទាំងអស់

ក្នុងឱកាសនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ ក្នុងឋានៈជាទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ មានសោមនស្សរីករាយណាស់ ដោយបានទទួលនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ ក្នុងឋានៈជាអធិបតី នៃពិធីប្រគេន ជូន នូវបរិញ្ញាប័ត្រចំពោះអស់លោកនិស្សិត ជាបព្វជិតខ្លះ ជាគ្រហស្ថខ្លះ ដែលបានសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ នេះ ហើយបានទទួលនូវលទ្ធផលដ៏ប្រសើរ ។

មុននឹងប្រគេន ជូន នូវបរិញ្ញាប័ត្រ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមភនឱកាសបន្តិច ដើម្បីថ្លែងពតិមានខសង្ខេបដែលទាក់ទងនឹងពុទ្ធិកសិក្សានេះ ។

អម្បាញ់មិញនេះ សហជីវិន អគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យ បានថ្លែងសុន្ទរកថាយ៉ាងគ្រោះក្រាយ អំពីមូលហេតុដែលនាំឲ្យពុទ្ធិកមហាវិទ្យាល័យ បានកើតឡើងអំពីការប្រព្រឹត្តទៅនៃពុទ្ធិកសិក្សាតាំងពីបឋមសិក្សា រហូតដល់ឧត្តមសិក្សា ដែលបានប្រកបដោយសុវត្ថិភាព និងប្រកបដោយជោគជ័យជាដរាបរៀងមក ។

សេចក្តីថ្លែងរបស់សហជីវិនអគ្គលេខាធិការនេះ បានមកដាស់ស្មារតីខ្ញុំឲ្យភ្ញាក់រលឹកឃើញឥតមានសល់ ព្រោះខ្លួនខ្ញុំនេះមិនមែនឋិតនៅឆ្ងាយអំពីពុទ្ធិកសិក្សានេះទេ គឺខ្លួនខ្ញុំបានធ្លាប់បំរើពុទ្ធិកសិក្សានេះច្រើនដងហើយ ដោយហេតុថា ខ្លួនខ្ញុំនេះធ្លាប់ធ្វើជាលេខាធិការផ្ទាល់ នៃរដ្ឋមន្ត្រីក្រសួងធម្មការមុន តមកទៀត បានធ្វើជារដ្ឋលេខាធិការក្រសួងធម្មការពីរដងផង ឥឡូវបានធ្វើជាទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការទៀត គឺខ្ញុំមានភ័ព្វវាសនាបានចូលរួមក្នុងពិធីបញ្ចុះបឋមសិលា ខាងពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ព្រមទាំងកម្មវិធីខាងការសិក្សាទៀតផង ។ ដោយហេតុនេះ ខ្ញុំសូមបញ្ជាក់ថា សេចក្តីថ្លែងរបស់សហជីវិនជាការពិតមែនទាំងអស់ ហើយសូមបន្ថែមថាការប្រព្រឹត្តទៅនៃពុទ្ធិកសិក្សាគ្រប់ផ្នែក ខ្លួនខ្ញុំក្តី អស់លោកទាំងឡាយឯទៀតក្តី ពុំអាចនឹងបំភ្លេចបានឡើយ នូវការខំប្រឹងប្រែងព្យាយាមនិងការតស៊ូស្វិតស្វាញជាទីបំផុត នៃសម្តេចព្រះពោធិវង្ស ដើម្បីឲ្យពុទ្ធិកសិក្សាបីផ្នែកបានកើតមានឡើង ដោយមានរបៀបរបបត្រឹមត្រូវ ក្រោម

ព្រះបរមរាជូបត្ថម្ភ ដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្ដេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក ។

លំដាប់តទៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមសរសើរដោយស្មោះ ចំពោះអស់លោកជាសាស្ត្រាចារ្យ ដែលបានខំបង្ហាត់បង្រៀនដោយយកព្រះទ័យ យកចិត្តទុកដាក់ដល់សមណនិស្សិតគ្រប់រូប សូមសរសើរចំពោះអស់លោកជានិស្សិតគ្រប់រូប ដែលបានខំប្រឹងព្យាយាមតស៊ូក្នុងការសិក្សា នូវចំណេះវិជ្ជា ទាំងខាងផ្លូវព្រះពុទ្ធសាសនា ទាំងខាងផ្លូវលោក អស់រយៈកាលច្រើនឆ្នាំ រហូតដល់បានសម្រេចផលដ៏ប្រសើរ គឺត្រូវបានទទួលនូវបរិញ្ញាប័ត្រជាគ្រាដំបូងបំផុតនេះ ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងបញ្ជាក់ថា អស់លោកនិស្សិតដែលបានទទួលបរិញ្ញាប័ត្រ អំពីពុទ្ធិកមហាវិទ្យាល័យនេះ ត្រូវចាត់ទុកថាជាអ្នកមានចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់ ទាំងខាងផ្លូវព្រះពុទ្ធសាសនា ទាំងខាងផ្លូវលោក សមជាវិញ្ញូកុលបុត្រ ឬវិញ្ញូជន នៃប្រទេសកម្ពុជា សម័យថ្មី ដែលបានទទួលយកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

នៅអវសាននេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រគេន-ជូន ពរសព្វសាធុការ ចំពោះអស់លោកជានិស្សិតទាំងអស់ សូមឲ្យបានប្រកបដោយពរទាំង ៤ ប្រការ គឺអាយុ: វណ្ណ: សុខ: ពល: និង បដិភាណ: គ្រប់ទិវារាត្រី កុំបីឃ្លៀងឃ្លាតឡើយ ។

×

បន្ទាប់ពីសុន្ទរកថាទាំងពីរនេះមក ព្រះភិក្ខុ ប៉ាង-ខាត់ សាស្ត្រាចារ្យ និមន្តឡើងហៅនាមបេក្ខសមណៈ ដែលត្រូវមកទទួលបរិញ្ញាបត្រនេះមួយម្តងៗ តាមលំដាប់ថ្នាក់ គឺមាននាមដូចតទៅ ៖

១– ទុំ-ឡៃ

២- ពាវ-ឆៃសុក

៣ អេង-ប៊ន

៤. ជា-ហាំង

៥ ឆោម-បាន

៦– គិម-កៀង

៧– លី-សុរិ

៨ ពុទ្ធ-សំអុល

តពីនេះមកទៀត សម្តេចព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សាកម្ពុជរដ្ឋ និងជាស្ថាបត្យករដ៏ធ្ងើមខាងពុទ្ធិកសិក្សារបស់ខ្មែរយើង ព្រះអង្គទ្រង់មានព្រះថេរដីកា ផ្តែផ្តាំ ប្រៀនប្រដៅចំពោះអ្នកដែលទទួលសញ្ញាប័ត្រដ៏ឧត្តមទាំងនេះ ដោយព្រះកត្រូញញឹម ព្រះកាចមួយៗ តែប្រកបដោយខ្លឹមសារ ពោរពេញដោយគតិបណ្ឌិត ដែលយើងសូមដកស្រង់តែខ្លះ ដូចតទៅ ៖

ជាបឋម សម្តេចទ្រង់ថ្លែងព្រះអំណរចំពោះកៀរតិគ្គយស ជាពិសេស

គឺវរជនសំខាន់ៗ ដែលបានអញ្ជើញមកក្នុងពិធីនេះ ដែលធ្វើឲ្យទឹកព្រះទ័យព្រះអង្គសប្បាយដោយសារកិត្តិយសនេះពន់ប្រមាណ ។ សម្តេចទ្រង់រាប់រៀបអំពីការលំបាកខ្លះ ដែលកើតមានក្នុងជីវភាពសមណនិស្សិត ដែលបានទំពុះពារមកតាំងពីបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សាក្នុងរយៈកាលមួយយ៉ាងវែង ។

បន្ទាប់មក ទ្រង់បែរព្រះភក្ត្រទៅផ្តាំផ្ញើចំពោះឧត្តមសិស្សរបស់ព្រះអង្គតាំង ៨ រូប មាន ៣ សំខាន់ គឺ៖

១ - តម្លៃនៃបរិញ្ញាប័ត្រ.— ព្រះអង្គទ្រង់ដៅបញ្ជាក់ថា៖ នេះជាសក្ខីកម្មមួយបញ្ជាក់ឲ្យស្គាល់ ច្បាស់នូវកំពស់ចំណេះវិជ្ជាដែលយើងមានដែលជាលទ្ធផលដ៏ស្វិតស្វាញ នៃពុទ្ធិកមហាវិទ្យាល័យយើង ជាគ្រាដំបូង ។ ដូច្នេះ អស់លោកដែលបានទទួល ក៏ត្រូវតែរក្សាតម្លៃនេះឲ្យបានហ្មត់ចត់ល្អតទៅ ។

២- អំពីសារៈប្រយោជន៍.— ព្រះអង្គទ្រង់ផ្តាំបន្តថា ៖ បើយើងបានទទួលសញ្ញាប័ត្រដ៏ខ្ពង់ខ្ពស់ដូច្នេះហើយ យើងពុំខិតខំប្រឹងរៀនសូត្របន្ថែមវិជ្ជា ឬផ្សព្វផ្សាយឲ្យបានល្អនូវចំណេះដែលយើងមានមកហើយទេ នោះបរិញ្ញាប័ត្រយើង ក៏បាត់គ្មានតម្លៃអ្វីដែរ ។ ហេតុនេះ គួរតែប្រកាន់ខ្ជាប់នូវការព្យាយាមស្វែងវិជ្ជាបន្ថែម និងប្រើការនូវវិជ្ជានេះ ឲ្យបានត្រឹមត្រូវ ហើយបានសាយភាយទូលំទូលាយផង ។

៣– អំពីគុណសម្បទរៀនខ្លួន.– បើយើងមានវិជ្ជាខ្ពង់ខ្ពស់ហើយ យើងតោងតែរក្សាចរិយារបស់យើងឲ្យសមរម្យជាអ្នករៀនសូត្រ ជ្រៅជ្រះខាងព្រះពុទ្ធសាសនា ចំជៀសកង់ឲ្យផុតពីពាក្យនិន្ទា ដែលអាចកើតមានពេលណាដែលៈយើងភ្លេចខ្លួន ។ បើមានចរិយាប្រពៃជាទីគោរពរាប់អានបែបនេះ កេរ្តិ៍ឈ្មោះយើងក៏ល្អ បរិញ្ញាបត្រនោះក៏រឹតតែលេចនូវគុណសម្បទពិសេសមួយថែមឡើងទៀត ។

ពិធីនេះបានចប់សព្វគ្រប់នៅម៉ោង ៩ កន្លះ ប្រកបដោយបរិយាកាសយ៉ាងរីករាយក្រៃលែង ។